ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2013, 09:40
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៨: ៣៦នាទី**

**សវនាការលើកទី១៩០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោកស្រី មីរាម ម៉ាហ្វេសហ្សង់ទិ
*(Ms. Miriam MAFESSANTI )*

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

កញ្ញា សុង ឆវ័ន្ត

លោក឵ ឃីត រ៉េយ៍ន័រ *(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ឡៃ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ស៊ីដនី ស្តេនប៊ឹក (TCW-624) | អង់គ្លេស |
| លោក សុខ រឿ (TCW-665) | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅសាក្សី៖ លោក ស៊ីដនី ស្តេនបឺក (TCW-624)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ....................ទំព័រ ២
សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ១៥
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ២៤

## ការសួរសំណួរទៅសាក្សី៖ លោក សុខ ភឿ (TCW-665)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៤៩
សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ៥២
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ៦៤
សួរដោយលោក ឃីត រេយ៍ន័រ ផ្តើមពី....................ទំព័រ ៦៩
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពី ....................ទំព័រ ៨១
សួរដោយលោក ពេជ អង្គ ផ្តើមពី ....................ទំព័រ ៨២
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្តើមពី ....................ទំព័រ ៨៦

# កិច្ចដំណើរការនីតិវិធី

[០៨:៣៦:០៥]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ នាពេលព្រឹកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស៊ីដនី ស្កេនប៊ឺក តាមប្រព័ន្ធសោតទស្សន៍ពីទីក្រុងញូវយ៉កសហរដ្ឋអាមេរិក។ ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីអត្តចរិតដែលមានរហស្សនាម TCW-665។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីខាងក្រោមបន្ទប់សវនាការនេះតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

នៅព្រឹកនេះ យើងនឹងបន្តបញ្ចប់ការស្តាប់សក្ខីកម្មសាក្សី ស៊ីដនី ស្កេនប៊ឺក តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក។ ហើយសាក្សីរូបនេះ បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្តល់សក្ខីកម្មផងដែរ។ ឯនៅពេលរសៀលនឹងសក្ខីកម្មសាក្សីសាក្សីដែលមានរហស្សនាម TCW-665។ សាក្សីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំៗការកោះហៅពីអង្គជំនុំជម្រះ។ សម្រាប់សវនាការថ្ងៃនេះមានសាក្សីបម្រុងមួយរូបគឺសាក្សីដែលមានរហស្សនាម TCW-742។ សូមអរគុណ។

[០៨:៣៧:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

សួស្តីលោក ស្កេនប៊ឺក! តើលោកបានត្រៀមខ្លួនហើយឬនៅ?

**លោក ស៊ីដនី ស្កេនប៊ឺក៖**

បាទ លោកប្រធាន ខ្ញុំរួចរាល់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៨:៣៨:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម។

**តាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សាយ័ណ្ហសួស្តីលោក ស្កេនប៊ឺក។ កាលពីម្សិលមិញ យើងបានបញ្ចប់ត្រឹមការនិយាយគ្នាថ្ងៃ១៧ មេសា ៧៥។ ខ្ញុំចង់ចូលទៅនិយាយយប់មុនថ្ងៃ១៧ មេសា ៧៥។ ខ្ញុំសូមឲ្យលោកចូលមើលទៅលើកំណត់ត្រាប្រចាំថ្ងៃរបស់លោកត្រង់ទំព័រ៦១ នៅខាងដើមទំព័រដែលមាន ERN 00898269, ចុះថ្ងៃទី១៦ មេសា ដែលសរសេរដូចតទៅ សូមដកស្រង់៖ "កន្លះម៉ោងក្រោយមក នៅពេលព្រឹកគឺព័ត៌មានចូលមកដល់សារព័ត៌មានអាហ្វ្រង់ប្រេស ដែលថាសម្តេច សីហនុ បដិសេធមិនទទួលយកសំណើ។ គាត់ថាមេដឹកនាំក្រុងភ្នំពេញ ដកស្រង់សម្តីរបស់សម្តេច, សម្តេចបានមានបន្ទូលថា "គឺបើកសម្រាប់តែពួកខាងភ្នំពេញលើកទង់ជ័យស ហើយនិងសុំចុះចាញ់"។ លោក ស្កេនប៊ឺក លោកចាំទេនៅពេលដែលលោកស្តាប់សារព័ត៌មានហ្នឹង តើលោកអាចជម្រាបអង្គជំនុំជម្រះអំពីរបាយការណ៍របស់សម្តេច ការរាយការណ៍របស់សម្តេច សីហនុ បានទេ?

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** គាត់បានរក -- អ្នករបាយការណ៍ខ្លះមកជួបខ្ញុំ ហើយអ្នកខ្លះស្តាប់ការផ្សាយតាមវិទ្យុហ្នឹងទាំងស្រុងតែម្តង។ ខ្ញុំគិតថា វិទ្យុនោះ គឺវិទ្យុ ប៊ី.ប៊ី.ស៊ី។

**ស៖** លោកចាំទេថា មានការរាយការណ៍ទៅលើបញ្ហានេះច្រើនទេដែលថា សម្តេច សីហនុ បានពន្យល់នៅក្នុងការផ្សាយនៅវិទ្យុភ្នំពេញម៉េចបានជាថា វិទ្យុដួលរលំនោះ?

**ឆ៖** ខ្ញុំមិនដឹងលម្អិតនោះទេ ការផ្សាយលម្អិតនេះ ថាហេតុអ្វីបានគាត់ធ្វើការកត់សម្គាល់នេះ។

ប៉ុន្តែវាមិនមានអ្វីធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលទេ។

[០៨:៤១:១៥]

**ស៖** ហេតុអ្វីក៏យ៉ាងដូច្នេះ?

**ផ៖** ដោយសារតែព្រះអង្គមានមូលហេតុផ្ទាល់ខ្លួនដើម្បីគាំទ្រដល់ខ្មែរក្រហម។ ខ្ញុំអត់ដឹងពីមូលហេតុនេះផ្ទាល់ពីព្រះអង្គទេ ប៉ុន្តែខ្ញុំដឹងមនុស្សដទៃទៀតគេបាននិយាយជាមួយព្រះអង្គ ហើយសមាជិកព្រះរាជសានុវង្សក៏មានស្លាប់ខ្លះដែរក្នុងពេលសង្គ្រាម។

**ស៖** លោកចាំទេ នៅក្នុងការផ្សាយនេះថាតើសម្តេចសីហនុ មានបន្ទូលអីផ្សេងៗទេអំពីទាហាន លន់ នល់ តើព្រះអង្គមានបន្ទូលអំពីជោគវាសនារបស់ទាហានទាំងនោះទេ?

**ផ៖** គឺខ្ញុំអត់មាន -- ខ្ញុំអត់ចាំរឿងហ្នឹងទេ។

**ស៖** ឥឡូវចូលទៅថ្ងៃ១៧ មេសា ៧៥ និងមួយថ្ងៃបន្ទាប់។ ខ្ញុំសូមឲ្យលោកចូលទៅមើលទំព័រ៧២ នៃកំណត់ត្រារបស់លោក ជាពិសេសគឺត្រង់កថាខណ្ឌខាងក្រោមមកទី២ ប៉ុន្តែខាងក្រោម ERN 00898280 នៅខាងក្រោមនៃទំព័រនេះ និយាយថា "ជនបរទេសដែលត្រូវបានបោកបញ្ឆោតឲ្យចូលស្ថានទូតនៅថ្ងៃបន្ទាប់នោះ គឺថាមានអ្នកខ្លះស្លាប់នៅតាមផ្លូវដោយសារតែអស់កម្លាំងក្នុងការធ្វើដំណើរ ក៏មានការរាយការណ៍អំពីសម្លាប់ -- កាប់សម្លាប់នោះដែរ ប៉ុន្តែមិនមានសាក្សីផ្ទាល់ភ្នែកឃើញយ៉ាងដូច្នេះទេ"។ តើលោកអាចពន្យល់លម្អិតបន្តិចបានទេ លោក ស្តេនប៊ឹក ត្រង់ឃ្លាចុងក្រោយដែលថាមិនមានសាក្សីផ្ទាល់ -- មិនមានការរៀបរាប់ដំណើររឿងពីនេះសាក្សីផ្ទាល់ភ្នែក?

[០៨:៤៣:២៩]

**ផ៖** ត្រឹមត្រូវហើយ មិនប្រាកដជាអ៊ីចឹងទេ។ នៅក្នុងក្បួនឡានធំនោះ នៅពេលដែលយើងចាកចេញពីទីក្រុងដែលខ្ញុំមិនធ្លាប់ធ្វើដំណើរលើកផ្លូវនោះទេ គឺផ្លូវចូលមកទីក្រុងមានសាកសពរាយប៉ាយពាសពេញមិនមានអ្នកណាវេចខ្ចប់សាកសពទាំងនោះទេ។ ពិបាកនឹងប្រាប់ថា អ្នកទាំង -- សពទាំងនោះជាទាហាន ឬក៏អ្នកប្រជាជនរស់នៅក្នុងទីក្រុង ប៉ុន្តែខ្ញុំឃើញមនុស្សស្លាប់ច្រើនណាស់ រាប់ឡូ។

**ស៖** អ្វីដែលខ្ញុំនិយាយសំដៅទៅនោះ គឺថាតើលោកនេះមួយថ្ងៃក្រោយ ១៧ មេសា ៧៥ ហ្នឹងបានឮរឿងរ៉ាវដែលសាក្សីបានឃើញនៅទីតាំងដែលទាហាន លន់ នល់ ត្រូវបានសម្លាប់នោះដែរឬទេ?

**ផ៖** យើងមិនមានឱកាសនិយាយប្រជាជនក្នុងពេលចាកចេញពីទីក្រុងទេ។ ក្រោយតែខ្ញុំត្រូវបានគេដោះលែងឲ្យមានសេរីភាពនុ៎ង ទើបខ្ញុំនិយាយជាមួយប្រជាជនដែលមានបទពិសោធន៍នៅអ្វីដែល

កើតមានឡើង នូវអ្វីដែលគេមើលឃើញថាជាចំណុចអវិជ្ជមាននោះ។ ខ្លួនខ្ញុំផ្ទាល់ មិនបានឃើញផ្ទាល់ភ្នែកទេ។

[០៨:៤៥:២០]

**សះ** នៅទំព័រ៧៧ នៃកំណត់ត្រាប្រចាំថ្ងៃរបស់លោកត្រង់ ERN 00898285។ ខ្ញុំសូមដកស្រង់ត្រង់ផ្នែកខាងលើនៃទំព័រនេះ "របាយការណ៍បានមកពីប្រភពទីពីរបាននិយាយថា គឺថាបានព័ទ្ធស្ថានទូត គឺថាពួកបះបោរបានសម្លាប់ប្រជាជន រួមទាំង ឡុង បូរ៉េត។ ហើយពាក្យចចាមអារ៉ាម មានការនិយាយដូច្នេះ ប៉ុន្តែមិនមានការអះអាងនោះទេ។ ហើយនៅទំព័រ៨១ -- សូមកែប្រែ ទំព័រ៩១ លោករៀបរាប់ឈ្មោះ ហេនរី បេកយ៉ែរ ហើយក្នុងកថាខ័ណ្ឌទីបីលោកសរសេរដូច្នេះថា "បេកយ៉ែរ មានចំណុចគួរឱ្យចាប់អារម្មណ៍មកប្រាប់យើង។ គាត់និយាយថា ខៀវសំផន មេដឹកនាំខ្មែរក្រហមមិនទាន់មកដល់ ភ្នំពេញទេ។ គាត់និយាយថា ឡុង បូរ៉េត មិនទាន់ត្រូវបានគេសម្លាប់នៅឡើយទេ"។ ខ្ញុំចង់ដឹងថាតើលោកដឹងដោយរបៀបណាអំពីពាក្យចចាមអារ៉ាម ហើយនិងការពិតនិយាយពីការសម្លាប់ទាហាន លន់ នល់ ឬក៏មន្ត្រីរដ្ឋាភិបាល ឬក៏ការសម្លាប់ពួកមហាក្សត់ទាំងប្រាំពីរនេះ។ អ៊ីចឹងខ្ញុំសួរឱ្យជាក់លាក់ថាតើលោកមានរបាយការណ៍គួរឱ្យជឿទុកចិត្តបំផុតពីសាក្សីផ្ទាល់ភ្នែកណាទេ អំពីការកាប់សម្លាប់ទាំងនេះ?

**ឆះ** មួយឆ្នាំក្រោយៗមកខ្ញុំឃើញសេចក្តីថ្លែងការណ៍របស់មេដឹកនាំខ្មែរក្រហមទទួលស្គាល់ថាពួកគេបានសម្លាប់ ឡុង បូរ៉េត និងអ្នកដទៃទៀត ព្រមទាំងទ្រង់ សិរីមតៈ។ ខ្ញុំក៏បានទទួលយកថានេះគឺជាការពិត ហើយដោយសារតែសម្តីនេះចេញអំពីការិយាល័យធិបតេយ្យរបស់ខ្មែរក្រហមខ្លួនឯង។ ខ្ញុំចង់ដឹង។

[០៨:៤៧:៤៥]

**សះ** ពាក្យចចាមអារ៉ាមពីមន្ត្រីរបស់រដ្ឋាភិបាល លន់ នល់ មន្ត្រីជាន់ទាបនោះយ៉ាងម៉េចដែរ?

**ឆះ** នៅពេលខ្ញុំត្រឡប់មកប្រទេសកម្ពុជាប៉ុន្មានឆ្នាំក្រោយមក ខ្ញុំបានជួបក្រុមគ្រួសារប្រជាជនដែលខ្ញុំបានស្គាល់ ដែលបានធ្លាប់ធ្វើការជាមួយខ្ញុំគឺអ្នកបើកឡានឱ្យខ្ញុំ។ ហើយប្រពន្ធរបស់គាត់បានថាតើគាត់ គេត្រូវបានយកទៅសម្លាប់ដោយរបៀបណានៅកន្លែងដែលគាត់ធ្វើការហើយ។ ហើយគាត់មិនដែលបានប្រាប់ថាហេតុអ្វីបានគេសម្លាប់មនុស្សយ៉ាងដូច្នេះទេ។ មានរឿងរ៉ាវយ៉ាងដូច្នេះ។ បាទ មនុស្សបានប្រាប់ខ្ញុំយ៉ាងដូច្នេះ។

**សះ** នេះគឺជារឿងរ៉ាវដែលលោក ទើបតែឮក្រោយមកទេ។ លោកមិនបានស្តាប់ឮពីសាក្សីផ្ទាល់

ផ្នែកអំពីការសម្លាប់ប្រជាជនមួយថ្ងៃក្រោយ ១៧ មេសា ទេ?

**ឆ៖** អត់ទេ វាមានលក្ខណៈស្មុគស្មាញ។ នៅជំរំជនភៀសខ្លួនគឺថាខ្ញុំបានជួប ហើយខ្ញុំអាចទៅប្រមូលព័ត៌មានទាំងនេះបាន។

**ស៖** តាមខ្ញុំយល់កំណត់ត្រាប្រចាំថ្ងៃរបស់លោកនោះគឺប្រជាជនបានមកស្ថានទូតទីក្រុងភ្នំពេញមួយថ្ងៃក្រោយ ១៧ មេសា ដោយមានរឿងរ៉ាវ រៀបរាប់រឿងរ៉ាវអំពីព្រឹត្តិការណ៍ដែលគេបានជួបប្រទះ។ អ៊ីចឹងខ្ញុំសួរថាតើលោកបានស្តាប់សាក្សីផ្ទាល់ផ្នែកអំពីការកាប់សម្លាប់ប្រជាជនមួយថ្ងៃក្រោយថ្ងៃ១៧ មេសាទេ?

[០៨:៤៩:៤០]

**ឆ៖** តើលោកសួរអំពីការសម្លាប់មេដឹកនាំរដ្ឋាភិបាល ឬក៏យ៉ាងម៉េច?

**ស៖** ខ្ញុំមិននិយាយតែចំពោះពួកមហាក្បត់ទាំងប្រាំពីរនាក់នោះទេ។ ខ្ញុំនិយាយការចោទប្រកាន់ថា មានការកាប់សម្លាប់ជាទូទៅទៅលើទាហានលន់នល់ ឬក៏មន្ត្រីរដ្ឋាភិបាល លន់ នល់។

**ឆ៖** ខ្ញុំមិនចាំមានអ្នកណាប្រាប់ខ្ញុំបែបនេះទេ មានប្រជាជនខ្លះប្រាប់ខ្ញុំ តើពួកគាត់ត្រូវបានគេបង្ខំឱ្យចាកចេញពីផ្ទះសម្បែង ដើម្បីចូលរួមរស់ជាមួយប្រជាជនដទៃទៀត គឺឱ្យធ្វើដំណើរឆ្ពោយទៅកាន់ទីជនបទ។ អ៊ីចឹងគឺចម្លើយរបស់ខ្ញុំអត់ទេ។

**ស៖** បាទ ប្រធានបទមួយទៀត។ នៅពេលដែលលោកនៅស្ថានទូតបារាំង លោកបានទទួលរបាយការណ៍ប្រហែលជាខាងមន្ត្រីរបស់អង្គការសហប្រជាជាតិ ឬអង្គការក្រៅរដ្ឋាភិបាលអំពីរបៀបដែលជនភៀសខ្លួនរស់នៅក្នុងទីក្រុងភ្នំពេញនោះ បានចាកចេញពីទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ឬថ្ងៃបន្ទាប់មក?

**ឆ៖** អង្គការមិនមែនរដ្ឋាភិបាល និងអ្នកដែលធ្វើការនៅក្នុងស្ថានទូតនេះ មិនដឹងអ្វីច្រើនជាងខ្ញុំ គេឃើញអ្វីដែលខ្ញុំឃើញអ៊ីចឹង។ ហើយក្រោយមកគេក៏បញ្ជូនខ្លួនទៅក្រៅប្រទេសកម្ពុជាទៅហ្នឹង ខ្ញុំដឹងតែប៉ុណ្ណឹង។

[០៨:៥១:៤៦]

**ស៖** បាទ ខ្ញុំសុំសួរអំពីស្ថានភាពជនភៀសខ្លួន ដែលរស់នៅរហូតដល់ ១៧ មេសា ៧៥។ ខ្ញុំសូមឱ្យលោកពិនិត្យមើលទំព័រ៥ នៃកំណត់ត្រាប្រចាំថ្ងៃរបស់លោកចុះថ្ងៃទី៧ មករា ៧៥, ERN00898213 នៅកថាខណ្ឌទី១ នេះគឺលោកសរសេរដូចតទៅ៖ “មន្ត្រីស្ថានទូតបានស្មានថាប្រជាជន ៤០.០០០ ទៅ

៥០.០០០ គឺបានជួបប្រទះដោយការបាញ់ផ្លោងនេះ។ មានការយល់ស្របរួចទៅហើយ ថាប្រជាជនពាក់កណ្តាលនៃប្រជាជនចំនួន ៧លាននាក់គឺបានជួបប្រទះ ប្រឈមមុខនឹងការសង្គ្រាមគឺថា ក្នុងរយៈពេល ៥ឆ្នាំគឺថាប្រជាជនជិត១លាននាក់ត្រូវបានសម្លាប់ ឬរងរបួស។ ហើយប្រជាជន១០.០០០ -- មានស្ត្រីមេម៉ាយ ១០.០០០នាក់ និងកុមារកំព្រា ១០.០០០នាក់ ហើយក្រោយពី៥ឆ្នាំ ជាពិសេសក្មេងៗ ហើយនិងកុមារដែលខ្វះអាហាររូបត្ថម្ភនោះគឺកំពុងតែស្លាប់ជាប្រចាំថ្ងៃ”។ លោក ស្ពេនប៊ឹក តើលោកអាចពន្យល់លម្អិតអំពីតួលេខនេះបានបន្តិចទេ តើលោកបានប្រភពពីចំនួននេះមកពីណា នៅពេលដែលលោកសរសេរក្នុងកំណត់ត្រានៅថ្ងៃថា ០៧ មករា ៧៥ ហ្នឹង?

[០៨:៥៣:១៩]

**ឆ៖** ប្រភពដែលខ្ញុំសរសេរគឺ តួលេខទី១នេះបានមកពីមន្ត្រីស្ថានទូត មន្ត្រីស្ថានទូតមកពីបណ្តាប្រទេសមួយចំនួន។ ហើយបញ្ហាផ្សេងទៀតដែលខ្ញុំបានឃើញដោយផ្ទាល់ភ្នែក ខ្ញុំឃើញកុមារកំព្រាដែលខ្វះអាហារូបត្ថម្ភ ខ្ញុំបានឃើញផ្ទាល់ភ្នែក ពួកគេបានស្លាប់នៅពេលដែលពួកគេត្រូវបានខាងអង្គការខាងរដ្ឋាភិបាលជួយព្យាបាលនោះ។ មរណភាពរបស់កុមារដែលខ្ញុំបានឃើញនៅក្នុងប្រទេសកម្ពុជានាពេលនោះ គឺខ្ញុំបានឃើញដោយផ្ទាល់ភ្នែកតែម្តង។

**ស៖** បាទ ខ្ញុំយល់អំពីការបរិច្ឆេទដែលចុះនៅក្នុងកំណត់ត្រានេះ ប៉ុន្តែផ្នែកទី២ នៃកថាខណ្ឌនេះ ឃ្លាទី២ នេះលោកសរសេរថា៖ “មានការយល់ស្របជាទូទៅរួចទៅហើយ គឺថាពាក់កណ្តាលប្រជាជនចំនួន ៧លាននាក់គឺថាប៉ះពាល់ដោយសារសង្គ្រាម”។ ដែលថាយល់ -- លោកយល់ថាម៉េចដែរចំណុចនេះ?

**ឆ៖** ខ្ញុំនិយាយថាអ្នកដែល -- ប្រជាជនដែលមានព័ត៌មានគឺអ្នកដែលធ្វើការជាមួយស្ថានទូត ឬក៏ជាមួយអង្គការរដ្ឋាភិបាលបានប្រាប់ខ្ញុំអំពីអ្វីដែលគេបានជួបប្រទះ បានឃើញ។ ពាក្យចេញពីមាត់មួយៗដែលគេបានស្តាប់ ហើយនិងគេបានឃើញ។ នេះគឺជាព័ត៌មានដែលខ្ញុំបានយ៉ាងដូច្នេះឯង។

[០៨:៥៥:១៧]

**ស៖** តើលោកនឹកឃើញ ឬក៏ចាំថាមានរបាយការណ៍ ឬក៏ព័ត៌មានណាមួយបញ្ជាក់ ឬវាប៉ាន់ប្រមាណពីចំនួនជនភៀសខ្លួនដែលរស់នៅក្នុងទីក្រុងភ្នំពេញ នៅខែមុន១៧ មេសា ៧៥ ទេ?

**ឆ៖** គឺអ្នកនោះគឺត្រូវតែទទួលមានឯកសារដើម្បីប្រាប់ថា មានប្រជាជនថ្មីៗចូលមករស់នៅក្នុងទីក្រុងភ្នំពេញ ចំនួនប្រជាជនកើនឡើងទ្វេរដងមុនសង្គ្រាម ប្រហែលជា១លានរស់នៅក្នុងទីក្រុងភ្នំពេញ

ហើយនៅពេលនោះ មានប្រហែល២លាន ឬក៏ច្រើនជាងនេះ។ ប្រជាជន២០ ទៅ៣០នាក់រស់នៅក្នុងផ្ទះមួយដែលពីដើមគេធ្លាប់រស់នៅតែប្រាំបីនាក់អីអ៊ីចឹង។

**ស៖** ពេលវេលាខ្លីខ្លី ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត។ នៅក្នុងកំណត់ត្រាចុះត្រង់ទំព័រ៧៥ គឺ ERN 00898283។ នៅពាក់កណ្តាលនៃទំព័រនេះ លោករៀបរាប់ការពិភាក្សាគ្នានៅក្នុងស្ថានទូតបរិវេណស្ថានទូតនោះ។ សូមដកស្រង់ដូចតទៅ៖ “ពួកយើងមួយចំនួនមើលខាងទ្វារខាងមុខ ឃើញប្រហែលជាពិភាក្សាអំពីមូលហេតុរបស់ពួកបះបោរដែលគេចង់បញ្ជូនប្រជាជនចេញពីទីក្រុងភ្នំពេញ។ ហើយមានការស្រាវជ្រាវរកមន្ត្រីរដ្ឋាភិបាលដែលកំពុងតែលាក់ខ្លួន ហើយអ្នកខ្លះនិយាយថាវាជាមធ្យោ-បាយមួយដើម្បីជៀសវាងអំពីការផ្គត់ផ្គង់ជនភៀសខ្លួនដែលរស់នៅ២លាននៅក្នុងទីក្រុង។ ហើយក្រោយមក គឺថាគេ អ្នកខ្លះថា -- ដើម្បីស្តីបន្ទោសទៅលើរដ្ឋាភិបាលចំពោះការស្លាប់នៅតាមផ្លូវនេះ”។ តើលោកសរសេរចំណុចនេះ នៅពេលណាជាក់លាក់?

[០៨:៥៨:០៥]

**ឆ៖** ខ្ញុំសរសេរចំណុចនេះ ដូចខ្ញុំបានជម្រាបពីម្សិលមិញ គឺក្រោយពីខ្ញុំចាកចេញពីកម្ពុជាទៅ។ ពេលនោះមានកំណត់ត្រាដែលខ្ញុំយកទៅជាមួយ បាទ កំណត់ត្រាដែលខ្ញុំសរសេរនៅក្នុងប្រទេសកម្ពុជា។ ហេតុដូច្នេះហើយ ទើបបានខ្ញុំ -- ព័ត៌មានទាំងនេះបានខ្ញុំសរសេរចូលក្នុងកំណត់ត្រានេះ។

**ស៖** លោកមានចាំទេ ការពិភាក្សាដែលលោកនិយាយជាមួយ មនុស្សដែលលោកនិយាយជាមួយ?

**ឆ៖** ខ្ញុំចាំ អ៊ីចឹងបានខ្ញុំសរសេរហ្នឹង។

**ស៖** ការជំទាស់តវ៉ាខ្លះ ជជែកតវ៉ាខ្លះដែលលោកសរសេរ តើលោកអាចជម្រាបអង្គជំនុំជម្រះដោយមធ្យោបាយមួយ តើវាស៊ីសង្វាក់គ្នាជាមួយនឹងការ ជាមួយនឹងអ្វីដែលលោកឃើញទេ?

**ឆ៖** បាទ ស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលខ្ញុំបានកត់សម្គាល់ឃើញ ប៉ុន្តែមិនមែនគ្រប់ឧប្បត្តិហេតុទាំងអស់នោះទេ។ ប៉ុន្តែខ្ញុំឆ្លើយថា ស៊ីសង្វាក់គ្នាហើយ។

**ស៖** ប្រជាជនខ្លះហាក់ដូចជាយល់ថា មានមធ្យោបាយពីការ -- គឺដើម្បីជៀសវាងកាតព្វកិច្ចផ្គត់ផ្គង់ស្បៀងអាហារទៅឲ្យប្រជាជនភៀសខ្លួន២លាននាក់ដែលខ្វះស្បៀងរួចទៅហើយនោះ។ តើការកត់សម្គាល់បែបនេះ វាស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោកឃើញដោយផ្ទាល់នោះទេ?

**ឆ៖** បាទ។

[០៨:៥៩:៤៨]

**ស៖** សូមលោកពន្យល់ពាក្យថា "បាទ" បន្តិច។ ពន្យល់ពាក្យ "បាទ" នេះឲ្យបានវែងឆ្ងាយបន្តិចបានទេ? ហើយឲ្យមូលហេតុផង?

**ឆ៖** ប្រសិនបើខ្មែរក្រហមចង់ចិញ្ចឹមប្រជាជននៅទីក្រុងភ្នំពេញនៅពេលនោះ គេត្រូវតែបើកច្រកមេគង្គ គេបានបិទច្រកមេគង្គនេះរួចមកហើយ។

**ស៖** ប៉ុន្តែចំណុចនេះ ខ្ញុំយល់ឃើញថាមិនគាំទ្រទៅដល់មូលហេតុនេះទេ ទៅដល់ទស្សនៈទេ។ តើខ្ញុំនិយាយខុសឬក៏ត្រូវ?

**ឆ៖** ទស្សនៈដែលគេគាំទ្រទៅដល់ការជម្លៀសប្រជាជន គឺថាដើម្បីបញ្ចៀសការចិញ្ចឹមប្រជាជន២លាននាក់។ អ៊ីចឹងលោកចង់និយាយថាអ៊ីចឹង?

**ស៖** យេស១ *(គ្មានការបកប្រែ)*។

**ឆ៖** ខ្ញុំថានេះជាការពន្យល់មួយមិនត្រឹមត្រូវទេ។

**ស៖** ប៉ុន្តែនេះជាគឺជា១យោបល់របស់លោកទេ។

**ឆ៖** បាទ ខ្ញុំពន្យល់ថាហេតុអ្វីបានជាពួកគេគ្រប់គ្រងទន្លេមេគង្គនុ៎ង ហើយទន្លេមេគង្គនេះវាជាប្រភពផ្គត់ផ្គង់ចម្បង។ ជាប្រភពដែលគេធ្លាប់ទទួលស្បៀងអាហារ ថ្នាំពេទ្យជាដើម។ល។

[០៩:០១:២៣]

**ស៖** បាទ ខ្ញុំសូមព្យាយាមសាកសួរតាមរបៀបនេះ តើលោកចាំទេ អ្នកណាដែលថាវាជាមធ្យោបាយមួយការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដើម្បីចៀសវាងពីកាតព្វកិច្ចចិញ្ចឹមជនភៀសខ្លួនដែលមើល ដែលមានជាង២លាននាក់ហូរចូលមកក្នុងទីក្រុង ដែលខ្វះស្បៀងអាហាររួចហើយនោះ? អ្នកណាយល់ឃើញថាដូច្នេះ?

**ឆ៖** បើតាមដែលខ្ញុំចាំនោះ គឺព័ត៌មាននេះជាព័ត៌មានមកពីខ្មែរក្រហម ហើយនិងអ្នកដែលគាំទ្រខ្មែរក្រហមថានេះនោះគឺជាហេតុផលដែលត្រូវតែឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ។ អ៊ីចឹងខ្ញុំ បើចំពោះខ្ញុំគឺថាដូចជាមិនមានន័យអីទេ មិន១ត្រូវយ៉ាងដូច្នេះទេ។ គឺមានន័យថាគេមិនត្រូវបង្ខាំងច្រកទន្លេមេគង្គ ដែលមាន ដែលត្រូវដឹកអ្វី១ទាំងអស់មកពីសាយហ្គុននោះ ដើម្បីផ្គត់ផ្គង់សម្ភារៈ បរិក្ខារទាំងអស់នេះ។

**ស៖** ពេលលោកថា ការលើកឡើងនេះគឺមកពីប្រជាជនដែលគាំទ្រខ្មែរក្រហម ឬក៏មកពីពួកខ្មែរក្រហមខ្លួនឯង។ តើលោកចង់និយាយថាប្រជាជនពីរនាក់ លោកសំដៅទៅលើប្រជាជនពីរនាក់ដែលចូល

មកស្ថានទូតនោះ គឺទំព័រ៨៩ នៃកថាខណ្ឌ -- នៃកំណត់ត្រារបស់លោកឈ្មោះ ជូ ម៉េង និង ចេង ថា ហ្នឹងមនុស្សពីរនាក់ហ្នឹង?

**ឆ៖** កថាខណ្ឌមួយណាដែលលោកកំពុងយោង?

**ស៖** ទំព័រ៨៩ កថាខណ្ឌទី២ គឺលោកនិយាយថា "មានអ្នកមកដល់ស្ថានទូតថ្មីពីរនាក់ឈ្មោះ ជូ ម៉េង និង សេង ថា"។

[០៩:០៣:៤១]

**ឆ៖** បើតាមខ្ញុំដឹងគឺគាត់ជនជាតិអូស្ត្រាលី ជាប់ខ្សែចិន។ ពួកគេទាំងពីរនេះព្យាយាមមកចូលរួមជាមួយក្រុមដែលមក ដែលនៅខាងក្នុងបរិវេណស្ថានទូតទៅហើយ។ មានការជំទាស់តវ៉ាពីរឿងបញ្ហាការខ្វះស្បៀងអាហារនៅក្នុងស្ថានទូតហ្នឹងហើយ។ អ៊ីចឹងឯង ពួកមន្ត្រីខ្មែរក្រហមបាន១ប្រាប់អ្នកទាំងពីរហ្នឹងឲ្យមកជ្រកកោននៅក្នុងស្ថានទូតនេះ។

**ស៖** តើលោកចាំអំពីការរាយការណ៍ដែលលោកបានធ្វើការ ឬក៏របាយការណ៍ដែលលោកបានធ្វើការ ឬក៏អ្វីដែលលោកបានឃើញមុនពេលពួកគេចូលមកស្ថានទូតដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំព័ត៌មានលម្អិតទេ ព្រោះពួកគេមិននិយាយលម្អិតនោះឡើយ។ ព្រោះពួកគេ -- គេនិយាយថាគេដើរបានត្រឹមតែ១០ទៅ១៥ម៉ាលប៉ុណ្ណោះ។ ហើយពួកគេក៏មិនបាននិយាយអំពីអ្វីដែលបានកើតឡើងដែរ លើកលែងតែគេប្រាប់ត្រឹមតែការជម្លៀសប៉ុណ្ណោះ។

**ស៖** តើលោកចាំថាគេនិយាយអ្វីខ្លះអំពីការជម្លៀសនោះ?

**ឆ៖** ពួកគេនិយាយ -- គេនិយាយថាការជម្លៀសហ្នឹងជារឿងត្រឹមត្រូវ ជារឿងស្របច្បាប់ ហើយគេគាំទ្រការជម្លៀសប្រជាជននេះ។

**ស៖** ពួកគេអាចនិយាយបែបនេះ ប៉ុន្តែលោកចាំថាពួកគេហ្នឹងមានបានរៀបរាប់អំពីអ្វីដែលគេបានឃើញដែរឬទេ? តើលោកចាំទេថា គេបានប្រាប់ថាឃើញអ្វីខ្លះនៅមុនពេលដែលពួកគេចូលស្ថានទូតដែរឬទេ?

[០៩:០៥:៥៧]

**ឆ៖** ពួកគេនៅខាងក្រៅប្រហែលជាពីរថ្ងៃប៉ុណ្ណោះ ប៉ុន្តែពួកគេអត់មានប្រាប់ថា គេឃើញអ្វីនោះទេ។ គេគ្រាន់តែនិយាយថាគេគាំទ្រការជម្លៀស ហើយពួកគេនិយាយថា អ្នកដែលនៅក្នុងស្ថានទូតហើយឃើញខ្មែរក្រហម ឬក៏មើលឃើញខ្មែរក្រហមថា ជាពួកកម្លាំងបំផ្លាញហ្នឹង គឺជាការខុស។ ពួក

គេគាំទ្រទៅលើអ្វីដែលខ្មែរក្រហមកំពុងតែធ្វើ។ ខ្ញុំមិនចាំថា តើគេនិយាយលម្អិតអ្វីបន្ថែមពីការឃើញរបស់គេនោះទេ។

**ស៖** តើលោកដឹងដែរឬទេថា ពួកគេនោះបានសរសេរ ឬក៏បានកត់ត្រានូវអ្វីដែលពួកគេបានឃើញនៅក្រោយថ្ងៃ ១៧ មេសា ដែរទេ?

**ឆ៖** ខ្ញុំអត់ឃើញថាពួកគេមានកត់ត្រា ឬក៏សរសេរអ្វីទុកនោះទេ។

**ស៖** កាលពីម្សិលមិញ ខ្ញុំបាននិយាយយោងទៅលើការរិះគន់ទៅលើរបាយការណ៍របស់លោក ហើយប្រភពនៃការរិះគន់ហ្នឹង គឺរិះគន់ដោយ ណោម ចមស្គី ដែលគេនិយាយថា ការរាយការណ៍របស់លោក គឺផ្អែកទៅលើរបាយការណ៍របស់បុគ្គលទាំងពីរនាក់នេះ គឺបុគ្គលដែលបានសរសេរនេះ។ តើលោកបានដឹងអំពីការពិភាក្សា ឬក៏ការនិយាយអំពីរបាយការណ៍ដែល ណោម ចមស្គី គាត់និយាយពាក់ព័ន្ធនោះដែរឬទេ គឺរបាយាករណ៍ដែល ណោម ចមស្គី និយាយពីបុគ្គលទាំងពីរនេះ?

**ឆ៖** ខ្ញុំអត់ដឹងទេ។ ខ្ញុំអត់ដែលឮទេ។ ខ្ញុំមិនដែលឃើញទេ។

[០៩:០៧:៥៨]

**ស៖** ឥឡូវនេះខ្ញុំលើកជាឧទាហរណ៍ គេនិយាយថា -- ខ្ញុំនិយាយជាពិសេសផ្នែកលួចប្លន់ ពួកគេនិយាយថា “គេមិនដែលឃើញអំពីការលួចប្លន់ជាក្រុម ឬក៏ការលួចប្លន់ណាមួយនោះទេ”។ តើលោកបាននិយាយជាមួយពួកគាត់អំពីការលួចឆក់ប្លន់នៅក្នុងទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** អត់ទេ។ ខ្ញុំអត់ដែលទេ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! បាទ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំមិនមែនងើបឡើងដើម្បីជំទាស់ទេ ប៉ុន្តែខ្ញុំសូមឱ្យសហមេធាវីការពារក្ដីផ្ដល់នូវប្រភពនៃព័ត៌មានថាតើគាត់អាន អត្ថបទដែលគាត់អានអំមិញហ្នឹងអានពីកន្លែងណា? វាមានប្រភពអ្វីខ្លះ?

[០៩:០៨:៥៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចផ្តល់ប្រភពបាន គឺខ្ញុំនិយាយទៅលើឯកសារ D39943 (*ស៊ីក*) គឺឯកសារដែលមានលេខ S0000457 (*ស៊ីក*), គឺឯកសារ D3/9942 គឺឯកសារដែលមានលេខ S0004544594 (*ស៊ីក*)។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ស្តេនប៊ឺក ខ្ញុំមិនបានទទួលចម្លើយ។ ថាតើលោកមិនបាននិយាយ មិនបានចាំថាបាននិយាយជាមួយពួកគេអំពីការលួចប្លន់ ឬក៏អំពីរបាយការណ៍ដែលគេបានឃើញនៅក្នុងភ្នំពេញនោះ?

**លោក ស៊ីដនី ស្តេនប៊ឺក៖**

**ឆ៖** ខ្ញុំបានជជែកជាមួយពួកគេខ្លះដែរ ហើយពួកគេនិយាយថា អ្វីដែលយើងឃើញគឺមិនពិតនោះទេ។ នៅត្រង់ចំណុចមួយនោះ គាត់ហើយនិងសង្សារបស់គាត់ ដោយសារតែយើងមិនយល់ស្របជាមួយពួកគាត់ទាំងពីរ ហើយយើងនៅតែប្រឆាំងជាមួយគាត់ គាត់ថាគាត់នឹងរាយការណ៍។ ពួកគាត់គំរាមថាគាត់នឹងរាយការណ៍ទៅមេដឹកនាំខ្មែរក្រហមដោយសារតែយើងមិនគាំទ្រគាត់។ហើយហេតុផលដោយសារតែជជែកជាមួយគាត់តែយើងទទួលបានលទ្ធផលជាអវិជ្ជមាន។ ដោយសារតែមិនមានការឯកភាពគ្នាខ្ញុំក៏លូកមាត់ចូលទៅ។ អានេះគឺជាបញ្ហា។ ហើយនៅពេលយើងងើបឡើងពេលព្រឹក គឺយើងមានតែបាយហូប ដូច្នេះគឺយើងហូបដូចអ្នកដទៃហូបអ៊ីចឹងដែរ។ អានេះគឺជាអ្វីដែលខ្ញុំ ចាំជាពិសេសគឺនៅពេលនោះស្ត្រីម្នាក់នោះនិយាយថា “យើងជាអ្នករាយការណ៍” គាត់ថា “យើងនឹងរាយការណ៍” ហើយយើងប្រាប់គាត់ថា ចង់រាយការណ៍រាយទៅតាមចិត្ត។

[០៩:១១:១២]

**ស៖** របាយការណ៍ដែលខ្ញុំនិយាយយោងហ្នឹងគឺរបាយការណ៍ដែលពួកគាត់និយាយថាភាគច្រើនយើងចំណាយពេលនៅក្នុងស្ថានទូតហ្នឹងគឺដើម្បីជជែកអំពីការភ័យខ្លាចក៏ដូចជាការគម្រាមកំហែងនានា ដូច្នេះគឺគេនិយាយមិនមែនសំដៅតែទៅលើ ចនស្វេន ទេ ពួកគេនិយាយសំដៅទៅលើលោកផងដែរ។ ហើយពួកគេបាននិយាយអំពីការដែលពួកគេបានជួបជជែកជាមួយលោកដែរ តើហេតុអ្វី?

**ឆ៖** ព្រោះថាពួកគេទាំងពីរនាក់នោះគាំទ្រពួកខ្មែរក្រហម គឺគាំទ្រហេតុការណ៍នានាដែលជាហេតុការណ៍ដ៏អាក្រក់។ ជាហេតុការណ៍ដែលបណ្តាលឲ្យមានការបាត់បង់ជីវិតមនុស្សយ៉ាងច្រើន។ ខ្ញុំចំណាយពេលជាច្រើនម៉ោងនៅតាមមន្ទីរពេទ្យនៅជាមួយនឹងជនរងគ្រោះនៅពេលដែលគេនាំយកជនរងគ្រោះមកមន្ទីរពេទ្យ។ ហើយខ្ញុំឃើញទាំងមនុស្សពេញវ័យក៏ដូចជាក្មេងៗដែលដាច់ដៃដាច់ជើង ហើយ

ខ្ញុំបានជជែកជាមួយពួកអ្នកជនរងគ្រោះទាំងអស់នោះ។ គឺពួកគេជាជនរងគ្រោះនេះពួកខ្មែរក្រហម គឺការវាយប្រហាររបស់ពួកខ្មែរក្រហម។ ហើយយើងឃើញសាកសពគេដាក់គរជើងលើគ្នា។ ហើយកម្រាលឥដ្ឋ កម្រាលជញ្ជាំងគឺប្រលាក់ទៅដោយឈាម ហើយវេជ្ជបណ្ឌិតគឺអស់តាំងពីស្រោមដៃដើម្បីវះកាត់។ សូម្បីតែអាកុលសម្រាប់សម្អាតហ្នឹងក៏គ្មានដែរ។ ហើយនៅក្រៅបន្ទប់វះកាត់ហ្នឹង គឺយើងឃើញប្រអប់កាតុងដែលគេសម្រាប់ដាក់ដៃជើងដែលដាច់ពីមនុស្សហ្នឹង គេដាក់ចូលទៅក្នុងប្រអប់ហ្នឹង។ វាមើលទៅដូចជារឿងមួយដ៏អាក្រក់ជាទីបំផុត។

[០៩:១៣:២៧]

**ស៖** អរគុណច្រើនលោក។ ខ្ញុំមិនដែលចូលរួមក្នុងសង្គ្រាមទេ ដូចដែលលោកបញ្ជាក់អ៊ីចឹង។ ប៉ុន្តែអ្វីដែលលោកប្រាប់ខ្ញុំនៅពេលនេះគឺវាហាក់ដូចជាបង្ហាញថាពួកគាត់ជាជនរងគ្រោះនៃសង្គ្រាម។ ប្រហែលជាវាមិនខុសប្លែកពីហេតុការណ៍ដែលកើតឡើងនៅពេលគឺនៅប្រទេសស៊ីរីជាដើម គឺវាមិនខុសគ្នាទេមើលទៅ ខ្ញុំគិតអ៊ីចឹង។ ដូច្នេះហើយគឺថា លោកបាននិយាយអំពី គឺរបាយការណ៍នោះបាននិយាយអំពីអារម្មណ៍អវិជ្ជមានដែលបុគ្គលទាំងពីរនាក់នេះមានចំពោះលោកនៅក្នុងស្ថានទូតបារាំង។ តើអ៊ីចឹងមែនទេ?

**ឆ៖** អានេះប្រហែលជាអ្វីដែលលោកជឿ។ ប៉ុន្តែខ្ញុំលើកអ៊ីចេះវិញ។ លោកមិនចាំបាច់ទៅកន្លែងដែលមានសង្គ្រាមទេ លោកនៅស្រុកខ្មែរហ្នឹងជួបតែប្រជាជនដែលធ្លាប់ទទួលរងគ្រោះហ្នឹងទៅដឹងហើយ ប៉ុន្តែអាហ្នឹងវាអាស្រ័យលើលោកដែរ។ គឺថា ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំគាំទ្រអ្វីដែលខ្ញុំបានឃើញ។ ខ្ញុំជឿទៅលើអ្វីដែលខ្ញុំបានឃើញ។

[០៩:១៤:៥៤]

**ស៖** ចំណុចមួយទៀត គឺប្រពន្ធរបស់ សេន ថា បានសរសេរថា៖ “វាច្បាស់លាស់ណាស់ថាយើងអត់មានអ្វី ដែលនិយាយអំពីការជម្លៀស ក៏ដូចជាការសម្លាប់ គឺថាពួកអ្នកសារព័ត៌មានទាំងអស់ហ្នឹងគាត់មិនពេញចិត្តជាមួយអ្វីដែលយើងនិយាយ”។ តើលោកចង់ផ្តល់មតិយោបល់អ្វីដែរ ទៅលើអ្វីដែលគេសរសេរ?

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអភ័យទោសលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនចាំថាមានការជជែកគ្នាបែបនេះទេ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត។ ខ្ញុំចង់និយាយអំពីលំដាប់លំដោយ -- ខ្ញុំចង់និយាយអំពីលំដាប់លំដោយដែលសហតំណាងមេធាវីការពារក្ដីនិយាយ គឺគាត់បាននិយាយអំពីកំណត់ត្រារបស់ ណោម ចមស្ដី នៅទំព័រទី១ ប៉ុន្តែបន្ទាប់មកទៀត ថាតើយ៉ាងម៉េចដែរ? ព្រោះខ្ញុំមិនដឹងថាតើឯកសារហ្នឹងគេបោះពុម្ពជាផ្លូវការ ឬក៏អត់នោះទេ។ ដូច្នេះខ្ញុំចង់ឲ្យគាត់បង្ហាញឲ្យបានច្បាស់ ចង់ឲ្យមេធាវីការពារក្ដីបង្ហាញឲ្យបានច្បាស់ ថាតើឯកសារហ្នឹងវាមានលក្ខណៈបែបណា បន្ទាប់មកបញ្ជាក់ថាតើគាត់អានពីទំព័រណា ឬក៏អានពីចំណុចណាមួយ? ដូច្នេះ ខ្ញុំសង្ឃឹមថាគាត់នឹងឲ្យមានភាពច្បាស់លាស់ ដូច្នេះក្នុងពេលកន្លងមកនេះគាត់ធ្វើហាក់ដូចជាមានភាពរញ៉េរញ៉ៃខ្លាំងណាស់។

[០៩:១៦:២០]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ស្របអ្វីដែលព្រះរាជអាជ្ញានិយាយ ប៉ុន្តែខ្ញុំ -- ឥឡូវនេះខ្ញុំប្រើលើសម៉ោងខ្ញុំទៅហើយ ហើយមេធាវី ខៀវ សំផន គាត់កំពុងចាំសួរសំណួរដែរ ដូច្នេះខ្ញុំគិតថាប្រហែលជាខ្ញុំត្រូវបញ្ចប់ ក៏ត្រូវបញ្ចប់ការសួររបស់ខ្ញុំនេះហើយមើលទៅ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

[០៩:១៧:០១]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ តើមេធាវីអាចផ្ដល់ព័ត៌មានបានដែរទេនៅពេលនេះ ជាជាងរង់ចាំដល់ពេលក្រោយ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនិយាយអំពីឯកសារដែលមានលេខ ERN គឺមានលេខ គឺឯកសារដែលមានលេខ S0045593 គឺទំព័រ៨៣ នៅក្នុងកំណត់ត្រានោះ។ គឺកំណត់ត្រារបស់ ណោម ចមស្ដី គឺទំព័រទី៨៣។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមលោកផ្តល់ព័ត៌មានអំពីទាក់ទងឯកសារ D ព្រោះខ្ញុំដូចជាមិនច្បាស់អំពីលេខ ERN ដែលចាប់ផ្តើមដោយ S នោះ។

**លោក ស៊ីដនី ស្តេនប៊ីក៖**

--

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

*យេស១ មីស្ទ័រ* ស្តេនប៊ីក។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឯកសារដែលមានលេខ S00045507។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ចុះចម្លើយ -- ចុះឯកសារ D?

**លោក វ៉ិចទ័រ កូប៉េ៖**

D4942។

[០៩:១៨:២២]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជួយ ប្រសិនបើខ្ញុំអាចជួយបាន។ ឯកសារដែលផ្តល់ហ្នឹងគឺជាឯកសាររបស់មជ្ឈមណ្ឌល ឌី.ស៊ី.ខេម ប្រហែលជាមិនមានលក្ខណៈច្បាស់លាស់ ប៉ុន្តែនេះគឺជាឯកសាររបស់ខាងមជ្ឈមណ្ឌលឯកសារកម្ពុជា។ គឺវាមាននៅក្នុងកន្លែងផ្ទុកឯកសាររួម គឺឯកសារនៅកន្លែងផ្ទុកឯកសាររួមលោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី ស្តេនប៊ីក។ សូមអញ្ជើញ!

[០៩:១៨:០៦]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក ស៊ីដនី ស្កេនប៊ឺក។ ខ្ញុំ – គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន ហើយតទៅនេះខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោក។ ជាដំបូងខ្ញុំចង់សួរបញ្ជាក់ថាតើរយៈពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ ដែលលោកបានឆ្លើយថាលោកបានមកធ្វើការនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ ១៩៧០ រហូតដល់ ៧៥នោះ មានរយៈពេលដែលលោកស្នាក់នៅពិតប្រាកដនៅក្នុងទឹកដីកម្ពុជារយៈពេលប៉ុន្មានដែរ ?

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** តាមពិតទៅ ការធ្វើដំណើររបស់ខ្ញុំហ្នឹង គឺវាមានរយៈពេលខុសគ្នាៗ។ ប៉ុន្តែការមកទស្សនកិច្ចរបស់ខ្ញុំ មិនដែលក្រោម២ខែនោះទេ។

**ស៖** លោកអាចសរុបជារួមបានទេ ថារយៈពេលទាំងអស់ប៉ុន្មានខែ ដែលលោកស្នាក់នៅក្នុងកម្ពុជាក្នុងរយៈពេល៥ឆ្នាំ ក្នុងសម័យសង្គ្រាមនៅក្នុងប្រទេសកម្ពុជា?

**ឆ៖** គឺថាខ្ញុំអាចប៉ាន់ស្មានបាន គឺប្រហែលជា២ឆ្នាំ ឬក៏លើសខ្វះតិចតួច។ ប្រហែលជា២ឆ្នាំ ៣ខែ ឬក៏ប្រហែលៗប៉ុណ្ណឹងឯង។

[០៩:២០:៥៣]

**ស៖** បាទ សូមអរគុណ។ ចុះក្រៅពីពេលវេលាដែលលោកនៅក្នុងប្រទេសកម្ពុជានៅពេលដែលលោកនៅខាងក្រៅប្រទេសកម្ពុជា តើលោកមានធ្វើសេចក្តីរាយការណ៍អំពីព្រឹត្តិការណ៍នានាដែលកើតនៅក្នុងប្រទេសកម្ពុជាដែរទេ?

**ឆ៖** សូមលោកសួរសំណួរមួយសាទៀត ខ្ញុំស្តាប់ដូចជាមិនច្បាស់លាស់សោះ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរថា ក្រៅពីពេលវេលាដែលលោកនៅក្នុងប្រទេសកម្ពុជានៅពេលនោះ តើលោកមានបានធ្វើសេចក្តីរាយការណ៍អំពីប្រទេសកម្ពុជា ឬក៏យកព័ត៌មានអំពីប្រទេសកម្ពុជានៅក្រៅទឹកដីនៃប្រទេសកម្ពុជានាពេលនោះដែរទេ?

**ឆ៖** ខ្ញុំប្រហែលជាអាច ប៉ុន្តែវាគ្រាន់តែកំណត់ត្រា ឬក៏សៀវភៅដែលខ្ញុំកត់ត្រា ដែលខ្ញុំរៀបចំឡើងនៅពេលដែលខ្ញុំនៅទីនោះ។ ដូច្នេះនៅពេលដែលខ្ញុំចាកចេញពីប្រទេសកម្ពុជា បន្ទាប់ពីខ្ញុំនៅ២ខែ ខ្ញុំត្រឡប់ទៅប្រទេសឥណ្ឌាវិញ គឺនៅពេលនោះ មូលដ្ឋានរបស់ខ្ញុំនៅប្រទេសឥណ្ឌា ប្រហែលជា១ថ្ងៃ ២ថ្ងៃក្រោយមក ខ្ញុំអាចធ្វើការរៀបចំ ប៉ុន្តែខ្ញុំមិនប្រាកដ ខ្ញុំមិនច្បាស់ថា ខ្ញុំបានសរសេររឿងរ៉ាវបែបនោះ

ទេ ប៉ុន្តែខ្ញុំនិយាយ ឬក៏ខ្ញុំអាចធ្វើការរៀបរាប់អំពីថ្ងៃចុងក្រោយរបស់ខ្ញុំនៅប្រទេសកម្ពុជានោះ។

[០៩:២១:១៨]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការយកព័ត៌មាននៅក្នុងទឹកដីកម្ពុជា ក្នុងចន្លោះឆ្នាំ ១៩៧០ដល់៧៥ តើលោកមានបានចូលយកព័ត៌មាននៅក្នុងទីសមរភូមិនៅលើទឹកដីកម្ពុជាណាខ្លះដែរទេ?

**ឆ៖** បាទ។

**ស៖** លោកអាចរៀបរាប់ទីតាំងសមរភូមិនោះបានទេ?

**ឆ៖** គឺមានរឿងរ៉ាវជាច្រើនដែលខ្ញុំបានសរសេរ គឺរឿងរ៉ាវដែលខ្ញុំបានឃើញផ្ទាល់ភ្នែក។ ខ្ញុំទៅកន្លែងទាំងអស់នោះ ព្រោះថាមានរបាយការណ៍ពីការវាយប្រយុទ្ធគ្នា ហើយខ្ញុំទៅទីនោះ ហើយខ្ញុំបានឃើញ គឺថាខ្ញុំមិនអាចទូទៅទាំងប្រទេសបានទេ។ កន្លែងមួយចំនួនត្រូវបានគេរាំងខ្ទប់ ដោយសារខ្មែរក្រហមគ្រប់គ្រង។

**ស៖** លោក ស្កេនប៊ឺក ខ្ញុំសូមកាត់លោក ដោយសារលោកឆ្លើយអត់ត្រូវនឹងសំណួររបស់ខ្ញុំ។ ខ្ញុំចង់សួរថា តើទីតាំងសមរភូមិ ទីតាំងជាក់លាក់នៃសមរភូមិដែលលោកបានទៅយកព័ត៌មាននោះជាទីតាំងនៅកន្លែងណាខ្លះ? ទី១ លោកអាចបញ្ជាក់ពីឈ្មោះទីតាំងសិនមក ហើយក្រោយមកខ្ញុំនឹងសួរអំពីស្ថានភាពនៅជុំវិញសមរភូមិដែលលោកបានឃើញ?

[០៩:២៤:៥១]

**ឆ៖** ខ្ញុំមិនអាចផ្តល់កាលបរិច្ឆេទឲ្យច្បាស់លាស់ទេ ប៉ុន្តែខ្ញុំមិនចាំឲ្យច្បាស់លាស់នោះទេ។ ប៉ុន្តែប្រសិនបើលោកបានអាននូវរឿងរ៉ាវទាំងអស់ ដែលខ្ញុំបានសរសេរ នៅក្នុងរបាយការណ៍ ឬក្នុងព័ត៌មានញូវយ៉ក គឺថាទីកន្លែងដែលខ្ញុំបានទៅពិនិត្យហ្នឹង លោកនឹងអាចមើលឃើញអំពីឈ្មោះកន្លែងទាំងអស់ដែលខ្ញុំបានទៅនោះ។ គឺថាមិនមានអ្វីជាអាថ៌កំបាំងដែលខ្ញុំត្រូវលាក់លៀមនោះឡើយ។ លោកអាច*សឺច*តាមហ្គូហ្គលរកឈ្មោះខ្ញុំបាន ហើយបន្ទាប់មកលោកអាចរកឃើញ។

**ស៖** អ៊ីចឹងខ្ញុំសូមឲ្យលោកមេត្តាឆ្លើយនៅចំពោះមុខអង្គសវនាការនៅពេលនេះ នូវអ្វីដែលលោកអាចចាំបាន ឬក៏លោកឃើញជាក់ស្តែងនៅពេលនោះ។ តែបើសិនជាលោកមិនបានចាំទេ ក៏មិនថ្វីដែរ លោកអាចឆ្លើយបញ្ជាក់ថាលោកមិនបានចាំអ៊ីចឹងទៅ។ ឥឡូវសូមលោកបញ្ជាក់សាឡើងវិញថា តាមអ្វីដែលខ្ញុំស្តាប់បាន គឺលោកមិនបានចាំអំពីទីតាំង ឬក៏កាលបរិច្ឆេទជាក់លាក់ណាមួយចំពោះការចូលយកព័ត៌មាននៅទីសមរភូមិទេ។ តើអ៊ីចឹងត្រឹមត្រូវទេ?

[០៩:២៦:១២]

**ឆ៖** បាទ គឺត្រឹមត្រូវហើយ។ ខ្ញុំសរសេរអត្ថបទជារៀងរាល់ថ្ងៃ ឬក៏ពីរបីថ្ងៃម្តង។ ហើយព័ត៌មានគឺនៅក្នុងអត្ថបទទាំងអស់នោះ។ ខ្ញុំមិនចង់ចាប់ផ្តើម ហើយនិយាយថាវានៅកន្លែងនេះ ឬក៏ឈ្មោះនៅខេត្តនោះ។ ខ្ញុំចង់ផ្តល់ចម្លើយដែលជាការទាយស្មាននោះទេ។ ខ្ញុំគ្រាន់តែផ្តល់យោបល់ថាលោកអាចរកឃើញថាបាន ហើយខ្ញុំប្រាកដថា លោកអាចរកឃើញបាន ហើយលោកមិនមានការលំបាកទេ ប្រសិនបើលោករកឃើញ រកតាមហ្គូហ្គលនោះ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមបន្តសំណួរទាក់ទងទៅនឹងការចូលទៅយកព័ត៌មានរបស់លោក លោកចូលតាមរយៈខាងកងកម្លាំងរបស់ខ្មែរសាធារណៈ។ -- រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ តើអ៊ីចឹងត្រឹមត្រូវទេ តាមអ្វីដែលលោកបានបញ្ជាក់ខាងមុនថា នៅលើទឹកដីមួយចំនួនដែលគ្រប់គ្រងដោយពួកខ្មែរក្រហមនោះ លោកអត់បានចូលទៅដល់ទេ?

**ឆ៖** ខ្ញុំមិនដែលទៅសមរភូមិដោយទៅជាមួយទាហានរដ្ឋាភិបាល ឬមន្ត្រីរដ្ឋាភិបាលនោះឡើយ។ ខ្ញុំធ្វើការរាយការណ៍ពីអ្នកដែលភៀសខ្លួន ដែលថាៗតើមានការប្រយុទ្ធអ្វីនៅកន្លែងណា? ហើយយើងទៅទីនោះដើម្បីទទួលព័ត៌មាន ហើយនិងទៅមើលអំពីហេតុការណ៍ពិតប្រាកដនៅទីនោះ។

[០៩:២៨:០៨]

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងទៅនឹងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក លោកមានដែលបានយកព័ត៌មានពីគ្រោះថ្នាក់ និងការបាត់បង់ការខ្ទេចខ្ទី ដោយសារការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅពេលសង្គ្រាមនៅកម្ពុជានោះដែរទេ?

**ឆ៖** បាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមឱ្យលោកបញ្ជាក់អំពីអត្ថបទរបស់លោក ដែលលោកសរសេរអំពី "ខេមបូឌា ដាយរី ១៩៧៥" ក្នុងសៀវភៅរបស់លោកក្នុងទំព័រទី៥។ នៅក្នុងដើម -- នៅថ្ងៃ០៧ មករា លោកបានបញ្ជាក់អំពីចំនួនអ្នកស្លាប់ និងរបួសមានប្រហែល១លាននាក់។ ខ្ញុំចង់ឱ្យលោកបញ្ជាក់ថាតើតួរលេខនេះលោកបានមកពីណា?

**ឆ៖** តួលេខទាំងអស់នេះ គឺខ្ញុំទទួលបានពីរបាយការណ៍ជាច្រើនតាមរយៈការជជែកជាមួយនឹងមន្ត្រីទូត ទាហាននៅតាមស្ថានទូត ឬក៏ពួកទាហាន អ្នកដែលគេបានធ្វើដំណើរត្រួតពិនិត្យមើលតាមផ្លូវអាកាសដែលធ្វើការត្រួតពិនិត្យទៅលើព័ត៌មានទាំងអស់នេះ។ គឺខ្ញុំទទួលបានព័ត៌មានពីប្រភពទាំងអស់នេះ។

[០៩:៣០:០៧]

**សៈ** បាទ សូមអរគុណ។ តើលោកមានឃើញជាតារាង ឬក៏ជាស្ថិតិនៃរបៀបនៃការវាយតម្លៃ ដើម្បីបញ្ជាក់អំពីចំនួនសរុបនៃអ្នកស្លាប់ និងអ្នករបួសនាពេលនោះដែរទេ?

**ផៈ** អត់ទេ។ ខ្ញុំសូមទោស ខ្ញុំមិនដែលឃើញបញ្ជី ឬក៏មិនដែលមានបញ្ជីបែបនេះទេ។

**សៈ** ចុះទាក់ទងទៅនឹងប្រភពដែលលោកបានរៀបរាប់អម្បាញ់មិញនេះ វាអាចជឿបានប៉ុនណា ដែរសម្រាប់លោកជាអ្នកយកព័ត៌មាននៅពេលនោះនុះ?

**ផៈ** ខ្ញុំមិនដែលប្រើប្រាស់ព័ត៌មានដែលប្រាប់ខ្ញុំ ដោយនិយាយកុហក ឬក៏និយាយបំផ្លើសឡើយ ដូច្នេះខ្ញុំជឿជាក់ថា ការប៉ាន់ស្មានរបស់ខ្ញុំ គឺប្រហាក់ប្រហែលទៅនឹងចំនួនពិតប្រាកដ។

**សៈ** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកអំពីទំនាក់ទំនងរវាងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ និងរដ្ឋាភិបាលសហរដ្ឋអាមេរិក។ ខ្ញុំចង់សួរថា តើលោកបានធ្វើសេចក្ដីរាយការណ៍ ឬក៏យកព័ត៌មានអំពីទំនាក់ទំនងរដ្ឋាភិបាលសហរដ្ឋអាមេរិកជាមួយនិងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរញឹកញាប់ប៉ុនណាដែរនៅក្នុងរបបកម្ពុជា -- នៅក្នុងរបបពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ នោះ?

[០៩:៣២:១៩]

**ផៈ** ខ្ញុំសរសេររបាយការណ៍ជាច្រើនអំពីទំនាក់ទំនងរវាងស្ថានទូតអាមេរិកជាមួយនឹងកម្ពុជា ដែលបានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយខ្ញុំរាយការណ៍អំពីការទម្លាក់គ្រាប់បែករបស់អាមេរិក។ ដូច្នេះ ខ្ញុំគិតថាលោកនឹងអាចរកឃើញប្រសិនបើលោកស្វែងរកតាមរយៈឈ្មោះខ្ញុំ ហើយនិងសារព័ត៌មានញូវយ៉កថាមស៍ លោកនឹងរកឃើញអត្ថបទទាំងអស់នោះ។

តាមពិតទៅ គឺនៅពេលដែលមានការទម្លាក់គ្រាប់បែក គឺការទម្លាក់គ្រាប់បែកហ្នឹងមិនឆ្ងាយប៉ុន្មានពីទីក្រុងភ្នំពេញទេ។ យើងអាចមើលឃើញការទម្លាក់គ្រាប់បែកហ្នឹងពីលើដំបូលផ្ទះនៅក្នុងទីក្រុងភ្នំពេញ យើងមើលឃើញ។

**សៈ** បាទ សូមអរគុណ។ លោកបានបញ្ជាក់អំពីទំនាក់ទំនងផ្នែកយោធារវាងរដ្ឋាភិបាលសាធា-រណរដ្ឋខ្មែរ និងរដ្ឋាភិបាលសហរដ្ឋអាមេរិក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើមានទំនាក់ទំនងអ្វីផ្សេងទៀត ឧទាហរណ៍ទាក់ទងទៅនឹងផ្នែកការទូតដែលរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ត្រូវការរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីជួយទំនុកបម្រុងនោះ?

[០៩:៣៤:០៦]

**ឆ៖** ខ្ញុំគិតថា ទំនាក់ទំនង គឺពិតជាមាន ប្រាកដជាមាន ហើយមានការផ្គត់ផ្គង់សព្វាវុធ ហើយនិងសម្ភារៈផ្សេងៗ គឺផ្គត់ផ្គង់ដោយរដ្ឋាភិបាលអាមេរិក។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ តើលោកមានដែលធ្វើបទវិចារណកថាផ្នែកសារព័ត៌មានទាក់ទងទៅនឹងឯករាជ្យភាពរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ នៅក្នុងចន្លោះឆ្នាំ១៩៧០-៧៥ នោះដែរឬទេ?

[០៩:៣៥:០៦]

**ឆ៖** តើលោកអាចពន្យល់បានទេ ថាតើលោកចង់និយាយមានន័យបែបណានៅពេលដែលលោកនិយាយថាខ្មែរសាធារណរដ្ឋឯករាជ្យហើយ តើលោកចង់មានន័យបែបណាដែលប្រើប្រាស់ពាក្យ "ឯករាជ្យ" ហ្នឹង?

**ស៖** បាទ ខ្ញុំចង់បញ្ជាក់ថាតើលោកមានបានធ្វើការសរសេរអត្ថបទ ឬក៏យកព័ត៌មានទាក់ទងទៅនឹងឯករាជ្យរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរនៅក្នុងសម័យឆ្នាំ១៩៧០ ដល់ ឆ្នាំ៧៥? ឯករាជ្យដែលខ្ញុំសួរលោកនេះគឺឯករាជ្យក្នុងនាមជាប្រទេសដែលកម្ពុជាមិនមែនជាប្រទេសចំណុះនៅក្នុងប្រទេសណាមួយ។ សូមលោកជួយបញ្ជាក់?

**ឆ៖** ខ្ញុំមិនមានព័ត៌មានអាថ៌កំបាំង ឬក៏ព័ត៌មានសម្ងាត់និយាយអំពីទំនាក់ទំនងរវាងទំនាក់ទំនងអាមេរិកនិងកម្ពុជានោះទេ។ គឺវាមិនមែនជាទំនាក់ទំនងយូរអង្វែង និងយូរលង់នោះទេ។ មានតែអ្នកដែលធ្វើការសម្រេចចិត្តក្នុងការគាំទ្ររបបលន់នល់ ឬក៏រដ្ឋាភិបាលលន់នល់ប៉ុណ្ណោះ គឺថាទាល់តែលោកសួរអ្នកដែលគ្រប់គ្រងរដ្ឋាភិបាលអាមេរិកនៅសម័យនោះទើបអាចដឹងបាន។ ដូច្នេះខ្ញុំជម្រាបបានប៉ុណ្ណោះ។ ហើយលោកក៏អាចស្វែងរកឃើញផងដែរនៅក្នុងអត្ថបទរបស់ខ្ញុំ ប្រសិនបើខ្ញុំធ្លាប់សរសេរទាក់ទងអំពីចំណុចទាំងអស់នេះ។ លោកក៏អាចស្វែងរកឃើញឯកសារយោងដែលនិយាយអំពីបុគ្គលមួយចំនួននៅក្នុងស្ថានទូតដែលនិយាយអំពីសេចក្ដីសម្រេចនានា។ ប៉ុន្តែនៅចំពោះមុខខ្ញុំ ខ្ញុំអត់មានអត្ថបទ ដែលខ្ញុំបានសរសេរកន្លងមកនោះទេ។ ដូច្នេះគឺថាវាគ្មានលទ្ធផលអីទេ បើសិនឲ្យខ្ញុំព្យាយាមនឹកឃើញ ឬក៏ព្យាយាមរកនឹកអ្វីដែលបានសរសេរកន្លងរួចមកហើយនោះគឺគ្មានលទ្ធផលទេ។

[០៩:៣៧:៤៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់ឲ្យលោកពិនិត្យទៅលើអត្ថបទរបស់លោកដដែលដែលជាសំណេរប្រចាំថ្ងៃរបស់លោកឆ្នាំ១៩៧៥ នៅត្រង់ទំព័រ៥៤។ នៅក្នុងកថាខណ្ឌទី៤។

**លោក គង់សំអុន៖**

លោកប្រធានខ្ញុំ សូមអនុញ្ញាតអានជាភាសាអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ អ្នកបកប្រែភាសាមានការសម្របសម្រួលនូវ *ផេទឆែល*ក្នុងការបកប្រែភាសា។ សូមអញ្ជើញ។

**លោក គង់ សំអុន៖**

**ស** (អានជាភាសាអង់គ្លេស៖) ដកស្រង់ "អ្នកដឹកនាំកម្ពុជាល្បីមួយរូបគឺឧត្តមសេនីយ៍ស៊ីសុវត្ថិ សិរិមតៈ ដែលជាអតីតនាយករដ្ឋមន្ត្រី – ហើយត្រូវបានគេចាត់ទុកដោយជនជាតិអាមេរិកាំងថាជាសេចក្តីសង្ឃឹមតែមួយគត់ក្នុងការកែប្រែនូវអនាគតរបស់កម្ពុជា – បានបញ្ជូនទូរលេខមួយទៅប្រធានាធិបតី ហ្វត ដែលចោទប្រកាន់ ប្រធានាធិបតីពីការក្បត់គាត់។ ឧត្តមសេនីយ៍ សិរិមតៈ នៅក្នុងរបាយការណ៍នៅក្នុងសេចក្តីរាយការណ៍របស់គាត់ជាដំបូងបានរៀបរាប់អំពីការចងចាំដ៏ល្អអំពីការប្រជុំដែលគាត់បានជួបជាមួយនឹងលោក ហ្វត នៅក្នុង *វ៉ែល ក្លូវ៉ាំងូ* ។ ហើយបន្ទាប់មកបាននិយាយថា គោលនយោបាយបោះបង់ចោលប្រទេសកម្ពុជា -- ប្រទេសដ៏ក្រីក្រដោយសម្រេចចិត្តយ៉ាងកាចសាហាវដោយមិនមានការជូនដំណឹង ឬក៏មិនមានការរៀបចំ គឺធ្វើឲ្យយើងស្ថិតនៅក្នុងស្ថានភាពមួយដែលត្រូវបានគេក្បត់យ៉ាងឃោរឃៅចាប់ជាទីបំផុត។ យើងក្នុងពេល ឥឡូវនេះនឹងព្យាយាមតស៊ូដោយម្នាក់ដោយគ្មានការគាំទ្រលោក។ យើងសុខចិត្តស្លាប់នៅលើដីរបស់យើងដើម្បីសម្រេចនូវគោលបំណងចុងក្រោយរបស់យើង គឺស្លាប់ដោយមានសេរីភាព។ ខ្ញុំទុកឲ្យប្រជាជនអាមេរិកទាំងអស់ឲ្យទទួលរងនូវវិប្បដិសារីអំពីការស្លាប់របស់ប្រជាជនកម្ពុជាអំពីបញ្ហានៅបច្ចុប្បន្ន និងអនាគតរបស់កម្ពុជា"។ *(ចប់ការអានជាភាសាអង់គ្លេស)*

លោក ស្កេនប៊ឹក នៅក្នុងអត្ថបទរបស់លោកនេះ លោកបានពិនិត្យហើយឬនៅ?

[០៩:៤០:៣១]

**ឆ៖** ខ្ញុំសរសេរបែបនេះមែន។

**ស៖** លោកអាចបញ្ជាក់បន្ថែមចំពោះខ្លឹមសារជាសរុប ដែលឧត្តមសេនីយ៍ ស៊ីសុវត្ថិ សិរិមតៈ បានសរសេរនៅពេលនោះទេ?

**ឆ៖** សិរិមតៈ គឺជាបុគ្គលដែលខ្ញុំគោរព។ គាត់ជាកងកម្លាំងនៅក្នុងរដ្ឋាភិបាល លន់ នល់ គឺរដ្ឋាភិបាលថ្មី។ អ្វីដែលគាត់និយាយ ខ្ញុំគិតថាវាជារឿងសមស្រប។

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់ពីគោលបំណងនៃលិខិតនោះបានដែរទេ?

**ឆ៖** ដោយសារតែខ្ញុំមិនមែនជាអ្នកសរសេរលិខិតនោះ ហើយខ្ញុំក៏មិនមែនជាមិត្តភក្តិស្និទ្ធស្នាលជាមួយ សិរិមតៈ ខ្ញុំមិនដឹងថាខ្ញុំឆ្លើយសំណួរលោកដោយរបៀបណានោះទេ។ នេះគឺជាលិខិតរបស់គាត់ ដូច្នេះ ខ្ញុំមិនអាចឆ្លើយតប ឬក៏មិនអាចផ្តល់មតិយោបល់អ្វីចំពោះលោកបានទេ។

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់ពីពាក្យថា "*ឡូដាយ-អ៊ីន-ហ្វ្រីដឹម*" – "ការស្លាប់នៅក្នុងសេរីភាព" នេះបានដែរទេ?

**ឆ៖** *(គ្មានការបកប្រែ)*

[០៩:៤២:៥៨]

**ប្រធានអង្គជំនុំ៖**

លោក ស្មេនប៊ឹក កុំអាលទាន់ឆ្លើយតប។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន សាក្សីទើបនិយាយថាគាត់មិនអាចនិយាយអំពីគំនិតរបស់ទៀតទេ គឺថាជាការសរសេរដោយបុគ្គលដទៃទេ។ គឺវាដែលមាននៅក្នុងលិខិតនោះ គឺមិនមែនជាពាក្យពេចន៍របស់សាក្សីនោះទេ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់ថា ទោះបីជាអត្ថបទនេះមិនមែនជា -- សរសេរឡើងដោយសាក្សីក៏ដោយ ក៏ប៉ុន្តែវាស្ថិតនៅក្នុងសៀវភៅកំណត់ហេតុរបស់សាក្សី ហើយដែលសាក្សីធ្វើការសង្ខេប។ អ៊ីចឹងវាមានន័យថា សាក្សីអាចយល់អំពីខ្លឹមសារនេះ ទើបគាត់យកចំណុចសំខាន់ៗទាំងនេះមកដាក់បញ្ចូលនៅក្នុងសៀវភៅរបស់គាត់ នៅក្នុងកំណត់ហេតុរបស់គាត់។ អ៊ីចឹងហើយបានជាខ្ញុំយល់ឃើញថា គាត់អាចឆ្លើយបញ្ជាក់បាន។

[០៩:៤៤:១៤]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងហេតុផលនៃការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាលើសំណួរនេះមានហេតុផលសមស្រប ដូច្នេះសាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវីជាតិ

ការពារក្តីលោក ខៀវ សំផន នេះទេ។ លោកមេធាវីអាចបន្តសំណួរថ្មីផ្សេងទៀត លោកមេធាវី ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក ស្តេនបឺក ខ្ញុំសូមឲ្យលោកពិនិត្យនៅលើសៀវភៅកំណត់ហេតុរបស់លោកត្រង់ទំព័រ ៤១, ចំណុចចុះត្រង់ថ្ងៃទី១១ ខែមេសា នៅក្នុងកថាខណ្ឌទី២ បន្ទាប់ពីថ្ងៃទី១១ ខែមេសា។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានជាភាសាអង់គ្លេស ដោយសារអត្ថបទជាភាសាអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

[០៩:៤៥:៣០]

**សួរដោយលោក គង់ សំអុន៖**

ខ្ញុំសូមដកស្រង់លោក ស្តេនបឹក។ *អាយ ខ្វត* – សូមដកស្រង់ *(អានជាភាសាអង់គ្លេស៖)*

"នៅវ៉ាស៊ីនតោន ឯកអគ្គរាជទូតកម្ពុជា អ៊ុំ សឹម ក្នុងសន្ទរកថាទៅដល់ក្រុមអ្នកសារព័ត៌មាននៅវ៉ាស៊ីនតោន យើងបានរកឃើញថា ករណីរបស់យើងគឺអស់សង្ឃឹមហើយ។ ប៉ុន្តែយើងត្រូវតែតស៊ូរហូតទៅដល់យើងស្លាប់។ លោកឆក់យកឱកាសពីយើង ឆក់ឱកាសបទពិសោធន៍របស់យើង ដោយសារអ្នកឯងឆ្លាតជាងយើង។ អ្នកឯងប្រើប្រាស់ឲ្យធ្វើការវាយប្រយុទ្ធគ្នា"។*(ចប់ការអានភាសាអង់គ្លេស)*

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ឆ្លើយបញ្ជាក់ថាតើអត្ថបទមួយនេះលោកបានទទួល និងបានធ្វើការរាយការណ៍អំពីខ្លឹមសារនេះដែរឬទេ?

[០៩:៤៦:៤៦]

**លោក ស៊ីដនី ស្តេនបឹក៖**

**ឆ៖** ខ្ញុំមិនចាំក្នុងការដាក់បញ្ចូលនូវសម្រង់នេះទៅក្នុងអត្ថបទរបស់ខ្ញុំទេ។ ខ្ញុំមិនដឹងថា ខ្ញុំបានឮពីអ្នកណា ប៉ុន្តែក្នុងនាមជាអ្នកសារព័ត៌មាន ខ្ញុំរកឃើញចំណុចនេះ ពីអ៊ីនធើណេត ឬពីសារព័ត៌មានដែលខ្ញុំបានឃើញឃ្លាហ្នឹង។ ខ្ញុំមិនដឹងថាខ្ញុំបានប្រើប្រាស់ឃ្លានេះនៅក្នុងដំណើររឿងនេះយ៉ាងណានោះទេ ដែល

វាមាននៅក្នុងសំណេររបស់ខ្ញុំ នេះគឺជាសំណេររបស់ខ្ញុំហើយ។ បាទ ខ្ញុំពិតបានជាបានដាក់បញ្ចូល។

**ស៖** បាទ សូមអរគុណ។ តើលោកមានបានដឹងព័ត៌មាន ឬក៏ធ្វើសេចក្ដីរាយការណ៍ទាក់ទងទៅនឹងប្រតិកម្មរបស់រដ្ឋាភិបាលអាមេរិក ទាក់ទងទៅនឹងសេចក្ដីថ្លែងរបស់លោក អ៊ុំ សឹម នេះដែរទេ?

[០៩:៤៨:១២]

**ឆ៖** អត់ចាំទេ។ មើលទៅដូចជាអ្វីដែលខ្ញុំសរសេរបញ្ចូល ប៉ុន្តែខ្ញុំមិនអាចផ្ដល់ចម្លើយជាក់លាក់ឲ្យលោកទេ។ លោកចូលទៅមើលសំណេរនៅថ្ងៃទី១១ មេសា ហើយលោកបើកមើលទៅ លោកនឹងឃើញថាខ្ញុំនឹងសរសេរវា ឬក៏អត់ហើយ។

**ស៖** បាទសូមអរគុណ។ ទាក់ទងទៅនឹងការព្រាងនូវកំណត់ហេតុរបស់លោក លោកបានបញ្ជាក់ថា លោកបានធ្វើវានៅក្នុងស្រុកខ្មែរ ហើយបានកែសម្រួលនៅពេលដែលលោកចាកចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៥។ ខ្ញុំចង់សួរថាតើការកត់ត្រាដំបូង ហើយនិងការកែសម្រួលចុងក្រោយរបស់លោកនោះ មានការប្រែប្រួលច្រើនប៉ុនណាដែរ?

**ឆ៖** អ្វីដែលខ្ញុំអាចឆ្លើយ បើថានិពន្ធនាយករបស់ខ្ញុំ ឲ្យខ្ញុំរក្សាទុកនូវកំណត់ត្រា។ ខ្ញុំមិនបានរក្សាសៀវភៅកត់ត្រាដាច់ដោយឡែកផ្សេងទៀត។ ខ្ញុំតែងតែសរសេរចូលនៅក្នុងសៀវភៅកត់ត្រារបស់ខ្ញុំ ខ្ញុំអត់បានសរសេរកំណត់ត្រាប្រចាំថ្ងៃរហូតដល់ខ្ញុំចាកចេញប្រទេសកម្ពុជា។ ដូចពីម្សិលមិញ និងពីម្សិលម៉្ងៃហើយថា គឺកំណត់ត្រានេះមិនបានចុះផ្សាយរហូតដល់ពេលដួលរំលំនៃទីក្រុងភ្នំពេញ។ គឺខ្ញុំសរសេរពីព្រឹត្តិការណ៍នៃការដួលរំលំទីក្រុងភ្នំពេញ។ ពួកគេមិនត្រូវការកំណត់ត្រានេះទេ ប៉ុន្តែខ្ញុំបានសរសេរនៅទីក្រុងបាងកក នៅពេលដែលខ្ញុំចាកចេញពីប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥។

[០៩:៥០:៣០]

**ស៖** បាទ សូមអរគុណ។ តើលោកមានកំណត់ត្រាដែលលោកបានធ្វើហ្នឹង ដែលអាចដាក់ជូនអង្គជំនុំជម្រះដើម្បីធ្វើការផ្ទៀងផ្ទាត់រវាងកំណត់ត្រាចាស់របស់លោកជាមួយនិងកំណត់ត្រាថ្មីនេះដែរទេ?

**ឆ៖** អត់ទេ ខ្ញុំមិនដែលរក្សាកំណត់ត្រាតាមរបៀបនេះទេ។ ខ្ញុំព្យាយាមស្វែងរកសៀវភៅកត់ត្រារបស់ខ្ញុំ ហើយលោកអាចប្រៀបធៀបគ្នាបាន ប៉ុន្តែខ្ញុំមិនមានហេតុផលអ្វីត្រូវពន្យល់នៅពេលខ្ញុំសរសេរគឺថា ខ្ញុំសរសេរនេះគឺសម្រាប់កំណត់ត្រាប្រចាំថ្ងៃ មិនមានអ្វីដែលខ្ញុំត្រូវការកែប្រែឃ្លាពាក្យពេចន៍ដើម្បីឲ្យវាមានអត្ថន័យ គឺជាអ្វីដែលខ្ញុំសរសេរនៅក្នុងសៀវភៅកត់ត្រារបស់ខ្ញុំតែម្ដង។

**លោក គង់ សំអុន៖**

សូមអរគុណលោក ស្តេនប៊ឺក ខ្ញុំអស់សំណួរ។ លោកប្រធាន ខ្ញុំសូមឱ្យសហមេធាវីរបស់ខ្ញុំសួរបន្ត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកភាគីទាំងអស់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ស្តេនប៊ឺក! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ហើយខ្ញុំនឹងចោទសំណួរមួយចំនួនបន្ថែមទៅកាន់លោក ក្នុងឋានៈជាមេធាវីនេះ។

លោក ស្តេនប៊ឺក លោកស្តាប់ខ្ញុំឮទេ?

**លោក ស៊ីដនី ស្តេនប៊ឺក៖**

**ឆ៖** *(គ្មានការបកប្រែ)*

[០៩:៥២:៤១]

**ស៖** ល្អណាស់អ៊ីចឹង។ សំណួរទី១ ដំបូងរបស់ខ្ញុំទាក់ទងទៅនឹងបទពិសោធន៍របស់លោកជាអ្នកកាសែតធ្វើការនៅក្នុងប្រទេសមានសង្គ្រាម។ ខ្ញុំបានតាមដានសក្ខីកម្មរបស់លោកនៅទីនេះ ហើយខ្ញុំឃើញថា លោកបាន -- ក្រៅពីគ្របដណ្តប់លើជម្លោះសង្គ្រាមនៅប្រទេសកម្ពុជា លោកបានគ្របដណ្តប់ព័ត៌មានសង្គ្រាមនៅវៀតណាម ហើយនិងប្រទេសផ្សេងទៀត។ តើលោកធ្លាប់បាននេះទេ ធ្លាប់បានទៅសិក្សាស្រាវជ្រាវនៅប្រទេសផ្សេងទៀតទេ?

**ឆ៖** បាទ ខ្ញុំគ្របដណ្តប់ព័ត៌មាននៅឥណ្ឌា និងប៉ាគីស្ថាន គឺថាខ្ញុំយកព័ត៌មាននៅក្នុងឆ្នាំ១៩៧១ គឺព័ត៌មានសង្គ្រាមនៅឥណ្ឌានិងប៉ាគីស្ថាន ចំពោះការទម្លាក់គ្រាប់បែកនៅបង់ក្លាដេស។ ខ្ញុំសរសេរអត្ថបទសារព័ត៌មានជាច្រើន។ លោកស្រីអាចរកឃើញព័ត៌មានទាំងអស់នៅក្នុងសារព័ត៌មានញូវយ៉កថាមស៍ បាទ នៅក្នុងការចងក្រងព័ត៌មានទាំងអស់នោះជាមួយញូវយ៉កថាមស៍។

[០៩:៥៤:២៤]

**ស៖** ចាសដើម្បីឱ្យលោកបំភ្លឺតុលាការ ប្រហែលជាសំណួររបស់យើងខ្ញុំនេះ អាចថាវាមើលទៅ

វាងាយពេក ក៏ប៉ុន្តែយើងនៅចំពោះមុខតុលាការ ហើយត្រូវតែសក្ខីកម្ម ហើយនិងភស្តុតាងនោះ លោកជាអ្នកបង្ហាញទេ។ អ៊ីចឹងពេលខ្លះសូមលោកអភ័យទោសដល់យើងខ្ញុំផង បើសិនជាសំណួរយើងនោះវាមើលទៅដូចថាលក្ខណៈដូចឆោតល្ងង់ពេក ក៏ប៉ុន្តែយើងគ្រាន់តែសុំឱ្យលោកជួយបំភ្លឺចំណុចមួយចំនួនតែប៉ុណ្ណោះ។ ក្នុងឋានៈលោកជាអ្នកកាសែត ហើយលោកបានធ្លាប់ទៅប្រទេសដែលមានសង្គ្រាមទាំងអស់នេះ តើលោកអាចពន្យល់បានទេថា អំពីប្រភពនៃព័ត៌មានទាំងអស់ដែលលោកបានទៅទទួលនេះ តើមានលក្ខណៈពិសេសអ្វីទេ? លោកបានពន្យល់ផងដែរ ថានៅពេលដែលលោកនៅប្រទេសកម្ពុជាប្រភពព័ត៌មានមួយក្នុងចំណោមទាំងអស់នោះ គឺថាទាក់ទងទៅនឹងការរុលចូលមកមុខនៃកងទ័ពទាំងពីរភាគីនេះគឺប្រភពមួយនោះគឺថាស្ថានទូតអាមេរិកាំង។ អ៊ីចឹងខ្ញុំសំណួរខ្ញុំចង់ដឹងថាតើក្រៅពីស្ថានទូតអាមេរិកាំងនេះ តើលោកមានប្រភពអ្វីផ្សេងទៀតទាក់ទងទៅនឹងការរីកចម្រើននៃការចរចា ឬក៏គោលជំហរអ្នកកាទូតទាំងពីរភាគីនេះ? តើលោកអាចពន្យល់បានទេ មានប្រភពអីផ្សេង?

[០៩:៥៦:០៤]

**ឆ៖** មានស្ថានទូតផ្សេងទៀតជាច្រើន ស្ថានទូតអូស្ត្រាលី ជប៉ុន ដែលធ្វើការឃ្លាំមើល តាមដានឃ្លាំមើលអំពីសង្គ្រាម។ អ្នករាយការណ៍ផ្សេងទៀតនិយាយទៅកាន់មនុស្សទាំងនេះ ខ្ញុំក៏និយាយទៅកាន់មនុស្សទាំងនេះ ខ្ញុំក៏បានធ្វើសេចក្ដីសម្រេចចិត្តថាតើពួកគេ ព័ត៌មានរបស់គេវាសុក្រឹត ឬក៏អត់នោះ។ នេះគឺជាអ្នកដែលមានវិជ្ជាជីវៈត្រឹមត្រូវអ៊ីចឹង ដូច្នេះហើយបានទើបខ្ញុំសរសេរ។ ហើយដើម្បីឱ្យខ្ញុំរកឃើញថាវាជាការពិត ព័ត៌មានពេញលេញឬក៏អត់ ហើយក៏ខ្ញុំបាននិយាយទៅកាន់មន្ត្រីនានា មន្ត្រីនៃកងទ័ពរបបលន់ នល់ នៅពេលដែលខ្ញុំចេញទៅក្រៅ ហើយរាយការណ៍អំពីសង្គ្រាមនៅពេលណាដែលខ្ញុំមានឱកាសជួបពួកគេនៅក្នុងទីក្រុងភ្នំពេញ។ ដូច្នេះក្រៅពីអ្វីដែលខ្ញុំឃើញដោយផ្ទាល់ភ្នែក គឺខ្ញុំត្រូវប្រមូលព័ត៌មានពីអ្នកដែលគេតាមដានចំពោះព័ត៌មានសង្គ្រាមនេះដែរ។

**សៈ** ខ្ញុំរហូតដល់ពេលនេះ អ្វីដែលខ្ញុំយល់ពីសក្ខីកម្មរបស់លោកនោះ គឺថាផ្នែកយោធាប្រភពផ្នែកយោធាដែលលោកមានតែមួយគត់នោះ គឺថាជួនពីកងទ័ព លន់ នល់ ជួនពីខាងពួកអាមេរិកាំង គឺថាលោកមិនអាចទៅតំបន់រំដោះបានទេ។ អ៊ីចឹងសំណួរខ្ញុំចង់ដឹងថា នៅភ្នំពេញនេះតើលោកមានទំនាក់ទំនងជាមួយអ្នកគាំទ្រខ្មែរក្រហមដែរឬទេក៏អត់? ឬក៏អ្នកគាំទ្ររណសិរ្សរួបរួមជាតិកម្ពុជាដែរឬទេ?

[០៩:៥៨:៣៤]

**ឆ៖** ខ្ញុំមិនមានទំនាក់ទំនងដោយផ្ទាល់នោះទេ ប៉ុន្តែមានមនុស្សខ្លះមានការទំនាក់ទំនងជាមួយនឹង

ខ្មែរក្រហម អ្នកដែលគាំទ្រមានសមានចិត្តជាមួយខ្មែរក្រហម។ អ្វីដែលខ្ញុំរកឃើញថាវាមានសារប្រយោជន៍ ឬគួរឲ្យជឿបាន គឺខ្ញុំត្រូវប្រើប្រាស់ព័ត៌មាននោះហើយ។

**ស៖** សូមអរគុណដែលបានផ្តល់សេចក្តីបំភ្លឺទាំងអស់នេះ។ សំណួរមួយទៀត ថាតើលោកធ្លាប់ទៅ នៅពេលដែលស្នាក់នៅអាស៊ីនេះ លោកធ្លាប់ទៅប្រទេសចិនដែរឬទេ? ហើយនិងនៅដល់នោះដើម្បីសំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំរណសិរ្សរួបរួមជាតិ ដែលមានសម្តេច សីហនុ មានវត្តមាននៅប្រទេសចិននេះ?

**ឆ៖** អត់ទេ ខ្ញុំមិនដែលបានទៅប្រទេសចិនទេនៅក្នុងអំឡុងពេលនុំង។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី ហើយនៅសំណួរច្រើនទៀតទេ? ទំនងចំណាយពេលវេលាប្រហែលប៉ុន្មានទៀតក្នុងការសួរសាក្សីរូបនេះ?

[១០:០០:០៦]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគិតថាបើតាមមើលនេះ ប្រហែលជាខ្ញុំត្រូវការប្រហែលជា ៤៥ទៅ ៥០នាទី ទៀត។ ហើយខ្ញុំបើគិតទៅថាខ្ញុំនឹងប្រើប្រាស់ពេលវេលាដែលតុលាការផ្តល់ជូនខ្ញុំ។ ហើយខ្ញុំព្យាយាម បញ្ចប់ឲ្យបានមុនម៉ោង ក៏ប៉ុន្តែដោយសារខ្ញុំមានសម្រង់ជាភាសាអស់គ្លេសមួយចំនួនដែលខ្ញុំត្រូវអានជូន អឺចឹងប្រហែលជាអាចប្រើប្រាស់ពេលវេលាដែលតុលាការបែងចែកជូននេះអស់តែម្តងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ខ្ញុំសួរនេះដោយសារពេលវេលាដល់ពេលត្រូវសម្រាកហើយ។ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ និងម្ភៃនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោក ស៊ីដនី ស្តេនប៊ីក ឥឡូវនេះអង្គសវនាការត្រូវសម្រាក ២០នាទីចាប់ពីពេលនេះតទៅ។ ដូច្នេះ សូមលោកជ្រាបបាទ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០១ នាទី ដល់ម៉ោង ១០:២២ នាទី)*

[១០:២២:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្តីលោក ស្កេនប៊ឹក តើលោករៀបចំខ្លួនហើយឬនៅ?

**លោក ស៊ីដនី ស្កេនប៊ឹក៖**

បាទ លោកប្រធាន ខ្ញុំត្រៀមរួចរាល់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១០:២២:៤៤]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ស្កេនប៊ឹក សាជាថ្មីម្តងទៀត -- ខ្ញុំបន្តទៀត។ យើងកំពុងនិយាយពីបទពិសោធន៍របស់លោកជាអ្នកកាសែតនៅក្នុងប្រទេសដែលមានសង្គ្រាម។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីសង្គ្រាមនៅប្រទេសវៀតណាម ដែលលោកបានគ្របដណ្តប់។ អ៊ីចឹងខ្ញុំចង់ដឹងថា តើនៅក្នុងក្របខ័ណ្ឌនៃការងាររបស់លោកនៅប្រទេសវៀតណាមនេះ ហើយនិងពេលបន្ទាប់មកទៀតនៅក្នុងការងាររបស់លោកនៅប្រទេសកម្ពុជា តើលោកធ្លាប់បានផ្សាភ្ជាប់ទំនាក់ទំនងរវាងសង្គ្រាមទាំងពីរនេះដែរឬទេ? ខ្ញុំសូមបញ្ជាក់សំណួរឡើងវិញ តើនៅពេលដែលលោកមកដល់ប្រទេសកម្ពុជាចន្លោះឆ្នាំ៧០-៧៥ មុនថ្ងៃទី១៧ មេសា ហើយនិងរយៈកាលមុនឆ្នាំ៧៥ តើប្រភពព័ត៌មានយោធាអាមេរិកាំងរបស់លោកត្រូវបានពន្យល់ប្រាប់លោកថា ហេតុអ្វីបានជាសហរដ្ឋអាមេរិកសម្រេចទម្លាក់គ្រាប់បែកលើទឹកដីប្រទេសកម្ពុជា? តើលោកអាចពន្យល់អំពីទំនាក់ទំនងរវាងសង្គ្រាមប្រទេសនៅវៀតណាម ហើយនិងសង្គ្រាមនៅប្រទេសកម្ពុជាបានដែរឬទេ?

មុននឹងអំមិញ គេនិយាយប្រាប់ខ្ញុំថា ខ្ញុំនិយាយខ្លាំងពេក ដល់ឥឡូវនេះ គេសុំឲ្យខ្ញុំនិយាយឲ្យជិតមីក្រូជាងហ្នឹងបន្តិច។ ឥឡូវនេះគ្រាន់បើជាងមុនទេ?

លោក ស្តេនប៊ឹក តើលោកបានឮសំណួរខ្ញុំដែរឬទេ?

[១០:២៤:៤៧]

**លោក ស៊ីដនី ស្តេនប៊ឹក៖**

**ឆ៖** បាទ គឺមានទំនាក់ទំនង គឺថាមានប្រវត្តិ -- គឺមានប្រវត្តិសាស្ត្ររៀបរាប់អំពីទំនាក់ទំនងនេះ ដែលប្រវត្តិសាស្ត្រនេះរៀបរាប់អំពីទំនាក់ទំនងរវាងអាមេរិក។ ហើយការទម្លាក់គ្រាប់បែកត្រូវបានគេធ្វើជាសម្ងាត់រហូតដល់ពួកគេទទួលបានការអនុញ្ញាត មិនមែនជាការអនុញ្ញាតជាលាយលក្ខណ៍អក្សរនោះទេ ប៉ុន្តែជាការអនុញ្ញាត ហើយគេទម្លាក់គ្រាប់បែកទៅលើផ្លូវលំហូជីមិញ គឺជាផ្លូវលំដែលផ្គត់ផ្គង់សម្ភារៈក៏ដូចជាស្បៀងអាហារទៅដល់ទាហាននៅក្នុងប្រទេសវៀតណាម គឺការប្រយុទ្ធរវាងវៀតណាមខាងជើង និងខាងត្បូង។ ហើយជនជាតិវៀតណាមក៏បង្កើតនូវបន្ទាយនៅតាមព្រំដែនជាមួយនឹងខាងត្បូង -- វៀតណាមខាងត្បូង ហើយក៏ជាព្រំដែនជាមួយប្រទេសកម្ពុជាផងដែរ។ សម្រាប់អាមេរិកគឺមានហេតុផលទាំងផ្នែកនយោបាយ និងផ្នែកនានាដែលព្យាយាមដើម្បីបញ្ចប់សង្គ្រាមនៅវៀតណាម ដែលបន្តអស់រយៈពេលជាយូរណាស់មកហើយ។ ដូច្នេះហើយដើម្បីកាត់បន្ថយនូវទំហំនៃទ័ពរបស់វៀតណាមនោះ ដូច្នេះហើយទើបវៀតណាមស្នើសុំឲ្យមានការសាងសង់ជាបន្ទាយ ក៏ដូចជាផ្លូវ ដើម្បីដឹកជញ្ជូនស្បៀងអាហារពីសមុទ្រចូលមកវៀតណាម។ ហើយគេទទួលការផ្គត់ផ្គង់ស្បៀងអាហារតាមមធ្យោបាយនេះ។

[១០:២៧:១០]

ដូច្នេះគឺថាគេមិនដឹងថាអ្នកណាទៅជួបទេ ប៉ុន្តែគេទៅជួបសម្តេច សីហនុ ហើយទទួលការឯកភាពដោយផ្ទាល់មាត់ ដើម្បីធ្វើការទម្លាក់គ្រាប់បែកនៅតាមផ្លូវលំ។ ដូច្នេះហើយគឺយើងនិយាយថានេះគឺជាការទម្លាក់គ្រាប់បែកដោយសម្ងាត់ដោយមានរយៈពេលប្រហែលជា៩ខែ គឺនៅមុនឆ្នាំ១៩៧០។ គឺដោយសារតែមានការទំនាក់ទំនងជាមួយសម្តេច សីហនុ នៅពេលដែលគាត់នៅប្រទេសបារាំង។

ហើយបន្ទាប់មកគឺមានរដ្ឋប្រហារ ហើយនៅពេលនោះគេទម្លាក់គាត់ចេញពីប្រមុខរដ្ឋាភិបាល គឺក្រុមរដ្ឋប្រហារដោយលោក លន់ នល់។ ហើយពួក លន់ នល់ ចង់ឲ្យមានការជួយពីសហរដ្ឋអាមេរិក។ សហរដ្ឋអាមេរិកក៏យល់ព្រម ហើយគេពិភាក្សាអំពីព័ត៌មានលម្អិតជាមួយកម្ពុជា។ ប្រហែលជាក្នុងខែមីនា ឬក៏មេសា គឺមានការបញ្ជូនទាហានអាមេរិកប្រហែលជារាប់ពាន់នាក់មកក្នុងប្រទេសកម្ពុជា ដើម្បី

បំផ្លាញនូវផ្លូវដឹកជញ្ជូន។ គឺគេចូលមកដើម្បីបំផ្លាញផ្នែកចំនួននៃផ្លូវលំហូជីមិញ។ ហើយប្រធានាធិបតីនិកសុន បានចាត់ទុកថា នេះគឺជាលទ្ធិនិកសុន។

គឺថាជាលទ្ធិមួយដែលជួយឲ្យពួកគេអាចជួយខ្លួនគេបាន ដូច្នេះហើយគេទុកទាហាននៅតែ ៦ខែប៉ុណ្ណោះ។ ហើយជាលទ្ធផល គឺថាសង្គ្រាមរហូតមកដល់ចំណុចនោះ -- រហូតមកដល់ពេលនោះ គឺកើតឡើងនៅតែតាមបណ្ដោយព្រំដែនវៀតណាម-កម្ពុជានៅភាគខាងកើតតែប៉ុណ្ណោះ ប៉ុន្តែក្រោយមកទៀតវាទៅជាសង្គ្រាមទូទាំងប្រទេសតែម្ដង។ ដូច្នេះហើយទាហានសហរដ្ឋអាមេរិក គឺត្រូវដកចេញក្រោយរយៈពេល ៦សប្ដាហ៍ក្រោយពេលចូលលុកលុយ។

[១០:៣០:០១]

នៅពេលនោះ ពួកខ្មែរក្រហមចាប់ផ្ដើមរីកចម្រើន ចាប់ផ្ដើមកើនឡើង ធំឡើងៗ ដោយសារពីមុនអាមេរិកទម្លាក់គ្រាប់បែកជាសម្ងាត់រយៈពេល៩ខែ ប៉ុន្តែក្រោយមកទៀត ដោយសារតែកម្ពុជាអនុញ្ញាតឲ្យមានការទម្លាក់គ្រាប់បែកនៅគ្រប់ទីកន្លែងនោះ ដូច្នេះហើយគឺថាគ្មានអ្នកណាម្នាក់ដឹងទេ។ ខ្ញុំគ្រាន់តែប្រាប់ថា ខ្ញុំនឹកឃើញអ្វី និយាយអ៊ីចឹងឯង។ គឺថានៅពេលនោះ មិនមានអ្នកណាដឹងថា តើមានអ្វីកើតឡើងទេ ប្រសិនបើអាមេរិកមិនមកចូលលុកលុយ ហើយមិនមកទម្លាក់គ្រាប់បែកនោះទេ។ ខ្ញុំគិតថាប្រហែលជាវាចំណាយពេលវេលាយូរ។ ប៉ុន្តែមានករណីជាច្រើននៅពេលនោះ ប្រទេសកម្ពុជាមិនមែនជាសង្គ្រាមវៀតណាមនោះទេ។ ដូច្នេះហើយ ខ្ញុំថានេះគឺជាទំនាក់ទំនងដែលលោកស្រីចង់សួរខ្ញុំមើលទៅ។

**ស៖** ចាស អ៊ីចឹងហើយ មានចំណុចពិសេសមួយ គឺថាលោកបានលើកអម្បាញ់មិញ ថាពីដំបូងនោះ ការបោកគ្រាប់បែកនោះ កម្រិតត្រឹមទម្លាក់គ្រាប់បែកសម្ងាត់នោះ កម្រិតត្រឹមតែផ្លូវលំហូជីមិញទេ ដើម្បីកាត់ផ្ដាច់ការផ្គត់ផ្គង់ស្បៀងទៅដល់ពួកវៀតណាម។ ម្សិលមិញលោកបានលើកឡើងថា -- លើកឡើងប្រាប់ទៅមេធាវី កូប៉េ ថាការកាត់ផ្លូវផ្គត់ផ្គង់ស្បៀងអាហារនេះ ទៅកងទ័ពបដិ -- ភាគីគឺជាការដែលអនុវត្តគ្រប់ទិសទី ថានៅអាមេរិកាំង នៅសហរដ្ឋអាមេរិក ក៏ដូចជានៅប្រទេសផ្សេងដែរ គឺថាគេតែងធ្វើដូច្នេះ ដើម្បីឈ្នះលើភាគម្ខាងទៀត។ អ៊ីចឹងអានេះបើតាមប្រភពដែលលោកមាន អ៊ីចឹងមែនទេ?

[១០:៣២:១៥]

**ឆ៖** បាទ ខ្ញុំគិតថា ខ្ញុំប្រហែលជាមិនអាចឆ្លើយសំណួរនេះបានទេ។ គឺវាផ្អែក ថាតើលោកស្រីគិតថាអ្វីជាគំនិតល្អ? ឧទាហរណ៍ថា ជនជាតិអាមេរិក គេគាំទ្រជំហរ ហើយជនជាតិអាមេរិកាំងភាគ

ច្រើនគិតថា សង្គ្រាមវៀតណាមមិនមែនជារឿងចាំបាច់។ ទោះបីយ៉ាងណាក៏ដោយ អ្វីដែលយើងសង្កេតឃើញ គឺថាការទម្លាក់គ្រាប់បែកសាថ្មី ឬក៏ការទំនាក់ទំនងសាថ្មី គឺវាកើតឡើងបន្ទាប់ពីសម្តេច សីហនុផ្តាច់ទំនាក់ទំនងជាមួយនឹងទីក្រុងវ៉ាស៊ីនតោន។ ហើយការផ្តាច់ទំនាក់ទំនងហ្នឹងមិនក្រោយពេល ប្រហែលជាបន្តិចក្រោយឆ្នាំ៧០ប៉ុណ្ណោះ។ ដូច្នេះខ្ញុំមិនអាចជម្រាបលោកស្រីបាន ថាតើ គឺថានៅពេលសង្គ្រាមយើងមិនអាចទាយស្មានថា ប្រសិនបើយើងធ្វើបែបនេះ យើងទទួលបានលទ្ធផលបែបណានោះទេ។ ដូច្នេះអ្វីដែលខ្ញុំជម្រាបបាន គឺថាជនជាតិអាមេរិកាំងជាច្រើន មិនរីករាយ មិនសប្បាយចិត្តជាមួយនឹងសកម្មភាពបែបនេះទេ។

[១០:៣៣:៤៦]

**ស៖** ខ្ញុំគិតថាយើងមិនយល់គ្នាទេ ប្រហែលជាសំណួរខ្ញុំមិនច្បាស់ក៏មិនដឹង។ ពេលដែលខ្ញុំសួរលោកអម្បាញ់មិញនេះ គឺថាក្នុងឋានៈលោកជាអ្នកកាសែតដែលធ្លាប់គ្របដណ្តប់ប្រទេសមានសង្គ្រាមនោះ គឺសំណួរខ្ញុំមិនចង់ដឹងថា មិនចង់ដឹងពីអ្វីដែលកើតឡើងទេ ហើយមិនចង់ឲ្យលោកទាយស្មានៗទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែដឹងថានៅក្នុងយុទ្ធសាស្ត្រយោធាដែលលោកទទួលបានជាព័ត៌មាន ដែលលោកធ្លាប់ដឹង។ តើនេះវាជាយុទ្ធសាស្ត្រដែលជាញឹកញាប់ ដែលគេប្រើប្រាស់ដែរឬទេ បើតាមបទពិសោធន៍លោកក្នុងយុទ្ធសាស្ត្រយោធានេះ ដែលលោកធ្លាប់គ្របដណ្តប់? បើខ្ញុំមិនច្រឡំទេ ម្សិលមិញ ឬក៏ម្សិលម៉្ងៃ លោកបាននិយាយជាមួយសហព្រះរាជអាជ្ញាអន្តរជាតិអំពីការបាញ់ផ្លោងដែលលោកបានឃើញ មុនឆ្នាំ១៩៧៥ នៅព្រលានយន្តហោះភ្នំពេញ។ ហើយពេលនោះ ហើយម្សិលមិញ ពេលដែលលោកឆ្លើយទៅនឹងលោកមេធាវី កូប៉េ លោកបានឆ្លើយថា នៅក្នុងពេលសង្គ្រាមនោះ លោកបានរៀបរាប់ការកាត់ផ្តាច់ការផ្គត់ផ្គង់ស្បៀងអាហារហ្នឹង ទៅភាគីប្រឆាំងហ្នឹង ជាការអនុវត្តជាទូទៅជាញឹកញាប់។ អ៊ីចឹងខ្ញុំចង់ដឹងថាតើខ្មែរក្រហមដែលគាត់ធ្វើយ៉ាងដូចគ្នានេះ ហើយនិងយុទ្ធសាស្ត្ររបស់អាមេរិកាំងដែលកាត់ផ្តាច់ផ្លូវលំហូជីមិញនេះ នេះវាជាយុទ្ធទាំងពីរហ្នឹង ខាងខ្មែរក្រហមក៏គេព្យាយាមកាត់ផ្តាច់ការផ្គត់ផ្គង់ស្បៀងខាងអាមេរិកាំងក៏ធ្វើដូចគ្នា។ នេះជាការអនុវត្តញឹកញាប់ទេ?

[១០:៣៥:៤០]

**ឆ៖** គឺថាអ្វីដែលខ្ញុំចង់និយាយយោង គឺនិយាយអំពីការកាត់ផ្តាច់ផ្លូវលំហូជីមិញ គឺការកាត់ផ្តាច់ផ្គត់ផ្គង់ ក៏ដូចជាការកាត់ផ្តាច់ផ្លូវទឹកតាមទន្លេមេគង្គដែលផ្គត់ផ្គង់មកប្រទេសកម្ពុជា។ ហើយខ្ញុំមិនមែននិយាយត្រឹមតែនៅព្រំដែននោះទេ។ ដូច្នេះខ្ញុំគិតថាលោកស្រី ប្រហែលជានិយាយអំពីអ្វីមួយដែលវាមាន

លក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងអ្វីដែលខ្ញុំគិត។ ដូច្នេះហេតុអ្វីបានជាការទម្លាក់គ្រប់បែកវាមានទំហំធំធេងបែបនេះ? ខ្ញុំមិនដឹងថាអ្នកណាជាអ្នកសម្រេចឲ្យមានការទម្លាក់ដែលមានរយៈយូរ និងច្រើនបែបនោះទេ។ ហើយខ្ញុំក៏មិនដឹងថាហេតុអ្វីបានជាគេធ្វើបែបនេះដែរ។ គេថាគេមានគោលដៅផ្សេង មានគោលដៅជាច្រើន។ ប្រហែលជាគេចង់ឲ្យរដ្ឋាភិបាល លន់ នល់ នៅបន្តរស់រានតទៅមុខទៀត។

ដូច្នេះខ្ញុំអាចជម្រាបលោកស្រីបានតែប៉ុណ្ណឹង។ ហើយខ្ញុំគិតថាវាមិនមែនជាអ្វីដែលសមស្របដែលសមស្មើគ្នានោះទេ។ អ្វីហេតុផលដែលអាមេរិកាំងទម្លាក់គ្រាប់បែក ប្រហែលជាមិនចង់ឲ្យមានការផ្គត់ផ្គង់គឺពួកគេព្យាយាមទម្លាក់គ្រប់បែកទៅលើទាហានខ្មែរក្រហម។

[១០:៣៦:៣៣]

**សៈ** ចាស លើប្រធានបទនៃការទម្លាក់គ្រប់បែកដដែល ដែលលោកបានពន្យល់ពីមូល -- ដែលការទម្លាក់គ្រប់បែកនេះចេញពីផ្លូវលំហូជីមិញរហូតដល់ទូទាំងប្រទេសតែម្តង។ ហើយលោកបានរៀបរាប់ផងដែរថា នៅពេលដែលលោកផ្លាស់ទីនៅចន្លោះឆ្នាំ៧០ ទៅ៧៥ នៅប្រទេសកម្ពុជា លោកធ្លាប់បានឃើញការខូចខាតដែលបង្កដោយគ្រាប់បែកបេ-៥២។ សំណួរទី១ គឺថាកន្លែងដែលត្រូវបំផ្លិចបំផ្លាញដោយគ្រប់បែកអាមេរិកាំង លោកបានពន្យល់ថាលោកឃើញថាស្ទើរតែពុំមានប្រជាជនទៀតទេ ហើយលោកមានឱកាសតិចតួចណាស់ក្នុងការសន្ទនាជាមួយអ្នកដែលនៅក្នុងទីកន្លែងនេះបន្តិចបន្តួចផង។ ក៏ប៉ុន្តែទន្ទឹមនឹងហ្នឹង អ្វីដែលលោកបានសង្កេតឃើញនោះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំហ្នឹង តើលោកធ្លាប់បានពិនិត្យមើលទេសភាពស្រែចម្ការ មុនពេលទម្លាក់គ្រាប់បែកហ្នឹង តើលោកឃើញថាមានការប្រែប្រួលទេមុនពេលទម្លាក់គ្រាប់បែក ហើយនិងក្រោយពេលទម្លាក់គ្រាប់បែក?

[១០:៣៨:៥៥]

**ឆៈ** ប្រាកដជាមានការផ្លាស់ប្តូរហើយ។ ប្រសិនបើយើងវាយប្រហារទៅលើទាហានដែលនៅជនបទ គឺជាកន្លែងដែលយើងរើសទាហាន ហើយនិងកន្លែងដែលពួកទាហាននោះមានប្រភពមកនោះគឺថាវាប្រាកដជាមិនមានអ្វីទាក់ទងទៅនឹងការផ្គត់ផ្គង់ខ្លាំងក្លានោះទេ។ ដូច្នេះប្រសិនបើយើងសួរថាមានទំនាក់ទំនង ខ្ញុំប្រាប់រួចហើយថា វាមានទំនាក់ទំនងផ្នែកប្រវត្តិសាស្ត្រដែលពាក់ព័ន្ធទៅនឹងសង្គ្រាមវៀត-ណាម។ ដូច្នេះ ខ្ញុំអាចជម្រាបលោកស្រីបានតែប៉ុណ្ណោះទេ ព្រោះថាខ្ញុំមិនអាចចូលទៅកន្លែងទាំងអស់នោះបានទេ ប្រសិនបើព្យាយាមចូលទៅកន្លែងនោះ ប្រហែលជាមានបញ្ហា ជាពិសេសកន្លែងដែលមានការទម្លាក់គ្រប់បែកនោះ។

**សះ** តើនៅពេលដែលលោកនៅភ្នំពេញនោះ លោកធ្លាប់បានសំណេះសំណាលជាមួយអាចារ្យកាតូលិកម្នាក់ដែលឈ្មោះ ហ្វ្រង់ស្វ័រ ប៉ុងស្វង់?

**ឆះ** ខ្ញុំមិនដែលធ្លាប់និយាយជាមួយអ្នកណាទេ ប៉ុន្តែខ្ញុំស្គាល់ជនជាតិបារាំងទាំងនេះ ប៉ុន្តែខ្ញុំមិនដែលធ្លាប់ជជែកជាមួយគាត់ទេ។

**សះ** តើលោកមានចាំថា គាត់នៅស្ថានទូតបារាំងដែរទេ នៅពេលដែលលោកនៅស្ថានទូតបារាំងហ្នឹង?

**ឆះ** បាទ។

[១០:៤០:៥១]

**សះ** ម្សិលមិញនៅពេលដែលអ្នក -- លោកនិយាយអំពីអ្នកជម្លៀសចេញពីក្រុងភ្នំពេញនោះ លោកបាននិយាយថា លោកបានសំណួរ -- ចោទសំណួរទៅពួកគាត់ថា បើតាមព័ត៌មាន -- ប្រភពព័ត៌មានដែលលោកបានទទួលពីអ្នកដែលរត់ចេញពីតំបន់នោះ ប្រសិនបើខ្ញុំនិយាយខុស សូមកែខ្ញុំ ហើយបើតាមលោកដឹងនោះ ពុំមានអ្នកដែលរត់ចេញ -- រត់គេចការទម្លាក់គ្រាប់បែកអាមេរិកាំងទេ។ តើខ្ញុំយល់អ្វីដែលលោកនិយាយបានច្បាស់ទេ ឬក៏លោកចង់បន្ថែមអ្វី?

**ឆះ** គឺថា លោកស្រី -- ខ្ញុំគិតថា ខ្ញុំតាមសំណួរលោកស្រីអត់ទាន់ទេ។ ខ្ញុំមិនយល់អំពីអ្វីដែលលោកស្រីចង់សួរទេ។ មនុស្សដែលខ្ញុំធ្លាប់និយាយជាមួយ គឺថាខ្ញុំជួបជាមួយមនុស្សទូទៅ។ ខ្ញុំជួបជាមួយមនុស្សដែលមាន -- មិនប្រាកដថាមានប៉ាស្ព័របារាំង ឬក៏ប៉ាស្ព័រអ្វីនោះទេ។ ហើយគាត់បាន គឺថាលោកស្រីលើកឈ្មោះ គាត់ដោយសារតែគាត់អ្នកស្រាវជ្រាវល្បីឈ្មោះ។ ដូច្នេះហើយ គឺថា លោកស្រីសួរថា ហេតុអ្វីបានខ្ញុំមិនសម្គាសគាត់។ ខ្ញុំគិតថា ខ្ញុំអាចមានឱកាស ប៉ុន្តែខ្ញុំមិនស្គាល់គាត់ទេ។ គឺថាខ្ញុំធ្លាប់និយាយជាមួយអ្នកទាំងអស់ណាដែលនៅក្នុងស្ថានទូតនោះ។

[១០:៤២:៣៥]

**សះ** សូមទោស កាត់ផ្តាច់លោកហ្នឹង ខ្ញុំគិតថា យើងមិនយល់គ្នាទេ។ នេះប្រហែលជាសំណួររបស់ខ្ញុំមិនច្បាស់អម្បាញ់មិញនេះ។ ឥឡូវនេះ ខ្ញុំសូមបំភ្លឺសំណួរខ្ញុំ។ ខ្ញុំអម្បាញ់មិញនេះ តាមពិតខ្ញុំចាប់អារម្មណ៍អំពីរយៈកាលមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ ខ្ញុំគ្រាន់តែរំឭកអំពីលក្ខខណ្ឌដែលលោកបានជួប ហ្វ្រង់ស្វ័រ ប៉ុងស្វង់ ប៉ុន្តែសំណួរខ្ញុំសួរទាក់ទងនឹងអ្នកជម្លៀសនេះ គឺថាអ្នកដែលរត់គេចខ្លួននេះ គឺថាចន្លោះឆ្នាំ៧០-៧៥ទេ។ អ៊ីចឹងឲ្យច្បាស់ទាំងអស់គ្នា។ អ៊ីចឹងចន្លោះ ៧០-៧៥ នេះនៅពេលដែលលោក

ឆ្លើយតបទៅនឹងលោកមេធាវី កូប៉េ លោកនិយាយថា បើខ្ញុំយល់មិនច្រឡំទេ លោកថាអ្នកភៀសខ្លួនដែលលោកបានសំណេះសំណាលជាមួយនៅក្នុងជំរំ ឬក៏នៅក្នុងសណ្ឋាគារដែលភ្នំពេញ នៅក្នុងទីក្រុងភ្នំពេញនេះ លោកបាននិយាយថា ជនភៀសខ្លួន ហើយនិងអ្នកដែលគេ -- ជនភៀសសឹកនេះបានប្រាប់លោកថា គេបានរត់ចេញពីតំបន់រំដោះដែលគ្រប់គ្រងដោយខ្មែរក្រហម ហើយលោកមិនបាននិយាយជាមួយជនភៀសសឹកដែលរត់គេចពីការទម្លាក់គ្រាប់បែកអាមេរិកាំងនោះទេ។ ខ្ញុំមិនដឹងថាអ្វីដែលខ្ញុំនិយាយនេះច្បាស់លាស់ ឬក៏អត់ទេ?

**ឆ៖** បាទ ច្បាស់ហើយ គឺត្រឹមត្រូវហើយអត់មានអ្នកណាប្រាប់ខ្ញុំនេះទេ។ នៅពេលដែលខ្ញុំសម្រេចថាអ្នកណា គិតមើលថាអ្នកណានៅក្នុងស្ថានទូតខ្លះ ខ្ញុំមិនដឹង ប៉ុន្តែក្រោមកមានជនភៀសខ្លួនចូលមកដល់។ ពួកគេបានរៀបរាប់អំពីរឿងរ៉ាវរបស់ពួកគេ ហើយគេមិនបាននិយាយថា គេរត់គេចពីការទម្លាក់គ្រាប់បែកទេ គេនិយាយថាគេរត់គេចពីពួកខ្មែរក្រហម។ ហើយសហភាតារបស់លោកស្រីនិយាយថា វាមិនមែនជាការពិតទេ។ ខ្ញុំគិតថា ខ្ញុំមិនដឹងទេ ព្រោះខ្ញុំជាអ្នកសម្ភាសគេ គឺគេនិយាយអ៊ីចឹង។ ប្រហែលជាមានអ្នករត់គេចពីការទម្លាក់គ្រាប់បែក ប៉ុន្តែខ្ញុំអត់ដែលជួប។ ប៉ុន្តែខ្ញុំជួបតែអ្នកដែលខ្លាចខ្មែរក្រហមប៉ុណ្ណោះ។

[១០:៤៤:៥៥]

**ស៖** បើអ៊ីចឹង គឺខ្ញុំយល់ត្រឹមត្រូវហើយអ្វីដែលលោកនិយាយម្សិលមិញនេះមានន័យអ៊ីចឹង។ ខ្ញុំចង់និយាយពីចំណុចមួយទៀតទាក់ទងនឹង ហ្វ្រង់ស្វ័រ ប៉ុងស្វង់ ដោយសារគាត់នេះបានមកផ្តល់សក្ខីកម្មនៅតុលាការយើងនេះ។ នៅសវនាការថ្ងៃទី១០ មេសា, ឯកសារ E1/179.1 មុនម៉ោង០៩:១៥នាទីបន្តិចសំណួរដែលគេចោទសួរទៅលោក ប៉ុងស្វង់ នេះ។ មុនឆ្នាំ១៩៧៥ហ្នឹងលោក ប៉ុងស្វង់ រស់នៅប្រទេសកម្ពុជាពីរបីឆ្នាំដែរ អ៊ីចឹងសំណួរដែលសួរទៅគាត់ដូចតទៅនេះ។ តើជនភៀសខ្លួននេះ ធ្លាប់បាននិយាយប្រាប់លោកថាពួកគេរត់ភៀសសឹក ឬក៏អ្នកខ្លះនោះរត់គេពីការប្រព្រឹត្តអាក្រក់ពីសំណាក់ពួកខ្មែរក្រហម? ចម្លើយរបស់គាត់ដូចតទៅនេះ "មានស្ថានភាពទាំងពីរ ម្យ៉ាងគឺមានអ្នកដែលខ្លាចសង្គ្រាមដូចគេនិយាយជាភាសាខ្មែរថា នៅពេលដែលដំរីវ៉ៃគ្នាស្រមោចងាប់។ ចាប់ពីឆ្នាំ១៩៧៣មក មានមនុស្សជាច្រើនរត់គេចការទម្លាក់គ្រាប់បែកអាមេរិកាំង"។ សំណួរខ្ញុំ ដោយយោងទៅលើសក្ខីកម្មរបស់លោក ប៉ុងស្វង់ ដែលធ្លាប់ធ្វើការជាមួយជនភៀសខ្លួន អ៊ីចឹងដោយយោងតាមសក្ខីកម្មនេះមិនស៊ីសង្វាក់ជាមួយនឹងការសម្ភាសរបស់លោកដែលលោកបានសម្ភាសជនភៀសសឹកនៅទីក្រុងភ្នំពេញទេ។ តើលោកយល់ឃើញ

យ៉ាងម៉េចដែរ?

[១០:៤៧:០១]

**ឆះ** អត់ទេ អ្វីដែលខ្ញុំអាចជម្រាបបានគឺគាត់ជួបមនុស្សច្រើន។ ដូច្នេះហើយខ្ញុំគ្មានហេតុផលអីទៅចោទសួរ សួរឆ្ងល់អំពីសក្ខីកម្មរបស់ ប៉ុងសួង៍ នោះទេ។ ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់ថាគាត់និយាយអ្វីមានលក្ខណៈបែបណានោះទេ វាជាការពិតៗ គឺមានតែប៉ុណ្ណឹង។ ខ្ញុំមិនដែលនិយាយថា គ្មាននរណាម្នាក់រត់គេចពីការទម្លាក់គ្រាប់បែកនោះទេ ហើយខ្ញុំក៏មិនដែលនិយាយថា គ្រាប់បែកទម្លាក់នោះមិនបានធ្វើឱ្យស្លាប់មនុស្សនោះដែរ។ ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយគឺថា លោកស្រីយកល្អលោកស្រីគួរតែបញ្ឈប់ព្យាយាមចង់ឱ្យខ្ញុំនិយាយតាមអ្វីដែលលោកស្រីចង់បាន។ គួរតែបញ្ឈប់កុំឱ្យខ្ញុំធ្វើឱ្យខ្ញុំនិយាយកុហកនោះ។ គឺថាខ្ញុំគ្រាន់តែជួបមនុស្សប៉ុណ្ណោះនៅពេលនោះ ហើយប្រហែលជាក្រុមដែលមនុស្សដែលខ្ញុំជួបប្រហែលជាគេមិនខ្លាចការទម្លាក់គ្រាប់បែកទេ ប៉ុន្តែគេខ្លាចខ្មែរក្រហមខ្លាំងជាងមើលទៅ។ ប៉ុន្តែយ៉ាងណាក៏ដោយគឺវាគ្មានអីពាក់ព័ន្ធជាមួយខ្ញុំថាតើខ្ញុំយល់ស្រប ឬក៏មិនយល់ស្របជាមួយអ្នកដទៃនោះទេ។ ហើយខ្ញុំសោកស្ដាយដែលលោកស្រីបង្ខំឱ្យខ្ញុំធ្វើដូច្នេះ។

**សះ** នៅក្នុងដំណាក់កាលនីតិវិធីយើងនេះខ្ញុំសូមធ្វើការបំភ្លឺ។ ខ្ញុំមិនរំពឹងទុកអ្វីមួយនោះទេ។ ខ្ញុំមិនខកចិត្តអំពីអ្វីដែលលោកនិយាយអម្បាញ់មិញនេះទេ លោកជាសាក្សី លោកមានសិទ្ធិសេរីភាពក្នុងការនិយាយអ្វីដែលលោកចង់និយាយតាមការដឹងឮរបស់លោក។

[១០:៤៨:៤៧]

ឥឡូវនេះយើងនៅក្នុងតុលាការកំពុងកាត់ក្ដីរឿងព្រហ្មទណ្ឌ ហើយខ្ញុំមានសិទ្ធិបង្ហាញភស្តុតាងដែលមាននៅក្នុងសំណុំរឿងដើម្បីឱ្យលោកបញ្ចេញប្រតិកម្ម។ ជួនកាលខ្ញុំត្រូវបំភ្លឺទៅកាន់លោក ហើយអ៊ីចឹងខ្ញុំមិនមានបំណងឱ្យលោកនិយាយអ្វីដែលលោកមិនចង់និយាយនោះទេ។ អ៊ីចឹងដោយស្មោះត្រង់ ខ្ញុំគ្រាន់តែដាក់ជូនលោកនូវអ្វីដែលខ្ញុំបានដឹងឮដើម្បីឱ្យលោកបញ្ចេញប្រតិកម្ម។ អ៊ីចឹងបើតាមចម្លើយរបស់លោកថា ដែលលោកថាអម្បាញ់មិញថា ប្រហែលជាលោក ប៉ុងសួង៍ សម្ភាសគេច្រើនជាងលោកឬក៏យ៉ាងម៉េចនោះខ្ញុំមិនមានយោបល់អ្វីទេ។ ក៏ប៉ុន្តែខ្ញុំមិនមែននៅទីនេះដើម្បីឈ្លោះជាមួយលោកនោះទេ។ ខ្ញុំគ្រាន់តែមកនៅទីនេះដើម្បីសួរលោក ហើយដើម្បីប្រៀបធៀបចម្លើយអ្នកផ្សេងទៀត សាក្សីផ្សេងទៀតដែលមកផ្ដល់សក្ខីកម្មនៅទីនេះ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ជូនលោកយ៉ាងដូច្នេះ។

ដោយសារខ្ញុំមានឯកសារផ្សេងទៀតបង្ហាញជូនលោកដើម្បីឱ្យលោកអត្ថាធិប្បាយនោះ អ៊ីចឹង

សូមលោកយល់ឲ្យច្បាស់អំពីចេតនារបស់ខ្ញុំ។ ខ្ញុំគ្រាន់តែចង់ឲ្យលោកធ្វើការអត្ថាធិប្បាយមួយចំនួនតែប៉ុណ្ណឹងទេ។

[១០:៥០:១៧]

*(សម្រាករយៈពេលខ្លី)*

[១០:៥០:២៦]

**កញ្ញា អង់តា ហ្គីសសេ៖**

លោក ស្កេនប៊ឹក លោកស្ដាប់ការបកប្រែឮទេ? ហើយយើងអាចបន្តទៀតបានទេ?

**លោក ស៊ីដនី ស្កេនប៊ឹក៖**

ខ្ញុំគិតថាយើងគួរតែបន្តទៅមុខទៀត។

**ប្រធានអង្គជំនុំ៖**

សូមៗជម្រាបជូនលោកមេធាវី ហើយនិងលោក ស្កេនប៊ឹក ថានៅក្នុងកិច្ចពិភាក្សាដេញដោលនេះ ទី១ ក្នុងករណីដែលលោក ស្កេនប៊ឹក ស្ដាប់ទៅ ហើយលោកមិនដឹងរឿងរ៉ាវអីទេ គឺលោកឆ្លើយថាលោកមិនដឹងទេ គឺចប់ហើយណ៎ា នៅតបទៅនឹងសំណួរដែលសួរ ពីព្រោះអ្វីដែលមិនដឹងហ្នឹង គឺមិនអាចឆ្លើយថាដឹង ដោយភូតកុហក ឬក៏និយាយមិនពិតបានទេ។

[១០:៥១:១៥]

បញ្ហាទី២ មានបញ្ហាផ្នែកខាងបកប្រែភាសា ដោយសារមានការមិនទុកគម្លាតពេលវេលាសមស្របសម្រាប់ឲ្យអ្នកបកប្រែភាសា។ អ៊ីចឹងសូមទាំងមេធាវីការពារក្ដី លោកស្រីជាអ្នកសួរ ហើយនិងលោក ស្កេនប៊ឹក ដែលជាអ្នកឆ្លើយ សូមទុកគម្លាតពេលវេលាបន្តិចក្រោយពីបានសួរ និងក្រោយពីបានឆ្លើយដើម្បីឲ្យការបកប្រែភាសាហ្នឹងបានពេញលេញ បានល្អបាទ។

សូមអញ្ជើញបន្តទៀត!

**លោក ស៊ីដនី ស្កេនប៊ឹន៖**

សូមអរគុណលោកប្រធានដែលបានណែនាំមកខាងខ្ញុំ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក ស្កេនប៊ឹក ខ្ញុំសូមបន្ត។ ដើម្បីបញ្ចប់បញ្ហាទម្លាក់គ្រាប់បែកអាមេរិកាំងនេះ ទាក់ទងនឹងបរិមាណគ្រាប់បែកដែលទម្លាក់លើប្រទេសកម្ពុជាក្នុងជម្លោះសង្គ្រាមនៅប្រទេសកម្ពុជានេះ តើលោក

ចាំអំពីតួរលេខដែលគេមាននៅពេល -- នៅសម័យនុំងទេ ថាមានចំនួនប៉ុន្មានតោនដែរ ថាគេទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជានេះ?

[១០:៥២:៤៤]

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** ខ្ញុំចាំថាគេប្រើប្រាស់ខ្នាតតោន ហើយគេនិយាយថាចំនួនដែលទម្លាក់នៅស្រុកខ្មែរហ្នឹង គឺវាច្រើនជាងចំនួនគ្រាប់បែកដែលទម្លាក់នៅក្នុងសង្គ្រាមលោកលើកទី២នៅអាល្លឺម៉ង់ នៅអឺជាដើមទៀត។ ខ្ញុំមិនមែន ខ្ញុំមិនជំទាស់ ឬក៏ខ្ញុំមិននិយាយថាខុសនោះទេ ខ្ញុំគិតថាប្រហែលជាអាចពិត។

**ស៖** នៅក្នុងការជម្រះសេចក្ដីយើងនេះ ខ្ញុំសូមដកស្រង់មួយ -- យើងបានស្ដាប់ចម្លើយរបស់លោក ហ្វីលីព ស្បូត ដែលសរសេរសៀវភៅមួយអត្ថមួយជូនតុលាការ គឺឯកសារ E3/9។ ខ្ញុំសូមដកស្រង់មួយពីសៀវភៅនេះ ERN ជាភាសាបារាំងគឺ 00639734 ហើយនិងបន្តទំព័របន្ទាប់មកទៀតបារាំង 00639735, ជាភាសាអង់គ្លេសគឺទំព័រ ERN 00396416។ អ្នកជំនាញនេះ សរសេរនៅក្នុងសៀវភៅគាត់ទាក់ទងទៅនឹងបរិមាណគ្រាប់បែកទម្លាក់នៅប្រទេសកម្ពុជាមានដូចតទៅនេះ៖

"នៅក្នុងសង្គ្រាមវៀតណាម នៅចុងទំព័រនៅក្នុងសង្គ្រាមវៀតណាម សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកលើឥណ្ឌូចិនបីដង លើសប្រទេសៗដែលទទួលការទម្លាក់គ្រាប់បែកនៅសង្គ្រាមលោកលើកទី២។ បរិមាណគ្រាប់បែកនេះវាបីដងលើសការទម្លាក់គ្រាប់បែកនៅប្រទេសជប៉ុន ដែលមានគ្រាប់បែកបែកបរិមាណូផងដែរ។ សំណួរទី១ អម្បាញ់មិញលោកបាននិយាយថា បាននិយាយអំពីបរិមាណដែលគេទម្លាក់នៅក្នុងសង្គ្រាមលោកលើកទី២ តើការប្រៀបធៀបរវាងគ្រាប់បែកដែលទម្លាក់នៅប្រទេសជប៉ុនហើយនិងនៅកម្ពុជាយើងនេះ វាស៊ីសង្វាក់ហ្នឹងប្រភពព័ត៌មានដែលលោកបានទទួលបានដែរឬទេ?

[១០:៥៥:៣៦]

**ឆ៖** ខ្ញុំមិនមានជំនាញផ្នែកនេះទេ ប៉ុន្តែខ្ញុំមិនមានហេតុផលអ្វីទៅជំទាស់ទៅនឹងចំនួនទាំងអស់នោះទេ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមចូលទៅប្រធានបទមួយទៀត។ ខ្ញុំសូមអភ័យទោសអំមិញនេះខ្ញុំភ្លេចដកស្រង់ទំព័របន្ទាប់អម្បាញ់មិញដែលខ្ញុំឱ្យលេខ ERN ហើយៗ គឺថាទំព័រជាអង់គ្លេសទំព័រដូចគ្នាជាភាសាបារាំងគឺលេខ ERN ដោយលេខ736 អ្នកជំនាញបានលើកឡើងដូចតទៅនេះ អំពីផលវិបាកនៃការទម្លាក់គ្រាប់បែកទាំងអស់នេះ។ គាត់និយាយថា "ផលវិបាកហ្នឹងវាទ្វេដងមានមនុស្សរាប់ម៉ឺននាក់ដែល

រត់ចូលមកទីក្រុងភ្នំពេញដែលគាត់រស់នៅលំបាកវេទនា ទុរ្ភិក្សប្រជាជនទីក្រុងភ្នំពេញដែលមានអង្កាល់នោះមាន៦សែននាក់។ ឥឡូវនេះឡើងទៅដល់ចូលខ្ទង់លាន ហើយនិងមកដល់ខ្ទង់២លានកន្លះនៅឆ្នាំ១៩៧៥។ ទាក់ទងទៅនឹងតួលេខ២លានកន្លះនៅឆ្នាំ១៩៧៥នេះ តើតួលេខនេះវាស៊ីសង្វាក់នឹងតួលេខដែលលោកទទួលបានទាក់ទងនឹងជនភៀសសឹកដែលឬទេ?

**អ្នកបកប្រែ៖**

សូមអភ័យទោសលោកប្រធាន មានបញ្ហាបច្ចេកទេសពី--

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលបច្ចេកទេសជាមួយនឹងទីក្រុងញូវយ៉ក!

[១០:៥៧:៣២]

*(មានបញ្ហាបច្ចេកទេស)*

[១១:០៣:៤០]

**ប្រធានអង្គជំនុំ៖**

សូមលោកស្រីមេធាវីអញ្ជើញត បាទ!

អញ្ជើញត! ហើយសំណួរចុងក្រោយអំមិញ សូមសួរទៅសាក្សីសាជាថ្មីឡើងវិញ ពីព្រោះទំនងជាអាចភ្លេចហើយ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក ស្កេនបឹក សូមអភ័យទោស។ តើលោកស្តាប់ឮការបកប្រែឃ្លា ដែលខ្ញុំបានអានជូនលោកស្តាប់អម្បាញ់មិញនេះទេ គឺជាសៀវភៅរបស់លោក ហ្វីលីព ស្សូត?

**លោក ស៊ីដនី ស្កេនប៊ឹក៖**

**ឆ៖** បាទ លោកស្រីអាចផ្តល់លេខឲ្យខ្ញុំបានទេ។ សូមផ្តល់លេខម្តងទៀតមក។

**ស៖** ខ្ញុំសូមអានឃ្លាចុងក្រោយ៖ “ប្រជាជនភ្នំពេញដែលមាន៦៥០.០០០នាក់ នៅក្នុងពេលរដ្ឋប្រហារបានកើនឡើងទៅដល់ចំនួនជាង១លាន ហើយរហូតទៅដល់ឆ្នាំ៧៥ គឺថាកើនឡើងរហូតទៅដល់២,៥លានឯណោះ”។ ដូច្នេះ ខ្ញុំចង់ដឹងថាចំនួន១លាន នៅចុងឆ្នាំ៧០ ហើយនិង២,៥លាន នៅឆ្នាំ៧៥នោះវាត្រូវគ្នាតួលេខដែលលោកទទួលបាន ឬក៏លោកបានកត់សម្គាល់ឃើញនៅពេលនោះទេ គឺនៅក្នុងទីក្រុងភ្នំពេញ?

**ផ៖** ចម្លើយរបស់ខ្ញុំ គឺផ្តាច់នៅពេលយើងឈប់សម្រាកនោះ គឺចម្លើយរបស់ខ្ញុំទៅនឹងសំណួរលោកស្រី។ ខ្ញុំក៏បានសាកល្បងត្រួតពិនិត្យទៅលើតួលេខទាំងអស់ហ្នឹង គឺពីម្សិលមិញ ប្រហែលនៅថ្ងៃមុនៗផង គឺ១លានមុនដំបូង ហើយច្រើនឡើងៗរហូតទៅដល់២លានក្នុងពេលជម្លៀសចេញពីទីក្រុង។

**សៈ** សូមអរគុណ។ ចំណុចមួយដែលខ្ញុំចង់សុំឱ្យលោកបញ្ជាក់ លោកបានឆ្លើយថា លោកអត់មានទំនាក់ទំនងផ្ទាល់អ្វីជាមួយនឹងពួកខ្មែរក្រហម ឬសមាជិករណសិរ្សរួបរួមជាតិកម្ពុជានោះទេ។ ក៏ប៉ុន្តែលោកមានមនុស្សកណ្តាល គឺមានអន្តរការី។ តើលោកអាចបញ្ជាក់បានទេថា អ្នកណាជាអន្តរការីរបស់លោកនោះ ហើយដែលជាអ្នកប្រាប់ប្រភពដល់លោកនោះ?

[១១:០៦:៣៤]

**ផ៖** ខ្ញុំគិតថា លោកស្រីធ្វើឱ្យសក្ខីកម្មរបស់ខ្ញុំច្របូកច្របល់ បើលោកនិយាយអំពីមេដឹកនាំខ្មែរក្រហម មេដឹកនាំអង្គការខ្មែរក្រហម ខ្ញុំមិនដែលបាននិយាយអ្នកណាម្នាក់ក្នុងចំណោមពួកមេដឹកនាំទេ។ ខ្ញុំមិនដែលបានបញ្ជូនអ្នកណាម្នាក់ឱ្យទៅនិយាយជាមួយពួកគេទេ។ បើបញ្ជូនទៅ គេសម្លាប់ចោលហើយ។ ខ្ញុំគិតថាខ្ញុំមិនបានអាចឆ្លើយទៅនឹងសំណួរលោកស្រីបានទេ ពីព្រោះលោកស្រីកំពុងតែរៀបចំសំណួរថាម៉េចបានខ្ញុំធ្វើរបាយការណ៍ខ្ញុំបែបហ្នឹង។

**សៈ** លោក ស្តេនប៊ីក ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែហើយ។ អម្បាញ់មិញនេះនៅពេលដែលខ្ញុំនិយាយអំពីវិធីសាស្ត្រការងាររបស់លោកនោះ ខ្ញុំសួរលោកថានៅក្នុងក្របខ័ណ្ឌការងាររបស់លោកនៅទីក្រុងភ្នំពេញ តើលោកមានទំនាក់ទំនងជាមួយនឹងអ្នកដែលសមានចិត្តជាមួយខ្មែរក្រហម ឬក៏ខ្មែរក្រហមផ្ទាល់នៅទីក្រុងភ្នំពេញដែរឬទេ? ហើយខ្ញុំបានសួរលោកទៀតថា តើលោកធ្លាប់បានជជែកពិភាក្សា ឬក៏សំណេះសំណាលគ្នាជាមួយនឹងអ្នកដែលមានសមានចិត្ត ឬក៏សមាជិករណសិរ្សរួបរួមជាតិកម្ពុជាដែរឬទេ? ពេលនោះខ្ញុំជឿថា លោកឆ្លើយថា លោកខ្លួនឯងផ្ទាល់នោះ លោកអត់មានទំនាក់ទំនងអ្វីជាមួយនឹងអ្នកទាំងអស់នោះទេ។ ក៏ប៉ុន្តែមានអ្នកផ្សេងទៀតដែលជាអន្តរការីនោះផ្តល់ព័ត៌មានឱ្យលោកពាក់ព័ន្ធទៅនឹងបញ្ហានេះ។ ដូច្នេះ តើខ្ញុំយល់ចម្លើយរបស់លោកច្បាស់ ឬក៏ខ្ញុំយល់ខុសទេ?

[១១:០៨:១៦]

**ផ៖** វាជាប្រព័ន្ធផ្សព្វផ្សាយ គឺថាលោកស្រីគិតថាវាពាក់ព័ន្ធទៅនឹងជំនឿនយោបាយក្តី អីក្តីលើកលែងតែគេវិលមកវិញមានព័ត៌មានថ្មីៗគួរឱ្យភ្ញាក់ផ្អើល ខ្ញុំនឹងមិនសរសេរវានោះទេ។ ខ្ញុំអាចជម្រាបជូនបានប៉ុណ្ណឹង។

**ស៖** បើអ៊ីចឹងខ្ញុំចូលទៅប្រធានបទផ្សេងតែម្តងទៅ។ មុននឹងចូលទៅដល់ឃ្លាមួយចំនួនអំពីសៀវភៅកំណត់ហេតុកម្ពុជារបស់លោកនោះ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ភាគីកាលពីប៉ុន្មានថ្ងៃនេះ គឺថាលោកបានឆ្លើយថា នៅចន្លោះពេលដែលលោកទៅដល់ស្ថានទូតបារាំង គឺនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ គឺនៅល្ងាចបន្ទាប់ពីទៅសណ្ឋាគាររួចហើយ និងនៅថ្ងៃទី៣០ មេសា ដែលជាថ្ងៃចេញក្បួនឡានដំបូងពីស្ថានទូតទៅកាន់ប្រទេសថៃនោះ គឺថាលោកអត់បានចាកចេញពីបរិវេណស្ថានទូតបារាំងទេ ដូច្នេះតើខ្ញុំស្តាប់អ៊ីចឹងត្រឹមត្រូវដែរឬទេលោក?

[១១:០៩:៥១]

**ឆ៖** ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងម្តង ចេញខាងក្រោយស្ថានទូត ដោយសារវាអត់មានទឹក។ មានទឹកច្រើនណាស់នៅខាងក្រោយស្ថានទូតប្រហែលជាចម្ងាយ១០០យ៉ាត។ ខ្ញុំក៏សម្រេចចិត្តដើរទៅដើម្បីលាងខ្លួន ហើយខ្ញុំមានជួបកងទ័ពនៅទីនោះ គេសួរសំណួរមួយចំនួនមកកាន់យើង គឺថាពួកគេមិនជាឃោរឃៅ ឬគំរាមកំហែងអីទេ។ ម្នាក់ក្នុងចំណោមទាំងអស់នុំងនិយាយបែបអវិជ្ជមានថា "គួរតែកាត់ -- អ្នកគួរតែកាត់សក់ចេញទៅ!"។ ប៉ុណ្ណឹងធ្វើឲ្យខ្ញុំភ័យខ្លាច ពីព្រោះគេមានកាន់កាំភ្លើង យើងខ្ញុំក៏ត្រឡប់មកចូលស្ថានទូតវិញ។ បាទ ហ្នឹងគឺជាតែមួយលើកទេ ដែលខ្ញុំដើរចេញទៅក្រៅស្ថានទូត។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់របស់លោក។ ខ្ញុំនឹងធ្វើតាមលំដាប់កាលប្បវត្តិនៃឃ្លាដែលខ្ញុំចង់ឲ្យលោកផ្តល់មតិយោបល់ពាក់ព័ន្ធទៅនឹងសៀវភៅកំណត់ហេតុរបស់លោក។ គឺឯកសារ E236/1/4/3.1។ ឃ្លាទី១ ដែលខ្ញុំចង់អានឲ្យលោកស្តាប់នោះ គឺនៅទំព័រទី៤ គឺកថាខណ្ឌចុងក្រោយ។ ERN ជាភាសាអង់គ្លេស គឺមានតែមួយទេ គឺ00898212 ឯកសារនេះមានតែមួយភាសាទេ។ គឺនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៥ នៅក្នុងសៀវភៅនោះលោកនិយាយអំពីការចល័តទ័ព គឺកងអនុសេនាធំមួយរបស់អាមេរិក ហើយក៏មានទាហាន លន់ នល់ ផងដែរ។ ដូច្នេះ ខ្ញុំសូមអភ័យទោសផង ព្រោះខ្ញុំត្រូវដកស្រង់ឃ្លានេះជាភាសាអង់គ្លេសហើយព្រោះអត់មានបកជាភាសាបារាំងទេ គឺឃ្លាចុងក្រោយ៖

[១១:១២:៣៧]

"មានកន្លែងមួយនៅតាមផ្លូវ គឺពួកបះបោរ គឺកំពុងតែបញ្ជូនកាំភ្លើង ហើយនិងម៉ាកជេ ពួកគេជិះមកកាន់ពោធិ៍ចិនតុងនៅក្នុងហ្ស៊ីបមួយ ហើយគេមានស្ពាយកាំភ្លើង។ ទាហានរដ្ឋាភិបាលនៅប៉ុស្តិ៍យាមហ្នឹង ហាក់បីដូចមិនមានចំណាប់អារម្មណ៍អីចំពោះការរំខានយាយីរបស់ខ្លាំងនោះ។ ពួកគេមានមោទនភាពចង់ឲ្យពួកយើងចេញទៅក្នុងវាលស្រែ ហើយបើមិនអ៊ីចឹងទេគេនិងកាត់ថ្លើមរបស់យើង។ បើសិន

ណាជាគេស៊ីថ្នើមរបស់ខ្មាំង គេនឹងមានកម្លាំង ហើយខ្លាំងក្លា ហើយនឹងអាចនាំមកនូវជោគសំណាង ជោគវាសនាផង។ យើងក៏ចាប់ផ្តើមមើលទៅលើសាកសពទាំងនុំង។ ប៉ុន្តែអាហ្នឹងគឺថាមានការផ្ទុះអាវុធ ហើយយើងក៏ចូលទៅក្នុងត្រង់សេ នៅក្នុងបន្ទាយនោះទៅ។ តាមដែល *(ឮមិនច្បាស់)* ណែនាំគឺដោយ យើងគ្មានការផ្តោតអារម្មណ៍មកលើការធ្វើដំណើររបស់យើង។ គាត់ចង្អុលបង្ហាញនូវជុំវិញហ្នឹងទៅ លើផ្នាំង ចាន គឺថា ឥឡូវនេះ លើផ្នាំងចានដែលចម្អិនថ្លើមហ្នឹង គឺថាថ្លើមឆ្អិនហើយ ដល់ពេលល្មមអាច ស៊ីបានហើយ”។ សូមបញ្ចប់ការដកស្រង់។

[១១:១៥:០៩]

កាលពីម្សិលមិញ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់លោក កូប៉េ ជាភាសាអង់គ្លេស ខ្ញុំមិនដឹងថា បកទៅត្រូវអត់ទេ ចំពោះរបស់ខ្ញុំហ្នឹង គឺថា១ នៅក្នុងក្របខ័ណ្ឌនៃហេតុការណ៍នោះ អ្វីដែល លោកបានឆ្លើយទៅនឹងលោក កូប៉េ នោះ ដែលគេនិយាយអំពីសង្គ្រាមហ្នឹង គេថាសង្គ្រាមដូចសត្វធាតុ ដែលថា មានមនុស្សស្លាប់ គឺថាមិនធម្មតាទេ តែសង្គ្រាមវាតែងតែមានអ៊ីចឹងហើយ វាមានស៊ីវិល មាន ទាហានស្លាប់អ៊ីចឹងឯង។ អ៊ីចឹងនេះជាអ្វីដែលលោកបានឆ្លើយអ៊ីចឹងមែនទេ?

**ធ៖** ខ្ញុំមិនគិតអំពីបញ្ហាតថភាពនៃសង្គ្រាមនោះទេ។ ខ្ញុំបានប្រតិកម្មជាអវិជ្ជមាននៅពេលដែល ខ្ញុំនិយាយថា ពេលមានសង្គ្រាមគេប្រព្រឹត្តមកលើមនុស្សដូចសត្វធាតុអ៊ីចឹង។ គឺថាភាគីមួយត្រូវតែ សម្លាប់ភាគីម្ខាងទៀត។ ហើយមានអ្នកដែលឆ្លងកាត់សង្គ្រាមយ៉ាងដូច្នេះ តែងបាត់បង់នូវកាយសម្បទា សមត្ថភាពកាយសម្បទាណាមួយហើយ តាមបទពិសោធន៍ខ្ញុំគឺថា សង្គ្រាមតិចតួចណាស់ដែលអាចដោះ ស្រាយបញ្ហាអីបាននោះ។ ពីព្រោះម្នាក់១ចង់ឈ្នះ។ ខាងរដ្ឋាភិបាលគឺថាមានឥរិយាបថមួយតាមរបៀប ខាងទាហានរដ្ឋាភិបាលត្រូវមានឥរិយាបថ ហើយថាតើមានភាពការប្រព្រឹត្តមកដូចសត្វធាតុអ៊ីចឹង។ ពិត ណាស់ជាមាន។ ខ្ញុំសរសេរអំពីសង្គ្រាម ព្រោះខ្ញុំចង់ពន្យល់ដល់ប្រជាជនដែលមិនស្ថិតនៅក្នុងសង្គ្រាម ដែលមិនឆ្លងកាត់សង្គ្រាម ហើយដែលមិនមានគេហៅថាទាហានខាងគូបក្ខដិបក្ខខាងខ្មាំងនោះចូលមក ទីធ្លាខាងក្រោយរបស់ខ្លួន។ ខ្ញុំចង់ឲ្យពួកគេដឹងដើម្បីកុំឲ្យគេមានការអន្ទះអន្ទែងចង់ធ្វើសង្គ្រាម ចង់បាន សង្គ្រាម។

[១១:១៧:០១]

**ស៖** ចំណុចមួយទៀតដែលខ្ញុំចង់ពិភាក្សាជាមួយលោក ហើយលោកក៏បានពិភាក្សានូវចំណុច នេះរួចហើយនៅក្នុងសៀវភៅកំណត់ហេតុកម្ពុជារបស់លោក ហើយនៅក្នុងអត្ថបទសារព័ត៌មានមួយ

ចំនួន។ ដូច្នេះ ខ្ញុំសូមចាប់ផ្តើមតាមរយៈអត្ថបទមួយដែលលោកសរសេរនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ៧៥ ឯកសារនេះគឺមានលេខ E236/1/4/3.1, ជាភាសាបារាំងគឺ 00789697, នេះជាអត្ថបទរបស់កាសែតញ៉ូវយ៉កថាមស៍ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ៧៥។ គឺថានៅកម្ពុជាគឺមានការប្រារព្ធខួបនៃការសម្លាប់។ ERN ជាភាសាអង់គ្លេស 00773772, ជាភាសាខ្មែរ00775776, ឃ្លានេះគឺខ្ញុំចង់ដកស្រង់ជាភាសាបារាំង គឺប្រហែលជានៅពាក់កណ្តាលទំព័រ។ ខ្ញុំសូមចាប់ផ្តើមការដកស្រង់។ នៅក្នុងអត្ថបទនេះលោកឡើងអំពីការពុករលួយនៅក្នុងរដ្ឋាភិបាល លន់ នល់ នៅសម័យនោះ។ លោកបាននិយាយថា "ផ្អាកប្រសិទ្ធភាពនៃរដ្ឋាភិបាល ហើយនិងការពុករលួយនៅក្នុងរដ្ឋាភិបាលនោះធ្វើឲ្យប្រជាជនមានការខឹងសម្បា។ និស្សិតនិងគ្រូមួយចំនួនបានរត់ចូលព្រៃដើម្បីចូលរួមជាមួយនឹងពួកបះបោរ។ ដូច្នេះពួកគេចូលធ្វើកងទ័ព គេធ្វើយ៉ាងម៉េចដើម្បីគេចចេញពីរបប លន់ នល់។ អ្នកណាដែលមានមធ្យោបាយគឺគេធ្វើទៅតាមមធ្យោបាយរបស់ខ្លួន។ ក៏ប៉ុន្តែពេលខ្លះទៅត្រូវបាននគរបាល ឬក៏យោធារបស់ លន់នល់ ចាប់ខ្លួនបានហើយនាំទៅជំរំឃុំខ្លួន"។ ហើយខ្ញុំសូមបន្ត ខ្ញុំរំលងបន្តិចខ្ញុំបន្តទៅទៀត លោកនិយាយអំពីមូលហេតុនៃការពុករលួយ, អំពើពុករលួយគឺជាមូលហេតុដ៏សំខាន់នៃការធ្លាក់ចុះរបស់រដ្ឋាភិបាល។

[១១:១៩:៤៨]

ខ្ញុំសូមដកស្រង់នូវឃ្លាមួយនៃសៀវភៅរបស់លោក គឺនៅក្នុងឯកសារ E236/1/4/3.1 គឺនៅថ្ងៃទី០៧ ខែមករា, ទំព័រ៥, ERN គឺ 00898213។ គឺនៅឃ្លាទី៣ លោកលើក លោករាយការណ៍អំពីសម្តីរបស់ឯកអគ្គរដ្ឋទូតមួយរូប។ ខ្ញុំសូមអានជាភាសាអង់គ្លេស ។

*(អានជាភាសាអង់គ្លេស៖)* "ឯកអគ្គរដ្ឋទូតបស្ចិមប្រទេសនោះបានធ្វើការចុះធ្វើទស្សនៈ -- បានពិនិត្យអំពីអំពើពុករលួយនៅក្នុងរដ្ឋាភិបាល លន់ នល់ ដែលជាបញ្ហាកើតមានឡើងយ៉ាងយូរ ធ្វើឲ្យអាមេរិកាំងមានការខ្មាស់អៀនយ៉ាងខ្លាំង។ ហើយដែលជាពិសេសអ្នកធ្វើសង្គ្រាម គឺថាទទួលបានផលប្រយោជន៍ពីអំពើពុករលួយហ្នឹង"។ សូមបញ្ចប់ការដកស្រង់។

[១១:២១:១៤]

នៅពេលដែលខ្ញុំលើកឃ្លាពីរមក ខ្ញុំមានសំណួរដូចតទៅនេះ៖ នៅរយៈកាលនោះ តាមរយៈប្រភពការទូតអាមេរិក តើលោកដឹងទេថាអំពោះពុករលួយនេះ គឺថាមានដើមកំណើតមកពីការលំបាករបស់រដ្ឋាភិបាលអាមេរិកក្នុងការបោះឆ្នោត ដើម្បីផ្តល់ជំនួយថ្មីទៅដល់រដ្ឋាភិបាល លន់ នល់ នៅសម័យនុំង។ ដោយសារតែអត់មានជំនួយពីអាមេរិកអ៊ីចឹងហើយបានជាមានអំពើពុករលួយ។ អ៊ីចឹងគឺលោកចង់មាន

ន័យអ៊ីចឹងទេនៅក្នុងប្រភពរបស់លោកនោះ?

**ឆៈ** ចម្លើយរបស់ខ្ញុំទៅនឹង គឺថាមានខ្ញុំមានរឿងរ៉ាវដែលខ្ញុំបានសរសេររឿងរ៉ាវជាច្រើនអំពីបញ្ហាពុករលួយ។ យើងខ្ញុំ គឺលោកស្រីអានស្អីដែលខ្ញុំសរសេរ ខ្ញុំគិតថាវាពិត។ អ៊ីចឹងខ្ញុំគ្មានអីបន្ថែមទៀតទេ។ លោកស្រីអាចមើលទំព័រពីអំពីពុករលួយហ្នឹងទៅ។ បាទ គឺថាមានអំពើពុករលួយមែន។ បាទ អស់ហើយ ខ្ញុំមិនមានអីបន្ថែមទៀតទេ។

[១១:២២:៥៤]

**សៈ** ខ្ញុំមិនដឹងថាតើគេបកប្រែសំណួររបស់ខ្ញុំច្បាស់ឬក៏អត់ទេ។ សំណួរខ្ញុំគឺចង់សួរពាក់ព័ន្ធទៅនឹងអំពើពុករលួយដែលលោកបានលើកឡើងពីប្រភពការទូតអាមេរិក។ អ៊ីចឹងខ្ញុំចង់ដឹងថា តើអំពើពុករលួយនេះ គឺថាបណ្តាលមកពីអាមេរិកបដិសេធមិនបោះឆ្នោតផ្តល់ជំនួយទៅឲ្យរដ្ឋាភិបាល លន់ នល់ តើអ៊ីចឹងមែនទេ? បើសិនជាលោកមិនដឹង ឆ្លើយថាមិនដឹងទៅ។ នេះជាសំណួររបស់ខ្ញុំ។

**ឆៈ** ខ្ញុំគិតថា ហេតុផលទៅលើចំណុចនេះគឺថាម្នាក់ៗគឺថាធុញទ្រាន់ទៅនឹងសង្គ្រាមនៅវៀត-ណាម នៅអាស៊ីអាគ្នេយ៍ ចង់ឲ្យចប់សង្គ្រាមឆាប់ៗ។ នេះគឺជាជំនឿរបស់ខ្ញុំ មិនមានអង្គហេតុអីបង្ហាញនោះទេ។

**សៈ** ខ្ញុំសូមនិយាយអំពីឃ្លាមួយទៀតនៅក្នុងសៀវភៅរបស់លោកគឺទំព័រ៤១, ERN ជាភាសាអង់គ្លេស 00898249។ គឺនៅឃ្លាទី៣ ដែលខ្ញុំអានជាភាសាបារាំង នៅក្នុងឃ្លាមុននោះ លោកលើកឡើងអំពីបញ្ហារអត់ឃ្លាននៅទីក្រុងភ្នំពេញ ហើយលោកបានសរសេរថា ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសដូចតទៅ៖

[១១:២៤:៣៨]

"ប៉ុន្តែមិនមែនប្រជាជនកម្ពុជាទាំងអស់ស្រេកឃ្លាននោះទេ។ កងទ័ពគឺថានៅវាយប៉ាយតាមផ្លូវនៅភាគខាងត្បូងនៃទីក្រុង ហើយមាននៅអាងហែលទឹកនៅសណ្ឋាគារឡឺភ្នំ។ ខ្ញុំបានសួរគាត់អំពីការបាញ់កាំភ្លើងធំដោយទាហានដែល -- ដោយ -- មកលើទាហានខ្លួនឯងបាញ់កាំភ្លើងធំ។ លោកវរសេនីយ៍ឯកហ្នឹងគឺថា ជាការឲ្យសោកស្តាយណាស់ ប៉ុន្តែគាត់បានបន្ថែមថា គឺថាបញ្ហាការបាញ់ច្រឡំគ្នាឯងអ៊ីចឹងមកចំកន្លែងគ្នាឯងក្នុងសង្គ្រាម ធម្មតាទេ គឺថាការបាញ់បែបនេះគឺថាបានសម្លាប់មនុស្សយ៉ាងហោចណាស់ ២០នាក់ បានធ្វើឲ្យអ្នកដទៃទៀតមានការជ្រួលច្របល់មែនទែន"។ សូមបញ្ចប់ការដកស្រង់។

[១១:២៥:៣៤]

សំណួរខ្ញុំគឺវាមានទំនាក់ទំនងទៅនឹងឃ្លានៃអត្ថបទដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ គឺថា ពាក់ព័ន្ធទៅនឹងការបាក់ទឹកចិត្ត គឺការរំសាយកងទ័ពរបស់ លន់ នល់។ តើនេះជាចំណុចដែលលោកបាន កត់សម្គាល់ឃើញនៅសម័យនោះ គឺមានន័យថាទោះបីជារដ្ឋាភិ -- ទោះបីជាអ្នកការទូតអាមេរិកចង់ឲ្យ គេបន្តជំនួយទៅដល់រដ្ឋាភិបាល លន់ នល់ ក៏ដោយនោះ ក៏ការរំសាយយោធាហ្នឹងគឺថាវាធ្វើឲ្យស្ថានភាព ប្រយុទ្ធហ្នឹងមានការលំបាក ពីព្រោះអត់សូវមានទ័ព។ តើនេះជាចំណុចដែលលោកកត់សម្គាល់ឃើញទេ នៅពេលនោះ?

**ឆ៖** ខ្ញុំបានកត់សម្គាល់ -- ខ្ញុំបាននិយាយចំណុចនេះពីមុនរួចមកហើយ។ ខ្ញុំមិនមានអ្វីត្រូវឆ្លើយ ទៀតទេ ខ្ញុំបានសរសេរ ខ្ញុំបាននិយាយអំពីអំពើពុករលួយ ខ្ញុំបានសរសេរនិយាយអំពីការបណ្ដុះបណ្ដាល ទាហានទាំងអស់នេះ ខ្ញុំសរសេរអំពីរឿងរ៉ាវអំពីទាហានកុមារ។ ខ្ញុំមិនមានការបកស្រាយអីទៅលើការ សរសេររបស់ខ្ញុំទេ នេះការសរសេរនេះបាន ខ្ញុំមិនអាចយល់អំពីចិត្តរបស់អ្នកដទៃបានទេ។ បាទ សាធារណជនអាចអាននៅចំណុចត្រង់នេះបាន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ឥឡូវនេះខ្ញុំមើលទៅឃើញថាម៉ោងដប់មួយកន្លះហើយខ្ញុំជិតបញ្ចប់ហើយ ដូច្នេះ ខ្ញុំសូមការសន្ដោសប្រណីពីអង្គជំនុំជម្រះ ដោយសារតែមានបញ្ហាបច្ចេកទេសអម្បាញ់មិញហ្នឹង សូមឲ្យ អង្គជំនុំជម្រះមេត្តាឲ្យខ្ញុំបន្តបញ្ចប់សំណួររបស់ខ្ញុំ។ ខ្ញុំត្រូវការប្រហែលជាមិនដល់១០នាទីទេលោកប្រធាន។ គឺថាប្រហែលជា៥ ទៅ ១០នាទីទេ សូមឲ្យលោកប្រធានមេត្តាបន្ថែមពេលវេលា។ បាទ ខ្ញុំឃើញថា លោកប្រធានងក់ក្បាលហើយ អ៊ីចឹងខ្ញុំបន្តទៅទៀត។

[១១:២៨:០១]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ចំណុចមួយដែលខ្ញុំចង់លើកឡើងនៅក្នុងសៀវភៅកំណត់ហេតុកម្ពុជារបស់លោក ហើយ ដែលមាននៅក្នុងអត្ថបទដែលខ្ញុំអានកាលពីមុននេះដែរ។ ឯកសារ E331/13.14, ERN ជាភាសាបារាំង 007896197, ជាភាសាខ្មែរ 00775767, ERN ជាភាសាអង់គ្លេស 00772772។ នៅក្នុងអត្ថបទ ដែលលោកបានលើកឡើងនោះគឺថា "ក្នុងអំឡុងពេល៥ឆ្នាំនៃសង្គ្រាម វ៉ាស៊ីនតោន បានប្រកាសជំនួយ ដល់កម្ពុជាសម្រាប់ជួយដល់ផ្នែកយោធា ហើយមានបន្តិចបន្តួចទេសម្រាប់គម្រោងមនុស្សធម៌សម្រាប់

ជនភៀសខ្លួននោះ"។ ដូច្នេះ ខ្ញុំចង់ដឹងថាតើលោកបានប្រភពមកពីណាពាក់ព័ន្ធនឹងតួលេខនៃជំនួសនេះ ដែលថា ផ្តល់ទៅឲ្យកងទ័ពនុ៎ងគឺថាច្រើន តែផ្នែកមនុស្សធម៌ហ្នឹងគឺថាតិចតួចទេ?

**លោក ស៊ីដនី ស្កេកប៊ឺក៖**

**ឆ៖** តាមដែលខ្ញុំចាំ ខ្ញុំគិតថាតួលេខនេះបានមកពីរដ្ឋាភិបាល។ ទោះបីជាតួលេខនេះគឺត្រូវបានបោះពុម្ពផ្សាយនៅវ៉ាស៊ីនតោនក្តី ឬក៏ស្ថានទូតឲ្យមកខ្ញុំៗមិនចាំច្បាស់ថាអ្នកណាឲ្យតួលេខនេះមកខ្ញុំនោះទេ។

[១១:២៩:៥៥]

**ស៖** ឥឡូវនេះខ្ញុំចូលទៅឃ្លារបស់លោកនៅក្នុងសៀវភៅដែលនិយាយពាក់ព័ន្ធទៅនឹងចំណុចនេះដែរ គឺទំព័រ៧ នៃសៀវភៅកំណត់ហេតុកម្ពុជារបស់លោក។ ERN គឺ 00898215។ គឺថ្ងៃ១១ ខែមករា ឃ្លាចុងក្រោយ លោកបានសរសេរដូចតទៅ។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។

*(អានជាភាសាអង់គ្លេស៖)* "គ្រាប់ខ្លះត្រូវបានទម្លាក់ដោយអាមេរិកាំង គឺមិនមែន -- នេះគឺសម្រាប់កងទ័ព មិនមែនសម្រាប់ ជនស៊ីវិលទេ"។

ខ្ញុំក៏សូមដកស្រង់ឃ្លាមួយទៀតផងដែរ ដែលនៅទំព័រ១៨ នៃសៀវភៅកំណត់ហេតុកម្ពុជារបស់លោក។ ERN គឺ 00898226។ គឺថ្ងៃទី២៧ ខែកុម្ភៈ, ឃ្លាទី១, "ការផ្តល់សម្ភារៈផ្គត់ផ្គង់តាមយន្តហោះគឺថាត្រូវបានពង្រីកជាម្តងទៀតហើយ គឺចាប់ផ្តើមនៅថ្ងៃនេះ។ យន្តហោះ គឺថាបាននាំយកនូវ ដឹកជញ្ជូនអង្ករ។ ឯឥឡូវនេះ គឺថាមានការកផ្តល់នូវគ្រាប់រំសេវ ប្រេងឥន្ធនៈ ប៉ុន្តែមិនមានស្បៀងអាហារទេ"។

ដោយសារតែខ្ញុំមានពេលវេលាខ្លីនោះ ខ្ញុំចង់ដឹងថា តើលោកចាំអំពីឃ្លានេះដែរឬទេ? ហើយខ្ញុំចង់ដឹងថា តើលោកដឹងមកពីណាថាទាល់ទេចាប់ផ្តើមពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ៧៥នោះ គឺថាតាមរយៈផ្លូវអាកាសនោះ គេបានបញ្ជូនស្រូវអង្ករមកឲ្យប្រជាជន គឺមិនមែនសម្រាប់យោធាទេ គឺមានឲ្យផ្តល់ទៅប្រជាជនផងដែរ តើលោកនៅចាំឃ្លាដែលលោកសរសេរនេះទេ? បើមិនចាំទេ ខ្ញុំនឹងចូលទៅចំណុចមួយផ្សេងទៀត។

[១១:៣១:៥៥]

**ឆ៖** បាទ ខ្ញុំនៅចាំ។

**ស៖** ចំណុចមួយទៀត ដែលលោកសរសេរនៅក្នុងសៀវភៅកំណត់ហេតុកម្ពុជារបស់លោក។ លោក ស្កេនប៊ឺក តើអំមិញនេះ ខ្ញុំសួរកាត់លោក ឬក៏យ៉ាងម៉េច លោក ស្កេនប៊ឺក?

**ឆ៖** លោកស្រីសួរម៉េច?

**ស៖** ចាស អំមិញនេះ ខ្ញុំគិតថា លោកចង់ឆ្លើយតប តែអត់អីទេ។ កាលពីម្សិលមិញនោះ លោកបានពិភាក្សាជាមួយនឹងមេធាវី កូប៉េ ពាក់ព័ន្ធទៅនឹងការទម្លាក់គ្រាប់បែករបស់ទាហាន លន់ នល់ ហើយលោកក៏បានរៀបរាប់អំពីជំនួយយោធាផងដែរ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ចំណុចមួយពាក់ព័ន្ធទៅនឹងព័ត៌-មាននេះ។ នៅក្នុងសៀវភៅកំណត់ហេតុកម្ពុជារបស់លោក គឺទំព័រ១៩, ERN ជាភាសាអង់គ្លេស 00898227។ លោកបានលើកឡើងអំពីគណៈប្រតិភូនៃសមាជិកព្រឹទ្ធសភាអាមេរិក គឺនៅថ្ងៃទី០១ ខែមីនា។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស គឺថ្ងៃទី០១ ខែមីនា ហើយឃ្លាទី១៖

[១១:៣៣:៣៦]

*(អានជាភាសាអង់គ្លេស៖)* "ប្រតិភូនៃព្រឹទ្ធសភាប្រាំមួយនាក់បានហោះហើរមកភ្នំពេញ ដើម្បីមកពិនិត្យមើលសំណើសុំផ្តល់យោធាជាបន្ទាន់។ ដើម្បីសម្រេចអំពីជោគវាសនារបស់ប្រទេសកម្ពុជា"។

ខ្ញុំសូមរំលងទៅឃ្លាទី៣ លោកបានរៀបរាប់ដូចតទៅ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។ គឺលោកនិយាយអំពីកិច្ចសន្ទនាមួយ។ ខ្ញុំសូមអានជាភាសាអង់គ្លេស។

*(អានជាភាសាអង់គ្លេស៖)* "មើលទៅក្រៅបង្អួចមើលឃើញផ្សែងទេ គឺថាមានសង្គ្រាម។ វីល្លៀមសិន បានមើលទៅ គឺថាមើលទៅដូចជាមានអ្វីមួយកើតឡើងហើយ វីល្លៀមសិន បាននិយាយថា តើមានភ្លើងនៅហ្នឹង តើត្រូវធ្វើម៉េច? គឺថាមានអ្នកសារព័ត៌មាននៅលើយន្តហោះហ្នឹង បានឆ្លើយតប គឺថារដ្ឋាភិបាល គឺភាគីដទៃទៀតមិនមានអ្វីនោះទេ"។ សូមបញ្ចប់ការដកស្រង់។

[១១:៣៤:៥៥]

សំណួរខ្ញុំគឺខ្ញុំចង់ដឹងថា តើអ្នកសារព័ត៌មានដែលលោកបានលើកឡើងនៅក្នុងឃ្លារបស់ -- សូមសួរអីចេះសិន តើនៅពេលនុ៎ង គឺថាលោកមានវត្តមានទេ ឬក៏កន្លែងហ្នឹងគេប្រាប់លោកទេ លោកអត់មានវត្តមាននៅពេលសន្ទនានុ៎ងទេ?

**ឆ៖** ខ្ញុំមានវត្តមាន។

**ស៖** តើអ្នកសារព័ត៌មានដែលប្រាប់ថា ខ្មែរក្រហមមិនមានកម្លាំងទ័ពអាកាសហ្នឹងតើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមទោសអ្នកណា? អ្នកណានិយាយថា ខ្ញុំអត់បានឮទេពាក់កណ្តាលឃ្លាដំបូង។

**ស៖** សូមអភ័យទោស ខ្ញុំសួរថា មនុស្សដែលរៀបរាប់នេះដែលប្រាប់លោកថា ខ្មែរក្រហមនោះ

អត់មានកងកម្លាំងទ័ពអាកាសទេ អ៊ីចឹងតាមលោកដឹងតើត្រឹមត្រូវទេដែលអ្នកកាសែតហ្នឹងប្រាប់លោកថាខ្មែរក្រហមអត់មានកងទ័ពអាកាសនោះ?

**ឆ៖** បាទត្រឹមត្រូវហើយ។

**ស៖** ចំណុចចុងក្រោយលោក ស្ពេនប៊ឹក ខ្ញុំនឹងបញ្ចប់ហើយគឺទំព័រ៩១ នៃសៀវភៅកំណត់ហេតុកម្ពុជារបស់លោក។ ដែលក្នុងនោះគឺថា លោកបានឆ្លើយជាមួយនឹងលោក កូប៉េ រួចទៅហើយ ក៏ប៉ុន្តែខ្ញុំចង់បានការបញ្ជាក់គឺលេខ ERN គឺ 00898299។ គឺនៅឃ្លាទីពីរ។ ដូច្នេះខ្ញុំសូមអានជាភាសាអង់គ្លេសទៀតហើយ។

[១១:៣៦:៤០]

*(អានភាសាអង់គ្លេស៖)* “នៅម៉ោងដប់កន្លះព្រឹក ហង់រី បេកយ៉រ ហើយនិងអ្នករស់រានមានជីវិតមួយចំនួនទៀតបានមកដល់ស្ថានទូត។ អ្នកជំនាញបារាំងម្នាក់នៅក្រសួងព័ត៌មាន គាត់ធ្វើការ បន្តធ្វើការងាររបស់គាត់រហូតដល់គាត់មកស្ថានទូតដែរ”។ សូមបញ្ចប់ការដកស្រង់។

ក្នុងទំព័រនេះគឺថាអត់មានថ្ងៃទី២១ ខែមេសា ទេ។ ក៏ប៉ុន្តែក្នុងនុំងគឺថាថ្ងៃហ្នឹងគឺថ្ងៃ២១ មេសាហើយ។ ប្រសិនបើខ្ញុំយល់ការសរសេររបស់លោកនោះ គឺថាលោកហ្នឹងទៅដល់ក្រសួងឃោសនាការនៅថ្ងៃទី២១ មេសា។ អ៊ីចឹងខ្ញុំចង់ដឹងថាតើគាត់មកដល់ ឬក៏គាត់នៅទីនុំងរហូតដល់ថ្ងៃហ្នឹង? លោកបានឆ្លើយថា លោកបានទៅនៅក្រសួងឃោសនាការនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥មួយភ្លែត។ អ៊ីចឹងនៅថ្ងៃនុំង ខ្ញុំចង់ដឹងថាពេលដែលលោកទៅមួយភ្លែតហ្នឹងលោកមានបានជួបលោក ហង់រី បេកយ៉រទេ?

**ឆ៖** ខ្ញុំអត់ដែលស្គាល់សហការីមួយនេះទេ ខ្ញុំមិនដឹងថា ខ្ញុំបានជួបឬអត់ទេនៅពេលនុំង។

**ស៖** ឃ្លាហ្នឹង គឺជាឃ្លានៅក្នុងសៀវភៅរបស់លោក គឺម៉ោងដប់កន្លះព្រឹក។ អ៊ីចឹងមានន័យថាកន្លែងហ្នឹង គេរៀបរាប់ប្រាប់លោក ឬក៏យ៉ាងម៉េច ព្រោះថាលោកបានសរសេរនៅក្នុងសៀវភៅលោកច្បាស់ណាស់។ អ៊ីចឹងមានន័យថាគេប្រាប់លោកទេ អ៊ីចឹងអំមិញនេះមានន័យថាលោកប្រាប់ថាលោកអត់ស្គាល់ទេ មែនទេ?

**ឆ៖** ខ្ញុំកំពុងតែអាន ដើម្បីពិនិត្យមើលឲ្យឃើញច្បាស់នោះ។ ហ្នឹងគឺនៅពេលដែលគាត់មកស្ថានទូតហើយ ខ្ញុំមិនដឹងថាគាត់បានចូលជាមួយនឹងហ្វូងមនុស្ស ឬក៏អត់ទេនៅថ្ងៃនុំង។ គឺនៅថ្ងៃដែលខ្មែរក្រហមចូលមកក្នុងទីក្រុង។ ប៉ុន្តែគឺខ្ញុំបានជួបគាត់ បានជួប បេកយ៉រ នេះនៅស្ថានទូត។

[១១:៣៩:២៨]

**ស៖** នៅទំព័រដដែលគឺឃ្លាបន្ទាប់មកទៀត។ ជាភាសាអង់គ្លេសដដែល។

*(អានភាសាអង់គ្លេស៖)* "បេកឃ័រ មានរឿងដែលគួរឲ្យចាប់អារម្មណ៍ទៅប្រាប់គាត់និយាយថា ខៀវ សំផន មេដឹកនាំខ្មែរក្រហមកំពូលមិនទាន់មកដល់ភ្នំពេញនៅឡើយទេ"។ សូមបញ្ចប់ការដកស្រង់។

ខ្ញុំចង់ដឹងថាសម្ដីដែលនិយាយហ្នឹងគឺថាលោកមានវត្តមានផ្ទាល់ទេនៅពេលដែលគាត់និយាយហ្នឹង ឬក៏គេប្រាប់លោកទេអំពីសម្ដីហ្នឹងនោះ?

**ឆ៖** ពួកយើងខ្ញុំមួយក្រុមបាននិយាយជាមួយនឹងគាត់ព្រោះគាត់ជាអ្នកសារព័ត៌មានដែរ។ គាត់នៅខាងក្រៅស្ថានទូតប្រហែលជាគាត់អាចឃើញដឹងរឿងអីដែលយើងអត់បានដឹង អ៊ីចឹងហើយបានយើងសួរទៅគាត់ច្រើនសំណួរដែរ។ គាត់ប្រាប់នូវអ្វីដែលគាត់បានដឹង អ្វីដែលបានឃើញបាទ ហ្នឹងគឺបានព័ត៌មាននេះ របៀបនេះឯង។

[១១:៤០:៣៥]

**ស៖** នៅឃ្លាខាងក្រោមមកទៀតមកគឺសំណួរចុងក្រោយមែនទែនហើយសូមដកស្រង់ជាភាសាអង់គ្លេស។

*(អានជាភាសាអង់គ្លេស៖)*"និយាយថានៅពេលដែលយើងទៅជួបជុំគ្នាហើយមានការឆក់លួចគ្រាន់តែមិនមានការប្រយុទ្ធគ្នារវាងជំនាន់ខ្មែរក្រហមនោះទេ ក៏ប៉ុន្តែប្រជាជនកម្ពុជាខ្លះបានប្រាប់គាត់ថាមានការដុតកន្លែងខ្លះនៅ ផ្នែកខ្លះនៃទីក្រុង"។ សូមបញ្ចប់ការដកស្រង់។

នេះជាចំណុចដែលគេនិយាយប្រាប់លោកនៅពេលសន្ទនាគ្នានោះមែនទេ? អ៊ីចឹងខ្ញុំចង់សួរលោកថា លោកឆ្លើយថានៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥ លោកបានដើរទៅមើលទីក្រុងបន្តិចហើយលោកមិនមានអារម្មណ៍ថាមានក្រុម ឬក៏ភាគីផ្សេងៗគ្នាទេ។ លោកបានឆ្លើយថា លោកឃើញមានខ្មែរក្រហមដែល-- តើលោកមានទំនាក់ទំនងឬក៏មានពិភាក្សាគ្នាជាមួយនឹងអ្នកដែលមកពេលក្រោយទៀត ហើយដែលគេអាចប្រាប់លោកថាអាចមានភាពខុសគ្នារវាងក្រុមផ្សេងៗរបស់ពួកខ្មែរក្រហមហ្នឹង អាចមានថាក្រុមខ្លះមានបទពិសោធន៍ច្រើនជាង ក្រុមខ្លះអាចមានបទពិសោធន៍តិចជាងអ៊ីចឹង។

[១១:៤២:២៧]

**ឆ៖** ខ្ញុំអត់ចាំទេថា ក្រុមប្រយុទ្ធគ្នាហ្នឹងជាអ្នកណានោះទេ ប៉ុន្តែអ្វីដែលខ្ញុំដឹងនោះគឺថា នៅផ្នែកមួយនៃថ្ងៃនោះក្រុមក្មេងៗដែលស្លៀកពាក់ខោអាវខ្មៅបានមកដើរមកសំដៅយើងថាគេគាំទ្រខ្មែរក្រហមហើយពួកគេចង់ចូលរួមជាមួយនឹងជ័យជម្នះនេះ។ យើងបាននិយាយជាមួយមេរបស់ពួកគេ។ គាត់មិន

ដែលបានជួបឧត្តមសេនីយ៍ខ្មែរក្រហមអីទេ។ គាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងក្នុងការដែលថាចង់ឲ្យចូលរួមជាមួយជ័យជម្នះនេះ។ ហើយថ្ងៃក្រោយមកទៀតគាត់ហើយនិងសហការី គឺថាបាត់ខ្លួនអស់ទៅ ខ្ញុំមិនដឹងថាមានអ្វីកើតឡើងចំពោះពួកគេនោះទេ។

**ស៖** លោកប្រធានខ្ញុំអស់សំណួរហើយ។ សូមអរគុណដែលលោកប្រធានអនុញ្ញាតឲ្យខ្ញុំសួរបន្ត។ ហើយលោក ស្កេនប៊ឹក សូមអរគុណចំពោះការអត់ធ្មត់ឆ្លើយនឹងសំណួររបស់ខ្ញុំ។ ខ្ញុំដឹងថានៅប្រទេសលោកហ្នឹងគឺយប់ជ្រៅណាស់ហើយ។

**ឆ៖** សូមអរគុណលោកស្រី។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្កេនប៊ឹក។ ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ លោកអាចត្រឡប់ទៅកាន់លំនៅដ្ឋានវិញបានហើយលោក ស្កេនប៊ឹក។ ហើយអង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមផ្តល់សក្ខីកម្មឲ្យដល់អង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេលបីពេលនៃថ្ងៃសវនាការកន្លងទៅនេះ ប្រកបដោយភាពអំណត់អត់ធ្មត់ និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពនិងលទ្ធភាពរបស់ខ្លួន។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ សូមជូនពរលោក ស្កេនប៊ឹក ឲ្យជួបតែសំណាងល្អ មានសុខភាពល្អ ហើយបានសេចក្តីសុខសេចក្តីចំរើន។ ហើយសូមជម្រាបលាលោក ស្កេនប៊ឹក។

[១១:៤៥:០៤]

**លោក ស៊ីដនី ស្កេនប៊ឹក៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក លោកស្រីទាំងអស់ដែលបានផ្តល់ឱកាសមកខ្ញុំដើម្បីពិភាក្សាអំពីប្រធានបទទាំងអស់នេះ ហើយនិងបានចូលរួមនៅក្នុងដំណើរការនីតិវិធីនេះ។ ខ្ញុំគិតថាវាជាការជំនុំជម្រះដ៏សំខាន់ហើយល្អមួយ។ ហើយខ្ញុំគិតថាការដំណើរការនីតិវិធី គឺមានលក្ខណៈជាដំណើរការបែបអាជីពតុលាការដ៏ល្អគួរឲ្យកោតសរសើរ ហើយសូមថ្លែងអំណរគុណសាជាថ្មីចំពោះលោក លោកស្រីចៅក្រម និងជាពិសេសលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ជម្រាបលា។

បាទឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ

តទៅរហូតដល់ម៉ោងមួយរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-665 ហើយសូមភាគីនៃរឿងក្តី បុគ្គលិកគាំទ្រដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមបន្ទប់សវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលឲ្យមុនម៉ោងមួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤៦នាទី ដល់ម៉ោង ១៣:០២ នាទី)*

[១៣:០២:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅរសៀលនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-665។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:០៣:៤៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកឈ្មោះអី?

**លោក សុខ រឿ៖**

**ឆ៖** បាទ សូមគោរពលោកប្រធាន ខ្ញុំឈ្មោះ សុខ រឿ។

**ស៖** បាទ អរគុណលោក សុខ រឿ។ តើលោកមានអាយុប៉ុន្មាន?

**ឆ៖** បាទ ខ្ញុំអាយុ៥២ឆ្នាំ។

**ស៖** អរគុណ។ ហើយទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** បាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យបាទ។

**ស៖** ហើយសព្វថ្ងៃនេះលោកប្រកបមុខរបរអ្វី?

**ឆ៖** បាទ ធ្វើស្រែចម្ការ។

**ស៖** អរគុណ ហើយឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី? ម្ដាយបង្កើតរបសលោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះ ដយ – យ៉ា ដយ, ម្ដាយបង្កើតឈ្មោះ យ៉ា ញ៉ៀវ។

[១៣:០៤:៥៧]

**ស៖** អរគុណ។ ហើយប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ ប្រពន្ធឈ្មោះ ទុយ មួយ។ បាទ មានកូនពីរនាក់។

**ស៖** អរគុណ។ ហើយលោក សុខ រឿ តាមរបាយការណ៍ក្រឡាបញ្ជីសវនាការ កាលពីព្រឹកថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ បានរាយការណ៍ថា តាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលត្រូវទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ ហើយក៏មិនជាប់ញាតិលោហិត ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ដែរ។ ហើយថាលោកបានស្បថនៅចំពោះអ្នកតាដំបងដែកនៅ អ.វ.ត.ក នេះរួចហើយ កាលពីថ្ងៃទី០៥ មិថុនា។ តើពិតមែនដែរទេ?

[១៣:០៥:៥៨]

**ឆ៖** បាទ ពិត។

**ស៖** បាទ អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះអង្គជំនុំជម្រះ។ លោក សុខ រឿ ក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនេះលោកអាចបដិសេធក្នុងការឆ្លើយតបនឹងសំណួរ ឬការសុំឱ្យលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយក្នុងការអនុវត្តសិទ្ធិនេះគឺអង្គជំនុំជម្រះបាន -- តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានចាត់តាំងមេធាវីប្រឹក្សាសាក្សីមួយរូប គឺលោក មឿន សុវណ្ណ ដែលអង្គុយក្បែរលោកនេះសម្រាប់ជាសាក្សីប្រឹក្សាក្នុងករណីដែលមានសំណួរណាដែល

ទំនងជាដាក់ពិរុទ្ធភាព ដាក់បន្ទុក ដាក់ពិរុទ្ធភាពលើខ្លួនលោក។ លោកពិភាក្សាថា តើលោកគួរឆ្លើយ ឬក៏មិនឆ្លើយ។

អំពីករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ ហើយត្រូវតែឆ្លើយតែការណ៍ដែលពិត ដែលលោកបានឃើញ បានដឹង បានឮ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

លោក សុខ រឿ តើលោកមានដែលធ្លាប់ផ្តល់សក្ខីកម្ម ឬក៏បទសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេប៉ុន្មានឆ្នាំកន្លងមកនេះ ពីឆ្នាំ២០០៨, ២០០៩, ២០១០ កន្លងមកនេះ?

[១៣:០៧:៤៥]

**ឆ៖** បាទ អត់មាន មានតែលោកមេធាវីរបស់លោក ខៀវ សំផន មកជួបខ្ញុំ។

**ស៖** បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

ហើយក្នុងការសួរដេញដោលស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន តាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយអង្គជំនុំជម្រះសូមជម្រាបថា មេធាវីទាំងពីរក្រុមគឺមេធាវីការពារក្តី ខៀវ សំផន និងរួមទាំងមេធាវីការពារក្តីលោក នួន ជា មានរយៈពេល១៥នាទីក្នុងការសួរសាក្សីនេះ។ ហើយមុននឹងតាំងសំណួរសូមឆ្លើយផង ថាតើការបែងចែកពេលវេលាជាមួយនឹងមេធាវីការពារក្តីលោក នួន ជា យ៉ាងម៉េចពីព្រោះការតាំងសំណួរនេះមានរយៈពេលដាច់ពីគ្នា គឺដំបូង ហើយនិងចុងក្រោយ ទើបយើងប្រគល់ឲ្យជូនទៅមេធាវីការពារក្តីលោក នួន ជា។

[១៣:០៨:៤៤]

**លោក គង់ សំអុន៖**

បាទ លោកប្រធាន សូមបញ្ជាក់អំមិញលោកប្រធានមានប្រសាសន៍ថា ប្រគល់ពេលវេលា ១៥នាទី ឬក៏១ម៉ោង១៥នាទី?

**ប្រធានអង្គជំនុំ៖**

១ម៉ោង១៥នាទី យើងបានជម្រាបជូនដំណឹងរួចហើយ ប៉ុន្តែសរុបហ្នឹង១ម៉ោង១៥នាទី។ ប៉ុនសូមបញ្ជាក់ផងព្រោះ១ម៉ោង១៥នាទីហ្នឹងពីរក្រុម ប៉ុន្តែក្រុមនេះយើងមិនធ្វើជាប់គ្នាទេ គឺធ្វើដាច់ពីគ្នា ពីព្រោះមេធាវីការពារក្តី នួន ជា គាត់នឹងមានឱកាសចុងក្រោយគេបង្អស់នៃកិច្ចដំណើរការ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តាមសញ្ញារបស់ក្រុមមេធាវីលោក នួន ជា ប្រហែលជាគាត់មិនត្រូវពេលវេលាទេ។ អ៊ីចឹងខាងខ្ញុំនឹងចាត់ចែងពេលវេលានេះតាមការគួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

[១៣:០៩:២៦]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក សុខ រឿ ខ្ញុំមេធាវី គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន ហើយតទៅនេះខ្ញុំមានសំណួរមួយចំនួនដើម្បីជម្រាបសួរលោក ដើម្បីឲ្យលោកជួយបញ្ជាក់ដល់អង្គជំនុំជម្រះពីបញ្ហាទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមាននៅក្នុងសំណុំរឿង០០២ ហើយជាពិសេសយើងក៏ចង់ឲ្យលោកបញ្ជាក់អំពីអត្តចរិតរបស់លោក ខៀវ សំផន ផងដែរ។ លោកស្តាប់ខ្ញុំបានទេ?

**លោក សុខ រឿ៖**

**ឆ៖** បាន១។

**ស៖** បាទ សូមអរគុណ។ តាមស្តាប់លោកមានប្រសាសន៍អម្បាញ់មិញ មានមេធាវីរបស់លោក ខៀវ សំផន ទៅជួបលោកនោះ លោកអាចបញ្ជាក់បានទេថា នៅពេលដែលក្រុមមេធាវីរបស់លោក ខៀវ សំផន ទៅជួបលោកនោះ?

**ឆ៖** បាទ ភ្លេចថ្ងៃ ប្រហែលជា១ឆ្នាំ ២ឆ្នាំហើយ បាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំបានស្តាប់ឈ្មោះរបស់លោកឪពុកម្តាយលោកអម្បាញ់មិញនេះ

តើលោកជាជនជាតិភាគតិច ហើយជាជនជាតិអីដែរទៅ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ បាន ខ្ញុំនៅជនជាតិភាគតិច ជាជនជាតិទំពួន បាទ នៅរតនគិរី។

[១៣:១១:០៦]

**ស៖** បាទ សូមអរគុណ។ លោកនៅរតនគិរីរហូតដល់ឆ្នាំណា ដែលលោកចេញមកភ្នំពេញ?

**ឆ៖** បាទ ខ្ញុំមកភ្នំពេញចុង៧៦ បាទ។

**ស៖** លោកមកភ្នំពេញពីរតនគិរីតែម្តង ឬមួយក៏លោកចូលទៅកន្លែងផ្សេងទៀតមុនចូលមកដល់ភ្នំពេញ?

**ឆ៖** បាទ ខ្ញុំនៅ ចេញពីស្រុកមក មកនៅតាមកងៗ ចុះតាមទន្លេសេសានមក មកនៅមន្ទីរ។ គេហៅថា មន្ទីរយោធាហ្នឹង នៅមន្ទីរ តាប៉ង់ ប៉ុន្តែនៅហ្នឹង១ខែ ប្រហែលជា២ខែ បានចុះបន្តមកទៀតនៅស្ទឹងត្រែងតែម្តង បាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការប្រើប្រាស់ភាសា តើលោកអាចស្តាប់ភាសាខ្មែរបានច្បាស់ទេ ពីឆ្នាំ១៩៧៥ ដល់១៩៧៩នោះ?

**ឆ៖** បាទ នៅពេលនោះ វាលំបាកដែរ ពីព្រោះត្រូវការរៀនអក្សរ រៀននិយាយផង បាទ។

**ស៖** បាទ សូមអរគុណ។ លោករៀនអក្សរ លោកនៅរៀននៅកន្លែងណា? ហើយរៀនបានប៉ុន្មានឆ្នាំដែរ? រៀនភាសាខ្មែរ ឬរៀនអក្សរអី? លោកបញ្ជាក់ផង។

**ឆ៖** បាទ ខ្ញុំរៀនភាសាខ្មែរ។ ពីព្រោះរៀនទៅ អត់មានសាលាទេ រៀននៅរបៀបថា នៅកន្លែងណា ឲ្យបងៗគាត់ចេះអីចឹង ចេះតែរៀនៗជាមួយគេទៅ។ បាទ នៅពេលវេលាដូចជាម៉ោង ផុតពីម៉ោងធ្វើការ ពេលល្ងាច ឬថ្ងៃត្រង់ បាទ ឆ្លៀតរៀន ពីព្រោះនិយាយទៅវាទាក់ទងភាសាហ្នឹង ការសរសេរខ្លះអីចឹងទៅ តិចតួចអីចឹង បាទ។

[១៣:១៣:១៥]

**ស៖** លោករៀនរបៀបនេះរយៈពេលប៉ុន្មានដែរ?

**ឆ៖** បាទ ពេលផ្លាស់កន្លែងម្តងៗ ឧបមាថា ខ្ញុំនៅចេញពីស្រុកខ្ញុំមក មកដល់នៅមន្ទីរយោធាចេញពីហ្នឹងមក មកនៅស្ទឹងត្រែង អង្កាល់ហ្នឹងបាន រៀនបានតិចតួចៗអ្វីដែលនេះចេះតែខំរៀនទៅ។ បើសៀវភៅនៅជាប់នឹងដៃ សៀវភៅ ក, ខ សៀវភៅអានសៀវភៅអីចឹងទៅណា។ ហើយមកបន្តនៅភ្នំពេញបានរៀនជាប់រហូត មកចេះតែរៀនដោយខ្លួនឯងអីចឹងទៅ មានគេចេះ ចេះបង្ហាត់តៗទៀត។

**ស៖** បាទ សូមអរគុណ។ លោកមានបានរៀនជាផ្លូវការទេ ឧទាហរណ៍ចូលរៀនថ្នាក់ទី១, ទី២, ទី៣ តាមរយៈសិក្សាធិការនៃសម័យណាមួយទេ?

**ឆ៖** រៀន វារៀនអត់ចប់ ជាលំដាប់លំដោយ។ ឧបមាថា នៅឯស្រុកពីសម័យនៅក្មេងៗពី៧២, ៧៣ រៀនដែរ រៀនតែក្នុងអំឡុងដែលពេលឈប់រវល់ការងារ រៀនទៅ។ ដល់រវល់ការងារតទៀត ជួយឪពុកម្តាយអីចឹងទៅកាលណោះ។ បាទ ម្យ៉ាងសង្គ្រាមផង។

**ស៖** បាទសូមអរគុណ។ ក្រៅពីការរៀនអក្សរ លោកមានរៀនបច្ចេកទេស ឬជំនាញអ្វីផ្សេងទៀតទេ?

[១៣:១៤:៥៨]

**ឆ៖** បាទ អត់បានរៀនទេ បាទ។

**ស៖** បាទសូមអរគុណ។ ទាក់ទងនឹងការងារវិញ តើលោកមានបទពិសោធន៍ការងារអ្វីខ្លះមុនឆ្នាំ ១៩៧៥?

**ឆ៖** បាទបទពិសោធន៍ការងារដូចជាមិនមានក្រៅពីការងារជុំវិញនៅកន្លែងបោសច្រាស ឬក៏ជម្រះស្មៅ ដាំបន្លែ រៀនសូត្រអីមានតែប៉ុណ្ណឹង អត់មានការងារអីបច្ចេកទេសអីផ្សេងទៀតទេ។

**ស៖** បាទសូមអរគុណ។ ទាក់ទងទៅនឹងបញ្ហាតស៊ូមុនឆ្នាំ១៩៧៥ តើលោកមានចូលរួមនៅក្នុងការតស៊ូនោះដែរទេ?

**ឆ៖** បាទសម័យនោះ គឺជានៅស្រុកលើ វាមានចលនាមួយដែលកុមារ គេប្រមូលកុមារទៅរបៀបថាពី៧២, ៧៣ ខ្ញុំចេញចូលៗ ជូនណាគេហៅទៅឃុំទៅអី ទៅធ្វើការ ធ្វើអីចឹងទៅ។ ទៅរបៀបថាមានណែរៀបចំធ្វើស្រែ ឬក៏ធ្វើចម្ការអីអីចឹង គេតែងតែហៅប្រមូលកុមារទៅអីចឹងដែរបាទ។

**ស៖** លោកអាចបញ្ជាក់ការងារច្បាស់លាស់ផ្សេងទៀតទេ មានទៀតទេ ក្រៅពីការធ្វើស្រែធ្វើចម្ការហ្នឹង?

**ឆ៖** បាទការងារវាតែប៉ុណ្ណឹង ព្រោះខ្ញុំរហូតមកដល់៧៣, ៧៤ ចូលរបៀបថាពាក់កណ្តាលកងចល័ត ពាក់កណ្តាលកុមារ។ កាលហ្នឹងនៅធ្វើការ ធ្វើតែស្រែទេ ភាគច្រើនខ្ញុំធ្វើស្រែជាប់ទៅមាត់ទន្លេមកខាងទន្លេសេសានអីចឹង មិនសូវដែលមកនៅផ្ទះទេបាទ។

**ស៖** បាទសូមអរគុណ។ នៅពេលដែលលោកចេញមកភ្នំពេញ តើលោកមានទំនាក់ទំនងអ្វីដែរហេតុអីបានជាលោកត្រូវបានគេនាំមកភ្នំពេញ?

[១៣:១៧:៣៨]

**ឆ៖** បាទកាលហ្នឹងភាគច្រើននេះ ទៅតាមរយៈដែលសម័យហ្នឹងគេហៅថាអង្គការជ្រើសរើស បាទគេថា ទី១ គឺពិនិត្យទៅលើប្រវត្តិរូប ពីការសកម្មភាពការងាររបស់យើងធ្វើការប្រចាំថ្ងៃ។ អ៊ីចឹងគេតែងតែជ្រើសរើសបន្តៗមកអ៊ីចឹងមក តាមឋានៈៗ។ បាទពីឃុំមក -- ពីភូមិទៅឃុំ ពីឃុំមកស្រុក ពីស្រុកមកខេត្ត។ បាទកាលណោះគេហៅថា ភូមិភាគ មកភូមិភាគអ៊ីចឹងទៅបាទ។

**ស៖** លោកអាចបញ្ជាក់ដោយសង្ខេបបានទេថា ប្រវត្តិរូបរបស់លោកយ៉ាងម៉េចដែរនៅពេលនោះ? ហើយប្រវត្តិការងាររបស់លោកយ៉ាងម៉េចដែរនៅពេលនោះបានជាគេត្រូវបានគេជ្រើសរើស?

**ឆ៖** បាទ ជាសកម្មភាពរបស់ខ្ញុំ រាល់ការងារគេឲ្យធ្វើ ខ្ញុំអត់ដែលប្រឆាំង អត់ដែលបដិសេធ អ៊ីចឹងចេះតែធ្វើ ឃើញគេធ្វើអីក៏ធ្វើ យើងអត់ដែលចេះត្អូញត្អែរអីយ៉ាងម៉េចទេ អត់។

**ស៖** បាទ ចុះមានបញ្ហាទាក់ទងរឿងវណ្ណភាពអីទេ?

**ឆ៖** បាទទាក់ទងវណ្ណភាព ពីព្រោះយើងជាកូនកសិករ វាអត់មានអី បញ្ហាអីលំបាកដល់គេទេ។ គឺយើងធ្វើការងារមក បានហូរហែមករហូតអ៊ីចឹងទៅ។

[១៣:១៩:១២]

**ស៖** បាទសូមអរគុណ។ នៅពេលដែលលោកចេញមកភ្នំពេញ តើដំបូងលោកទៅកន្លែងណា?

**ឆ៖** បាទ ចេញពីស្ទឹងត្រែងមកចូលមក កាលហ្នឹងគេដឹកកន្តុកកន្ទៀតមក រហូតមកចូលក្នុង ក-៨។ ក-១៨ មិនអ៊ីចឹងទេ ក-៨ -- ក-១៨ បាទចូលកន្លែងហ្នឹងហើយជាប់ជាមួយ ក-១ មន្ទីរហ្នឹងជាប់មួយ ក-១ តែម្តង នៅមាត់ទន្លេ។

**ស៖** លោកអាចបញ្ជាក់ម្តងទៀត ព្រោះអំមិញខ្ញុំស្តាប់ឮដូច ក-៨ផង, ក-១៨ផង។ លោកយកមួយណាពិតប្រាកដ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប រង់ចាំក្បាលមីក្រូហ្វូននៅមុខលោកហ្នឹងប្រតិបត្តិការសិន ដោយភ្លើងសញ្ញាណក្រហម សឹមលោកឆ្លើយ ទើបសំឡេងលោកចូលក្នុងប្រព័ន្ធចែកចាយសំឡេងភាគី សាធារណជន និងអ្នកបកប្រែនៅទីនេះដើម្បីបកប្រែភាសារបស់លោកទៅជាពីរភាសាផ្សេងទៀត។ មានភាសាបារាំង និងភាសាអង់គ្លេសដែលប្រើប្រាស់នៅ អ.វ.ត.ក យើងនេះ។

[១៣:២០:៣២]

**លោក គង់ សំអុន៖**

**ស៖** បាទ សូមលោកឆ្លើយថាក-៨ ឬក៏ ក-១៨?

**ឆ៖** បាទ ក-៨។

**ស៖** បើអ៊ីចឹង ក-៨ អ៊ីចឹង?

**ឆ៖** បាទ

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេ ថាក-៨ ហ្នឹងជាកន្លែងធ្វើអីដែរ?

**ឆ៖** បាទ កន្លែងដាំបន្លែ។

**ស៖** គេដាំបន្លែយកទៅណា លោកដឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ ខាងខ្ញុំគឺដាំ ហើយនិងអ្នកថែទាំស្រោចទឹកស្រោចអី អត់ដឹងថាគេយកទៅណាទេ ព្រោះយើងមិនដល់ត្រឹមរយៈមួយខែពីរខែអត់ដឹងអីទាំងអស់បាទ។

**ស៖** លោកស្គាល់អ្នកណាគេជាមេធំនៅក-៨ ហ្នឹងដែរទេ?

**ឆ៖** បាទ កាលហ្នឹងមានតែ ពូហាន។

**ស៖** គាត់មានឋានៈយ៉ាងដូចម្តេចកាលហ្នឹង? ឈ្មោះ ហានហ្នឹង?

**ឆ៖** បាទ ពេលនោះគឺថាគាត់ជាប្រធានមន្ទីរ។

**ស៖** បាទ សូមអរគុណ។ លោកនៅក្នុងក-៨ ហ្នឹងរយៈពេលប៉ុនណាដែរ?

**ឆ៖** ប្រហែលជាបួនខែ។

**ស៖** ហើយលោកចេញទៅណាទៀត?

**ឆ៖** ចេញមក ក-១។

**ស៖** ហេតុអីបានចេញដែរ?

**ឆ៖** ព្រោះខ្ញុំត្រូវដូរកន្លែង។

[១៣:២២:៥៤]

**ស៖** ចុះការងាររបស់លោកវិញមានដូរពីការទទួលខុសត្រូវដែរទេ?

**ឆ៖** បាទ ដូរ ព្រោះទៅកន្លែងថ្មីយើងត្រូវតែដូរ ប៉ុន្តែវាអត់ខុសគ្នាទេ វានៅតែជម្រះស្មៅដាំបន្លែដដែលដើម្បីផ្គត់ផ្គង់ក្នុងកន្លែង។

**ស៖** អ៊ីចឹងបានន័យថានៅ ក-១ ក៏លោកជាអ្នកដាំបន្លែជម្រះស្មៅដែរ?

**ឆ៖** បាទ ។

**ស៖** លោកដឹងថាអ្នកណាជាមេ ក-១ ទេនៅពេលហ្នឹង?

**ឆ៖** កន្លែងហ្នឹងដូចជាមិនសូវជាច្បាស់ ប៉ុន្តែឥឡូវ ពូឌីម គាត់ស្លាប់ហើយមានតែពូឌីម ទេដែលឧស្សាហ៍ជួបជាមួយពួកខ្ញុំពីព្រោះគាត់ជាជនជាតិខាងលើដែរ។

**ស៖** លោកនិយាយពីឈ្មោះ ឌីម។ ឌីមហ្នឹងជាអ្នកគ្រប់គ្រងលោកផ្ទាល់ ឬក៏ជាអ្នកធំជាងគេបង្អត់នៅក្នុង ក-១ ហ្នឹង?

[១៣:២៤:២៤]

**ឆ៖** បាទ មិនដឹងថាអ្នកណាធំជាងអ្នកណាព្រោះគាត់កាលណាមកទំនាក់ទំនងជាមួយពួកខ្ញុំពីព្រោះគាត់ចេះភាសាអ៊ីចឹងទៅ មកព្រោកប្រាជ្ញលេងជាមួយពួកខ្ញុំ។

**ស៖** បាទ សូមអរគុណ។ លោកនៅ ក-១ រយៈពេលប៉ុន្មានដែរ?

**ឆ៖** នៅប្រហែលជា ៦ខែ។

**ស៖** លោកដឹងថា ក-១ ជាកន្លែងអីទេ?

**ឆ៖** ព្រោះសួរបងៗគេមកមុន គេថាកន្លែងអ្នកដឹកនាំបាទ។

**ស៖** លោកដឹងថាកន្លែងហ្នឹងគេធ្វើអីខ្លះទេ?

**ឆ៖** អត់ដឹងដែរ ព្រោះគិតតែការងារខ្លួនឯងបាទ។

**ស៖** បាទ សូមអរគុណ។ ហើយអ្នកណានៅក្នុងក-១ ខ្លះ? អ្នកដឹកនាំណាដែលនៅក្នុងក-១ ខ្លះ?

**ឆ៖** ខ្ញុំអត់ដឹងទេ ព្រោះព្រឹកឡើងទៅធ្វើការបាត់។ អត់មានបានចាប់អារម្មណ៍រឿងអ្នកធំទេ។

**ស៖** លោកមានបានជួបអ្នកៗធំណាខ្លះនៅក្នុងក-១ ហ្នឹងដែរទេ នៅក្នុងរយៈពេលដែលលោកធ្វើការនៅក-១ ហ្នឹង?

[១៣:២៥:៥៨]

**ឆ៖** បាទ អត់ទេ។

**ស៖** អំមិញលោកនិយាយថា លោកនៅក-១ រយៈពេល៦ខែ។ អ៊ីចឹងចេញពីក-១ ទៅ លោកទៅណាទៀត?

**ឆ៖** បាទ ខ្ញុំទៅនៅក-៣បាទ។

**ស៖** លោកទៅនៅក-៣ តែម្តង ឬមួយក៏លោកមានទៅកន្លែងណាផ្សេងមុននឹងទៅក-៣ទេ?

**ឆ៖** អត់ទេ ទៅក-៣តែម្តងបាទ។

**ស៖** លោកអាចចាំពីអំឡុងឆ្នាំ ឬក៏ខែដែលលោកចេញទៅក-៣ទេ?

**ឆ៖** ខែ១០ៗ ចុង៧៧ ហ្នឹងហើយនៅ៧៨។

**ស៖** បាទ ខ្ញុំសូមបញ្ជាក់ ខែ១០/៧៧ ឬ៧៨?

**ឆ៖** ៧៨។

**ស៖** បាទ អ៊ីចឹងគឺខែ១០ ឆ្នាំ៧៨។ លោកនៅបានប៉ុន្មានខែនៅក្នុងក-៣ហ្នឹង?

[១៣:២៧:៣២]

**ឆ៖** នៅដូចរយៈពេលខ្លះទេ ពីព្រោះខែ៣ៗ ៧៩ ដល់បាត់ហើយ ចុង៧៨ វាដូចនៅខ្លីដែរ។

**ស៖** លោកនិយាយខែ៣ៗអីគេ លោកចង់និយាយពីថ្ងៃដែលរបបខ្មែរក្រហមដួលរំលំ? សូមលោកបញ្ជាក់ថារយៈពេលដែលលោកនៅប្រហែលប៉ុន្មានខែ ៣ខែ ឬមួយយ៉ាងម៉េច? សូមលោកជួយបញ្ជាក់។

**ឆ៖** ប្រហែលជាៗ៣ខែ ពីព្រោះខែថ្ងៃ០៣ ខែ០១ ចេញពីភ្នំពេញ។

**ស៖** បាទ សូមអរគុណ។ លោកធ្វើអីខ្លះនៅក-៣ហ្នឹង? អ៎!សូមទោស ហ្នឹងហើយនៅក-៣ហ្នឹង?

**ឆ៖** បាទ មកដល់ក-៣ ក៏នៅភាគច្រើនបោសច្រាសផ្ទះសម្បែង យាមច្រកចេញចូលខ្លះ។ ថ្ងៃត្រង់រៀន ល្ងាចរៀនអ៊ីចឹងទៅបាទ។

**ស៖** លោករៀនអីដែរ?

**ឆ៖** បាទ រៀនអក្សរខ្មែរ។

[១៣:២៨:៤៧]

**ស៖** អំមិញលោកឆ្លើយបញ្ជាក់ថាលោកជាអ្នកយាមផងដែរ។ លោកយាមយ៉ាងដូចម្តេចទៅលោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ យាមមាត់ទ្វារចេញចូល គ្រាន់តែជំនួសពេលបងៗគាត់បាយអ៊ីចឹងទៅ ខ្ញុំទៅយាមអ៊ីចឹងទៅ។

**ស៖** បាទ នៅក-៣ ហ្នឹងមានច្រកចេញចូលប៉ុន្មានដែរ?

**ឆ៖** បាទ ពីរមានទៅខាងកើតមួយ ខាងលិចមួយ។

**ស៖** ហើយលោកយាមនៅកន្លែងណា?

**ឆ៖** បាទ អត់ទៀង សម្រេចទៅលើគេចាត់តាំងបាទ។ ជួនខាងកើត ជួនខាងលិច។

**ស៖** បាទ លោកបានឃើញអីខ្លះនៅពេលដែលលោកយាម?

**ឆ៖** បាទ ពេលយាម ដូចមិនឃើញអី គ្រាន់តែជំនួសគេ ជួនណា១ម៉ោង ២ម៉ោងអ៊ីចឹងណ៎។ បាទ ជំនួសពេលបាយពេលអីអ៊ីចឹងទៅ។ ខ្ញុំអត់សូវបានយាមមួយថ្ងៃៗថ្ងៃទេ។

**ស៖** លោកអាចបញ្ជាក់ពីថ្នាក់ដឹកនាំ ជាមេរបស់លោកផ្ទាល់ ក៏ដូចជាមេធំ អ្នកគ្រប់គ្រងធំនៅក្នុងក-៣ តើលោកស្គាល់ទេ?

[១៣:៣០:៣៥]

**ឆ៖** បាទ ប្រធានមន្ទីរនៅក-៣ មានដែលចំណាំដែលជួបជាមួយខ្ញុំជាមួយអី ច្រើនតែខ្មោចពូឌីម គាត់ស្លាប់បាត់ហើយ។

**ស៖** គាត់ធ្វើអីដែរ?

**ឆ៖** ហ្នឹងជាប្រធាន របៀបថាការគ្រប់គ្រងនៅមន្ទីរហ្នឹង។

**ស៖** បាទ ចុះលោកមានដែលស្គាល់អ្នកដឹកនាំណាខ្លះនៅក្នុងក-៣ទេ?

**ឆ៖** បាទ ពេលនោះខ្ញុំអត់សូវបានគិតថាតើអ្នកណានេះទេ គិតតែភាគច្រើនទៅជួបតែគ្នាឯងបាទពូៗ ដែលមកពីខាងលើ ខ្ញុំជួប ប៉ុន្តែថាកន្លែងហ្នឹងអ្នកធំអីអ៊ីចឹងទៅ អត់ដែលជួបគេទេ អត់ទេបាទ។

**ស៖** លោកជួបគ្នារបស់លោកហ្នឹង លោកជួបអ្នកណាខ្លះ?

**ឆ៖** ដូចជាបងៗគេមុនខ្ញុំ១ខែ ២ខែអ៊ីចឹងទៅ ហើយសុទ្ធដូចខ្មោចពូ សាមី អីហ្នឹងឧស្សាហ៍ជួបអ៊ីចឹង។

**ស៖** លោកមានជួបអ្នកណាអ្នកនៅរស់រានមានជីវិតរហូតសព្វថ្ងៃហ្នឹងទេ?

**ឆ៖** ក្រុមភាគច្រើនពួកខ្ញុំមកពីលើ សឹងដូចអត់មានអ្នកណានៅសល់។ ឥឡូវអ្នកនៅសល់ហ្នឹងមិនជាគេនៅឯណា គេបែកបាក់គ្នាតាំងពី៧៩មក បាទអត់ដឹងកន្លែងគេនៅដែរ។

[១៣:៣២:២៦]

**ស៖** បាទ សូមអរគុណ។ តើលោកស្គាល់លោក ខៀវ សំផន ទេនៅពេលហ្នឹង?

**ឆ៖** បាទ ឮតែឈ្មោះ ប៉ុន្តែអត់បាននេះទេ ឃើញឮតែឈ្មោះ មិនបានជិតស្និទ្ធជាមួយគាត់ទេ។

**ស៖** ឮតែឈ្មោះហ្នឹងលោកឮយ៉ាងម៉េច? ឮតាមរយៈសារព័ត៌មាន ឬមួយលោកឮតាមរយៈ

មិត្តភក្តិ ឬមួយក៏ក្នុងលក្ខណៈបែបណា? សូមលោកជួយបញ្ជាក់។

**ឆ៖** បាទ ពួតាមគ្នាឯង។

**ស៖** អ្នកណាគេគ្នាឯងដែលលោកនិយាយហ្នឹង?

**ឆ៖** គឺខ្មោច សឿន, ធន, ខ្មោច បងយ៉ុន, នឿ ដែលនៅជាមួយគ្នា។

**ស៖** លោកដែលមានឱកាសនិយាយជាមួយលោក ខៀវ សំផន ដោយផ្ទាល់ទេនៅក្នុងពេលដែលលោកនៅក-៣?

[១៣:៣៣:៥៦]

**ឆ៖** បាទ អត់ទេ។

**ស៖** បាទ សូមអរគុណ។ លោកដឹងថាលោក ខៀវ សំផន នៅទីណាដែរទេ ពេលដែលលោកនៅក-៣ហ្នឹង?

**ឆ៖** ដឹងថាគាត់នៅក-៣ដែរ ប៉ុន្តែគ្រាន់ថាបែងចែកថាយើងៗគឺយើង គាត់គឺគាត់អ៊ីចឹងបាទ។

**ស៖** បាទ សូមអរគុណ។ មានអ្នកណាទៀតនៅក-៣ ដែលជាអ្នកដឹកនាំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ?

**ឆ៖** កាលនោះមិនសូវបានដឹងដែរហ្នឹង បាទអត់ដឹងផង។

**ស៖** ចុះលោកដឹងថាលោក ខៀវ សំផន ធ្វើអីទេក្នុងពេលដែលលោកនៅក្នុងក-៣នោះ?

**ឆ៖** បាទ អត់ដឹងទេ។

**ស៖** តើលោកដឹងពីការហូបចុករបស់លោក ខៀវ សំផន ដែរឬទេនៅពេលដែលលោកនៅក-៣?

**ឆ៖** បាទ អត់ដឹង។

[១៣:៣៥:៣៧]

**ស៖** បាទ សូមអរគុណ។ តើលោកដឹងពីការចេញចូលរបស់លោក ខៀវ សំផន ដែរទេ ដោយលោកបានបញ្ជាក់មុននេះថា ពេលខ្លះលោកជាអ្នកយាមនៅច្រកចេញចូលនៅក្នុងក-៣ នោះ?

**ឆ៖** បាទ អត់ទេ។

**ស៖** លោកដឹងថា លោក ខៀវ សំផន មានទំនាក់ទំនងជាមួយបុគ្គលិកដទៃទៀត ឬក៏អ្នកដែលជាមិត្តភក្តិរបស់លោកដទៃទៀតហ្នឹងដែរទេ?

**ឆ៖** បាទ កាលណោះអត់ដឹងទេ។

**ស៖** បាទ សូមអរគុណ។ តើលោកស្គាល់ ខៀវ សំផន ច្បាស់នៅពេលណា?

**ឆ៖** បាទ ខ្ញុំនៅជាប់ជាមួយគាត់នៅ ៨៩។

**ស៖** ពីឆ្នាំណាដល់ឆ្នាំណា? ពីឆ្នាំចាប់ផ្តើមបែករហូតដល់៨៩ ឬពីឆ្នាំ៨៩ រហូតមកដល់ក្រោយមកទៀត? សូមលោកជួយបញ្ជាក់។

**ឆ៖** បាទ ខ្ញុំនៅជាមួយគាត់ពីឆ្នាំ៨៩ មករហូតមកទល់នឹង ៩៦ អ៉ំ! ៩៥ បាទ ៩៥។

**ស៖** ពីឆ្នាំ៨៩ ដល់ឆ្នាំ៩៥ លោកធ្វើជាអីនៅពេលហ្នឹង?

**ឆ៖** កងការពាររបស់គាត់ នៅជាមួយគាត់តែម្តង។

**ស៖** តើលោកដឹងពីការងាររបស់គាត់យ៉ាងម៉េចខ្លះទេនៅពេលដែលលោកនៅជាមួយគាត់ហ្នឹង?

**ឆ៖** បាទ ឃើញតែគាត់ធ្វើការជាប់ជាមនុស្ស ជាអ្នកធ្វើការឬត់ចត់ហើយ ខ្ញុំការងារខ្ញុំ គាត់ការងាររបស់គាត់អ៊ីចឹងទៅបាទ។

**ស៖** លោកអាចបញ្ជាក់ពីទីកន្លែងបានទេលោកធ្វើការជាមួយគាត់ហ្នឹងនៅឆ្នាំ៨៩ហ្នឹងកន្លែងណា?

[១៣:៣៨:៤១]

**ឆ៖** បាទ អង្កាល់ហ្នឹងចេញចូលមកដីថៃ មកប៉ៃលិន មកក្នុងមួយជួរភ្នំផ្ត្រ បាទ ហើយនិងជួរអន្លង់វែង។

**ស៖** បាទ សូមអរគុណ។ តើពេលវេលាដែលលោកនៅជាមួយគាត់ជាប់ហ្នឹងមានរយៈពេលប៉ុន្មានណាដែរក្នុង១ថ្ងៃៗ? ខ្ញុំចង់និយាយអំពីពេលវេលាដែលនៅស្និទ្ធ នៅជិតគ្នាណ៎ា បាទ?

**ឆ៖** បាទ ពេលវេលាច្រើនណាស់ ពីព្រោះគាត់ដើរធ្វើការរហូត អង្កាល់ហ្នឹងគាត់នៅក្នុងព្រៃគាត់ទទួលការងារក្រៅប្រទេសអីផងៗ ហើយគាត់ចេញចូលអីផង ហើយគាត់ចេញចូលៗក្រៅប្រទេសផង។ បាទ បើនៅកន្លែងឲ្យតែមកដល់មន្ទីរ មកដល់នៅកន្លែងហើយ ខ្ញុំទៅផ្ទះគ្រួសារខ្ញុំទៅ គាត់នៅផ្ទះគាត់នៅផ្ទះគាត់អ៊ីចឹងទៅ។ ត្រូវការខ្ញុំ គាត់ចេញចូលទៅណាទៀត បានគាត់ហៅខ្ញុំទៅតែម្តង។

**ស៖** បាទ សូមអរគុណ។

**ឆ៖** បាទ។

**ស៖** តើលោកស្គាល់គ្រួសាររបស់គាត់ទេ?

**ឆ៖** បាទ ស្គាល់។

[១៣:៤០:០៥]

**ស៖** លោកដឹងពីការរៀនសូត្ររបស់គាត់ទេ?

**ឆ៖** បាទ ទើបតែដឹងយើងក្រោយនេះ ពីដើមអត់ទេ ពីមុនមកអត់ទេ។

**ស៖** លោកដឹងពីប្រវត្តិការងារ ឬក៏តួនាទីរបស់គាត់ពីសម័យមុនៗរហូតមកដល់បច្ចុប្បន្នហ្នឹងទេ?

**ឆ៖** បាទ អង្កាល់នោះ ខ្ញុំអត់សូវបានគិតគូពីរឿងប្រវត្តិអីរបស់ -- ដឹងប្រវត្តិអំពីប្រវត្តិគាត់ពីមុនយ៉ាងម៉េច ក្រោយមកយ៉ាងម៉េច អត់ដឹងទេ។ បាទ ដឹងតែពីអំឡុងដែលខ្ញុំនៅជាមួយគាត់តែម្តង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់អំពីអាកប្បកិរិយា ឬក៏ការប្រព្រឹត្តរបស់លោក ខៀវ សំផន បានទេ នៅពេលដែលលោកនៅជាមួយគាត់នោះ លោកសង្កេតឃើញយ៉ាងដូចម្តេចដែរ?

[១៣:៤១:៣៦]

**ឆ៖** បាទ អាកប្បកិរិយាដែលខ្ញុំធ្លាប់រស់នៅជាមួយ គាត់មនុស្សមិនមែនជាមនុស្សឆេវឆាវ ហើយគាត់មិនងាយចេះថាផ្តេសផ្តាស ហើយគាត់ដែលមនុស្សមួយ គឺថាហ្មត់ចត់ ចេះពិចារណា។ គាត់មិនចេះតែខឹងអត់ដឹងក្បាលកន្ទុយនោះទេ នេះចរិតរបស់គាត់។ ហើយគាត់តែងតែមានគំនិតមួយផ្តល់យោបល់ទៅឲ្យ ចំពោះពិសេសដូចខ្ញុំអី ជាគឺថាអ្នក យើងធ្លាប់តែអ្នកនៅស្រុកលើ ឲ្យចេះរបៀបរកស៊ីប្រឡូករបបសង្គមមូលធនអីចឹង គាត់តែងតែនិយាយ។ អីចឹងការចងចាំរបស់ខ្ញុំគឺអីចឹង។ បាទអានេះបញ្ជាក់នូវអត្តចរិតរបស់គាត់ គាត់មិនដែលមើលកសិករទេ បាទ។

**ស៖** បាទ សូមអរគុណ។ តើលោកមានដែលជួបប្រទះនូវបទពិសោធន៍ណាមួយជាមួយនឹងលោក ខៀវ សំផន ដែលធ្វើឲ្យលោកអន់ចិត្ត ឬក៏ខឹង ឬក៏ការចងគំនុំណាមួយជាមួយលោក ខៀវ សំផន ដែរទេ ក្នុងរយៈពេលដែលលោកនៅជាមួយលោក ខៀវ សំផន?

**ឆ៖** បាទ ទាល់សព្វថ្ងៃនេះ ខ្ញុំក៏អត់ ពីព្រោះនិយាយរួម វាអត់ៗ គាត់កម្រ-- និយាយរួមគាត់អត់ដែលស្តីពីរឿងការងារអីទេ។ ហើយគាត់មានតែការណែនាំ ប្រសិនបើយើងមានបញ្ហាអី។

[១៣:៤៣:៣៥]

**ស៖** បាទ សូមអរគុណ។ ចុះអ្នកដទៃវិញ លោកដែលឃើញការប្រព្រឹត្តរបស់លោក ខៀវ សំផន ដោយឃោរឃៅ ឬក៏ស្ថានភាពណាមួយដែលលោកកត់សម្គាល់ ចំពោះមិត្តភក្តិរបស់លោក ឬក៏អ្នកបង្គាប់របស់លោក ឬក៏អ្នកនៅក្រោមបង្គាប់លោក ខៀវ សំផន ដទៃទៀតទេ?

**ឆ៖** បាទ អត់ឃើញទេ។

**ស៖** ទាក់ទងទៅនឹងទស្សនៈនយោបាយ តើលោកអាចធ្វើការអត្ថាធិប្បាយ ឬក៏យល់អំពីលោក ខៀវ សំផន ធ្លាប់និយាយជាមួយលោកបែបណាទេ? លោកមានចាំបានទេ?

**ឆ៖** បាទ និយាយពីភាគច្រើន គាត់និយាយជាមួយខ្ញុំ គាត់ផ្តោតទៅលើសំខាន់ក្នុងរបបសេដ្ឋកិច្ច ដែលទីផ្សារសេរី ប្រើលុយ។ គាត់ធ្វើម៉េចរៀបចំក្នុងក្រុមគ្រួសារឱ្យមានហូបមានចុក ដើម្បីដំណើរ សមរម្យ ជាប្រជាពលរដ្ឋល្អ។ ភាគច្រើនគាត់អ្នកណែនាំទៅអ៊ីចឹងដែរ។ នយោបាយផ្សេងទៀត អត់។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងការឱ្យដំបូន្មានរបស់លោក ខៀវ សំផន ចំពោះលោកផ្ទាល់ ជាពិសេសទាក់ទងទៅនឹងការរៀបចំគ្រួសារ ឬក៏ស្ថានភាពសេដ្ឋកិច្ចគ្រួសារ តើលោកមានចាំអ្វីជាពិសេស ដែលលោក ខៀវ សំផន ធ្លាប់និយាយជាមួយលោកដែរទេ?

[១៣:៤៥:៣៥]

**ឆ៖** ដូចអត់មានក្រៅពីហ្នឹងទេ។

**ស៖** លោកមានចាំបានអ្វីដែលជាអំពើល្អរបស់លោក ខៀវ សំផន ដែលលោកបានប្រព្រឹត្ត ចំពោះអ្នកដទៃនៅក្នុងអំឡុងពេលដែលលោកនៅជាមួយលោក ខៀវ សំផន ដែរទេ?

**ឆ៖** ពីព្រោះក្នុងអំឡុងពេលដែលខ្ញុំនៅ គាត់ ន៎ែ ចំពោះអ្នកដទៃ គឺដូចជាមិនមានអី ផលលំបាក អីទេ។

**ស៖** បាទសូមអរគុណ។ លោកមានអ្វីចង់បន្ថែមថាជាអំពើល្អរបស់លោក ខៀវ សំផន ចំពោះ លោក ឬក៏ចំពោះអ្នកណាម្នាក់ដែលលោកបានជួបប្រទះ បានឃើញ ចង់ជម្រាបជូនអង្គសវនាការនៅ ពេលនេះទេ?

**ឆ៖** បាទ អត់មាន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយលោក សុខ រឿ។ ខ្ញុំអស់សំណួរលោក ដែលលោកបានមកជួយឆ្លើយនៅទីនេះ។ សូមអរគុណលោកប្រធាន។

[១៣:៤៧:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ លោកសាក្សីជម្រាបសួរ ខ្ញុំឈ្មោះ ចៅក្រម ឡាវែន៍។ ខ្ញុំសួរសំណួរមួយចំនួនបន្ថែមទៅនឹងអ្វីដែលសួរដោយលោកមេធាវី។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកត្រូវបានគេសួរអំពីបុគ្គលិកលក្ខណៈរបស់លោកខៀវ សំផន។ ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ លោកថា លោកខៀវ សំផន ជាមនុស្សរឹងមាំ ក៏ប៉ុន្តែមិនងាយខឹងសម្បាផ្តេសផ្តាសទេ។ គាត់មនុស្សហ្មត់ចត់ណាស់ ហើយគាត់ក៏ជាមនុស្សមានហេតុផល។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើលោកចាត់ទុកលោក ខៀវ សំផន ថាជាមនុស្សដែលមានភាពច្បាស់លាស់ ឬក៏ថាជាមនុស្សមួយដែលអាចឲ្យមានគេសង្ស័យបានដែរ?

**លោក សុខ រឿន៖**

**ឆ៖** បាទ សម្រាប់ខ្ញុំ ខ្ញុំថាគាត់ជាមនុស្សច្បាស់លាស់ពីព្រោះគាត់ធ្វើអីមួយមិនដែលទៅប៉ះខាងផ្លូវចិត្តខ្ញុំអីអ៊ីចឹងទៅ។ ខ្ញុំគិតថាជាច្បាស់ត្រឹមត្រូវបាទ។

[១៣:៤៩:១១]

**ស៖** តើលោក ខៀវ សំផន ធ្លាប់ដែលមានការសម្តែងការសោកស្តាយទៅលើហេតុការណ៍ដែលថាគាត់ធ្លាប់បានជួបប្រទះដែរទេ?

**ឆ៖** បាទ រឿងហ្នឹង ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកធ្លាប់និយាយជាមួយលោក ខៀវ សំផន អំពីអ្វីដែលបានកើតឡើងនៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៩ ដែរឬទេ ឬក៏ថាលោកមិនធ្លាប់ដែលនិយាយអំពីរឿងរ៉ាវទាំងអស់នេះជាមួយគាត់ទេ?

**ឆ៖** បាទអត់ទេ អត់ដែលនិយាយទេ ព្រោះអត់ដឹង។

**ស៖** នៅពេលដែលលោកមកដល់ភ្នំពេញលោកបានឆ្លើយថាលោកនៅ ក-៨, ក-១ បន្ទាប់មកទៅ ក-៣។ លោកជួបមនុស្សជាច្រើន។ តើលោកមានកត់សម្គាល់ឃើញថានៅក្នុងអំឡុងពេលដែលលោកនៅទីក្រុងភ្នំពេញនោះតើមានមនុស្សបាត់ខ្លួនទេ នៅក្នុងអំឡុងពេលនោះ?

[១៣:៥០:៤១]

**ឆ៖** បាទ អត់ដឹងទេ ព្រោះកាលនោះនិយាយខ្មែរ គេនិយាយតែជ្រៅបន្តិចលែងដឹងហើយ។

**ស៖** ខ្ញុំមិននិយាយអំពីរឿងរ៉ាវស្មុគស្មាញអ្វីទេ ខ្ញុំគ្រាន់តែចង់ដឹងថា ក្នុងចំណោមមនុស្សនៅជុំវិញលោក មនុស្សដែលលោកស្គាល់មនុស្សដែលលោកធ្វើការជាមួយ តើលោកមានបានឃើញថាអ្នកទាំងអស់ហ្នឹងមានអ្នកណាខ្លះបាត់ខ្លួនទេ? ឧទាហរណ៍ដូចថ្ងៃណាមួយទៅលោកលែងឃើញមនុស្សមួយចំនួនលែងឃើញត្រឡប់មកវិញ ធ្លាប់មានហេតុការណ៍អ៊ីចឹងកើតឡើងទេ?

[១៣:៥១:២៤]

**ឆ៖** អ៊ូ! ដែលក្រុមនៅជាមួយគ្នាអត់ទេ អត់មានទេ។

**ស៖** តើលោកធ្លាប់ចូលរួមនៅក្នុងវគ្គទិតៀន និងស្វ័យទិតៀនដែរឬទេ? លោកស្គាល់ពាក្យទាំងពីរនេះទេ? ប្រជុំទិតៀន និងស្វ័យទិតៀន។

**ឆ៖** បាទ នៅក្នុងក្រុមតែងតែប្រជុំ បាទ ប្រជុំទិតៀនស្វ័យទិតៀនបាទ។

**ស៖** ចុះជាមួយលោក ខៀវ សំផន តើមានការនិយាយគ្នាអំពីវគ្គទិតៀន និងស្វ័យទិតៀន នេះទេជាមួយលោក ខៀវ សំផន នោះ?

**ឆ៖** បាទ នៅពេលដែលខ្ញុំនៅជាមួយគាត់គាត់អត់បានចូលរួមទេ ប៉ុន្តែពួកខ្ញុំធ្វើតែពួកខ្ញុំទេ នៅសម័យអំឡុងដែលខ្ញុំនៅជាមួយគាត់។

**ស៖** សំណួរខ្ញុំនោះខ្ញុំចង់ដឹងថាលោកជាអ្នកការពារលោក ខៀវ សំផន តើគាត់មានបាននិយាយជាមួយលោកអំពីបញ្ហាទិតៀន និងស្វ័យទិតៀនហ្នឹងទេ?

**ឆ៖** បាទ ហ្នឹងគាត់ -- មានតែអ្នកផ្សេងទេ គេនិយាយពីរឿងទិតៀន ស្វ័យទិតៀន ពីព្រោះពួកខ្ញុំតែងតែប្រជុំក្រុម ឬក៏ពួកគេតែងតែប្រជុំដកពិសោធ ប្រជុំក្រុម មានប្រជុំទិតៀនស្វ័យទិតៀនហ្នឹងដែរតែជាមួយគាត់ គាត់អត់ដែលនិយាយប្រាប់ពួកខ្ញុំទេ។

[១៣:៥៣:៥០]

**ស៖** អម្បាញ់មិញនេះលោកនិយាយថា លោក ខៀវ សំផន ជាមនុស្សម៉ាំទាំ ជាមនុស្សរឹងម៉ាំគឺលោកចង់និយាយថា ជាមនុស្សចេះដឹកនាំចេះធ្វើឲ្យគេគោរព។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រូវ។ ព្រោះអាហ្នឹងគាត់និយាយជាមួយខ្ញុំទល់មុខជាមួយខ្ញុំតែម្តងរបៀបថាជាការនិយាយសាមញ្ញៗ អានេះពីព្រោះគាត់អត់មានពេលទៅប្រជុំអីជាមួយពួកខ្ញុំទេ។ បាទ អ៊ីចឹងគាត់មានតែនិយាយរបៀបសាមញ្ញ ព្រោកប្រាជ្ញទៅ ក៏យើងយកជាផ្លូវការបញ្ជាក់ថា ជាគំនិតល្អៗរបស់គាត់មានបាទ។

**សៈ** ចុះនៅពេលដែលលោក ខៀវ សំផន បញ្ជាឲ្យលោកធ្វើអ្វីមួយ ឬក៏ឃើញគាត់ចេញបញ្ជា នោះគឺជាការបញ្ជាដែលមានលក្ខណៈជាក់លាក់ ហើយដែលគេត្រូវតែអនុវត្តតាមតើអ៊ីចឹងមែនទេ?

**ផៈ** នៅពេលដែលខ្ញុំនៅជាមួយគាត់ ខ្ញុំនិយាយកាត់ ខ្ញុំអត់និយាយពីមុនទេ។ ខ្ញុំតែពី៩៩ ដែលខ្ញុំនៅជាមួយគាត់។ បាទ ពីព្រោះគាត់ធ្វើការខាងក្រៅ ច្រើនជាងក្នុងផ្ទៃក្នុង បាទខាងផ្ទៃក្នុងចង់និយាយថា ក្នុងចំណោមមន្ទីរ។ បាទចំណោមមន្ទីរហ្នឹង ខ្ញុំទៅជាប់ជាមួយគាត់មានគ្នាតែប៉ុន្មាននាក់អ៊ីទៅមកជាមួយគាត់ហ្នឹង គាត់មិនសូវជាជាប់ជាមួយកម្លាំងមន្ទីរទេ គាត់ច្រើនជាប់តែនៅខាងក្រៅ នៅពីអំឡុងសម័យសង្គ្រាមចុងក្រោយនេះ។ បាទពីដែលខ្ញុំនៅជាមួយគាត់៩៩ -- នៅ៨៩ ច្រឡំ។

[១៣:៥៦:០៣]

**សៈ** ប្រហែលជាសំណួរខ្ញុំមិនសូវច្បាស់មើលទៅ ខ្ញុំចង់ដឹងថាតើចំពោះលោកនោះលោក ខៀវ សំផន គឺជាមនុស្សមួយដែលពូកែបញ្ជាដែរឬទេ? គឺបានន័យថាគាត់ចេះបញ្ជាមនុស្ស ចេះប្រើមនុស្ស ចេះបញ្ជាទៅឲ្យគេគោរពតាម។

**ផៈ** បាទ បញ្ជា វាអត់យល់។ មួយរបៀបបញ្ជាទាហាន ឬបញ្ជាយ៉ាងម៉េច?

**សៈ** លោក ខៀវ សំផន ហ្នឹងគឺថាគាត់គឺជាមនុស្សម្នាក់ដែលមានអំណាច គឺគាត់ជាថ្នាក់លើរបស់គាត់។ ដូច្នេះបើគិតទៅគាត់មានអំណាចបញ្ជាមនុស្សមួយចំនួនដែលនៅក្រោមបង្គាប់របស់គាត់។ ដូច្នេះខ្ញុំចង់ដឹងថាក្នុងឋានៈគាត់ជាអ្នកមានអំណាចបែបនេះនោះ គាត់ហ្នឹងជាមនុស្សចេះបញ្ជាទេ?

**ផៈ** បាទ ពីព្រោះខ្ញុំដឹងតែដែលខ្ញុំនៅជាមួយគាត់ គាត់របៀបថាមិនមែនបញ្ជាថា របៀបបញ្ជាអាជ្ញានោះទេ។ បាទគាត់តែងតែណែនាំ ហើយណែនាំនោះក៏តែមួយចង្កោមតែពួកខ្ញុំបីបួននាក់អ៊ីចឹងដែលជុំវិញគាត់។ ហើយភាគីច្រើនគាត់ខ្ញុំជាមេបញ្ជាការពារ កិច្ចការមួយចំនួន គាត់និយាយអំពីយាមកាម គឺខ្ញុំដឹងតែពីយាមកាមតែប៉ុណ្ណឹងទេបាទ។ បាទហើយការដែលគាត់និយាយ យើងត្រូវតែការងាររបស់យើង យើងធ្វើការងាររបស់គាត់ គាត់ធ្វើតែម្តងបាទ។ ហើយគាត់តែងតែណែនាំ ហើយយើងការពារយាមពីព្រលប់អ៊ីចឹងទៅ មើលទឹកក្តៅទឹកត្រជាក់អ៊ីចឹងសម្រាប់គាត់។

[១៣:៥៨:១៧]

**សៈ** លោកសាក្សី លោកជាអង្គរក្សរបស់គាត់ នៅពេលដែលគាត់ចេញបញ្ជាអ្វីមួយទៅលោក តើលោកស្តាប់បញ្ជារបស់គាត់ទេ?

**ផៈ** បាទ នៅក្នុងអំឡុងដែលខ្ញុំនៅជាមួយគាត់ពី៨៩ បាទពីព្រោះសិទ្ធិគាត់ធំ។ យើងឧបមាថា

ទៅជាមួយគាត់ ត្រូវតែទៅជាមួយគាត់អ៊ីចឹងហើយបាទ។

**ស៖** សំណួរចុងក្រោយលោកសាក្សី ពីដំបូងអម្បាញ់មិញនេះលោកនិយាយថា លោកបានជួបជាមួយមេធាវីរបស់លោក ខៀវ សំផន។ ខ្ញុំមិនដឹងថាអ្នកណាដែលលោកថាជាមេធាវីហ្នឹង លោកមានឃើញទេក្នុងបន្ទប់សវនាការហ្នឹង ថាលោកជួបជាមួយអ្នកណាដែរដែលលោកថាជាមេធាវីលោក ខៀវ សំផន នុ៎ង នៅពេលដែលលោកនិយាយថាលោកបានជួបមេធាវីរបស់លោក ខៀវ សំផន ហ្នឹងតើលោកសំដៅលើអ្នកណាមួយ លោកមើលទៅមើល លោកឃើញទេ មានអ្នកណាទេនៅក្នុងបន្ទប់សវនាការហ្នឹង?

**ឆ៖** បាទ អត់។ ខ្ញុំតែជួបគ្នាម្ដងមិនបានមើលមុខគេ ភ្លេចបាត់។ បាទ អ៊ីចឹងចំណុចខ្សោយ។

[១៤:០០:០៤]

**ស៖** ប៉ុន្តែម្នាក់ហ្នឹងលោកនិយាយថា ជាមេធាវីរបស់លោក ខៀវ សំផន តើអ៊ីចឹងទេ? ប្រាកដទេ? លោកប្រាកដទេ ថាគាត់ជាមេធាវី? អ៊ីចឹងអ្នកដែលសួរសំណួរលោកថ្ងៃនេះហ្នឹង មេធាវីអម្បាញ់មិញហ្នឹង តើជាម្នាក់ដែលលោកជួបនៅថ្ងៃនុ៎ងទេ? លោកច្បាស់ទេ?

**ឆ៖** បាទ មិនមែនទេ។ បាទ មិនមែន។

**ស៖** បើសិនជាមិនមែន លោកស្គាល់ឈ្មោះគាត់ទេ មេធាវីហ្នឹង ឈ្មោះអីដែរ?

**ឆ៖** ខ្ញុំអត់បានចាំឈ្មោះទៀតហ្នឹង បាទ។

**ស៖** ចុះថាលោកថាមេធាវីហ្នឹង នៅពេលដែលគាត់ទៅជួបលោកហ្នឹង គាត់និយាយអីប្រាប់លោកខ្លះ?

**ឆ៖** បាទ គាត់សួររបៀបលោកមេធាវីនេះដែរ គាត់សួរអំពីប្រវត្តិដើមទងដែលខ្ញុំរាយរាប់ជម្រាបលោកមេធាវី។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១៤:០១:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវី -- អ៎! តំណាងសហព្រះរាជអាជ្ញាដើម្បីមាន

ឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន។ លោក លោកស្រីចៅក្រម។ សូមគោរព និងសួស្តីទៅដល់ភាគី មេធាវី រួមទាំងសាក្សីផងដែរ នៅក្នុងរសៀលនេះ។

លោកប្រធាន នៅពេលនេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដោយចាប់ផ្ដើមបន្តពីសំណួរដែលសួរពីចៅក្រម ឡាវ៉ែន៍ ដើម្បីគោលបំណងនេះ ខ្ញុំមានបំណងបង្ហាញជូនសាក្សីនេះ នូវទំព័រក្របខាងមុខនៃឯកសារមួយ។ ឯកសារ E3/71។ គឺជាកំណត់ហេតុនៃការធ្វើសម្បថរបស់សាក្សី។ គឺសាក្សី TC-639។ ឯកសារនេះ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៩។ ដូច្នេះ ខ្ញុំស្នើសុំពីលោកប្រធាន បង្ហាញកំណត់ហេតុមួយនេះ ជូនទៅកាន់សាក្សី ដើម្បីឲ្យសាក្សីបញ្ជាក់ថាតើសាក្សីរូបនេះ ស្គាល់សាក្សីនៅក្នុង-- មានឈ្មោះនៅក្នុងឯកសារនេះដែរឬទេ? សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១៤:០៤:០៨]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមពន្យល់នៅក្នុងតុលាការនេះតែម្ដង។ ឯកសារនេះ គឺបានចេញផ្សាយនៅក្នុងសារព័ត៌មានពីមេធាវីមួយនៅក្នុងក្រុមនោះ។ ERN ជាភាសាអង់គ្លេស គឺមានសរសេរនៅក្នុងឯកសារនោះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក សុខ រឿ ជាដំបូង ខ្ញុំសូមសួរលោក ថាតើលោកបានដឹង ឬក៏ស្គាល់របស់បុគ្គលដែលមានសរសេរនោះដែរទេ? តើលោកស្គាល់ ឬក៏មិនស្គាល់?

**ប្រធានអង្គជំនុំ៖**

លោក សុខ រឿ កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន។

[១៤:០៤:៥៨]

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំសូមឱ្យតំណាងសហព្រះរាជអាជ្ញាមេត្តាបញ្ជាក់អំពីឯកសារនេះ ថាតើបានបញ្ចូលនៅក្នុង អ៊ីនធីហ្វេស សម្រាប់ធ្វើការបទបង្ហាញហើយឬនៅ? ហើយម្យ៉ាងទៀតសូមឱ្យតំណាងសហព្រះរាជអាជ្ញាបន្តប្រើនីតិវិធីដូច ដែលធ្លាប់អនុវត្តកន្លងមក។ បាទសូមអរគុណ។

**លោក ឃីត វេយ៍ន័រ៖**

ខ្ញុំគឺថា ឃើញថាអ្វីដែលខ្ញុំបានសួរនេះនឹងបង្ហាញឱ្យបានច្បាស់នៅក្នុងពេលនេះតែម្តង។ នេះគឺជាហេតុផលដែលវាអាចបង្ហាញចេញតាមសក្ខីកម្មនេះផ្ទាល់តែម្តង។ ហើយយើងមិនអាចរំពឹងថាសក្ខីកម្មគឺគាត់នឹងឆ្លើយអ្វីខ្លះនោះទេ ចំពោះសាក្សីរូបនេះដោយសារតែយើងមិនមានកំណត់ហេតុជាមុន។ ហេតុដូច្នេះហើយ គឺយើងមានហេតុផលផ្តល់ឯកសារនេះឱ្យគាត់បញ្ជាក់។ ដូច្នេះហើយមានវិធីណាមួយដែលថាយើងត្រូវតែមានលទ្ធភាពដាក់ឯកសារនេះជាមុនទៅអ៊ីនធីហ្វេស ដោយសារយើងមិនទាន់ដឹងថាសាក្សីនេះបានឆ្លើយពីអ្វីផងនោះ។ ខ្ញុំបន្ថែមថាទោះបីជាមិនមាននៅក្នុងអ៊ីនធីហ្វេសក៏ដោយ គឺវាមាននៅក្នុងសំណុំរឿងចំពោះឯកសារមួយច្បាប់នេះ។

[១៤:០៦:១៩]

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** តើលោកស្គាល់ឈ្មោះទេ លោកសាក្សី ស្គាល់ឈ្មោះបុគ្គលដែលមានឈ្មោះនៅក្នុងឯកសារនេះដែរឬទេ? ស្គាល់ ឬក៏មិនស្គាល់?

**លោក សុខ វឿ៖**

**ឆ៖** បាទអត់ស្គាល់ទេ។

**ស៖** នេះគឺជាសាក្សី, អង់គ្លេស ERN គឺ00288623។ សាក្សីនេះ គេសួរសាក្សីនេះថា "តើលោកឈប់ធ្វើការងារនៅ ក-១៨ នៅពេលណា? ឆ្លើយ៖ ខ្ញុំធ្វើការងារនៅក-១៨ រហូតដល់ឆ្នាំ១៩៩៣ ឬក៏ឆ្នាំ១៩៩៤"។ ERN ជាភាសាអង់គ្លេស 00288622 នៅត្រង់ចំណុចកណ្តាលទំព័រឯកសារនេះសាក្សីបានរៀបរាប់អំពីអ្នកបកប្រែឯកសារម្នាក់ ហើយវាបង្ហាញអំពីរយៈកាលនៅមន្ទីរក-១៨។ សាក្សីនេះបានឆ្លើយដូចតទៅនេះថា "នៅក្នុងពេលនោះ ប៉ុល ពត និង ខៀវ សំផន ក៏ស្នាក់នៅក្នុងមន្ទីរក-១៨ ផងដែរ"។

ដូច្នេះសំណួរដំបូងរបស់ខ្ញុំ សួរទៅកាន់លោកសាក្សី គឺថាតាមការដឹងឮរបស់លោក ឬក៏តាមការសង្កេតរបស់លោកនៅពេលដែលលោកនៅក-១៨ នោះថាតើ ខៀវ សំផន បានចំណាយពេលនៅជាមួយ

នឹង ប៉ុល ពត ដែរឬទេនៅមន្ទីរនោះ?

[១៤:០៨:០៦]

**ឆៈ** បាទខ្ញុំពេលនោះអត់ដឹងគេ ដល់ពេលនែ៎ រំសាយ។ ដឹងថាកន្លែងហ្នឹងជាកន្លែងរបស់ខាងគាត់។ ខ្ញុំម៉េចដឹង ព្រោះខ្ញុំគ្រាន់តែអ្នកជម្រះស្មៅ ដាំបន្លែ បាទ។

**សៈ** ប្រហែលជាលោកយល់ច្រឡំនឹងសំណួរដែលខ្ញុំសួរអម្បាញ់មិញលោក សុខ រឿ។ ខ្ញុំមិនមែននិយាយអំពី ក-៨ ដែលលោករៀបរាប់នៅក្នុងទសវត្សរ៍ឆ្នាំ៧០នោះទេ។ ខ្ញុំសួរអំពីមន្ទីរ ក-១៨ ដែលលោកបានរៀបរាប់។ លោកបានរៀបរាប់ថានៅក្នុងទសវត្សរ៍ឆ្នាំ៩០ គឺឆ្នាំ៩២ ឬក៏ឆ្នាំ៩៣ លោករៀបរាប់អំពីមន្ទីរ ក-១៨នោះ។ ខ្ញុំសួរថា តើនៅពេលដែលលោកធ្វើការងារនៅមន្ទីរ ក-១៨ ក្នុងឆ្នាំទសវត្សរ៍ឆ្នាំ៩០ នោះ តើនៅពេលដែលលោកធ្វើការងារនៅមន្ទីរ ក-១៨ ក្នុងទសវត្សរ៍ឆ្នាំ៩០នោះ តើលោកមានដែរឃើញលោក ខៀវ សំផន រស់នៅជាមួយគ្នាជាមួយនឹងលោក ប៉ុល ពត ដែរឬទេ?

**ឆៈ** បាទនៅក្នុងអំឡុងហ្នឹង ដូចនៅក្នុងអំឡុង៩១, ៩២ នៅក្នុងសង្គ្រាមនៅឡើយទេ។ ខ្ញុំនៅព្រោះអំមិញអត់និយាយទាក់ទងទៅនឹងទេអំមិញ។ ខ្ញុំនៅជាមួយគាត់តាំងពី៩៩ បាទ -- អ៎! ៨៩ ច្រឡំ សូមទោស ៨៩។

[១៤:១០:០០]

**សៈ** សូមឲ្យលោកបញ្ជាក់ លោកបានឆ្លើយប្រាប់តុលាការនៅក្នុងថ្ងៃនេះថា លោកបានប្រាប់ថាលោកបានធ្វើការងារជាមួយនឹងលោក ខៀវ សំផន ជាអ្នកកងការពាររបស់គាត់ ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៥។ តើលោកអ្វីដែលលោកឆ្លើយអម្បាញ់មិញក្នុងថ្ងៃនេះៗត្រឹមត្រូវតាមដែលខ្ញុំរៀបរាប់អម្បាញ់មិញដែរទេ ឬក៏លោកចង់កែប្រែទៅនឹងចម្លើយដែលលោកឆ្លើយអម្បាញ់មិញនេះ?

**ឆៈ** បាទ ដែលខ្ញុំនិយាយនៅជាប់នឹងគាត់ និយាយតែពីអំឡុងពី៩០ អ៎! ពី៨៩ មកដល់អំឡុង៩៦។ ហើយអំឡុងមុននោះ និយាយតែពីអង្គាល់ដែលនៅចូលថ្មីថ្មោងនៅចូលទៅភ្នំពេញ ហាក់បីដូចជាព្រោះវានៅធ្វើតាមលំដាប់ៗ មួយខែ ពីរខែ--

**សៈ** ខ្ញុំដឹង ក៏ប៉ុន្តែខ្ញុំសូមកាត់លោក។ ខ្ញុំមិនបានសួរលោកអំពីចំណុចនេះទេ ខ្ញុំសូមឲ្យលោកឆ្លើយនូវអ្វីដែលខ្ញុំបានសួរលោកអម្បាញ់មិញនេះតែម្តងទៅ។ តើលោកឆ្លើយប្រាប់តុលាការចៅក្រម នៅក្នុងពេលនេះ គឺលោកបាននិយាយថា ពីឆ្នាំ១៩៨៩ ដល់ ឆ្នាំ៩៦ នៅពេលនោះគឺលោកធ្វើជាអង្គរក្សរបស់ខៀវ សំផន។ អ៊ីចឹងបានន័យថាក្នុងអំឡុងពេលឆ្នាំ៨៩ ដល់ឆ្នាំ៩៦ ពេលដែលលោកធ្វើជាអង្គរក្សលោក

មិនដែលធ្លាប់ឃើញ ប៉ុល ពត ទេឬ?

[១៩:១១:៤៨]

**ឆ៖** បាទ ធ្លាប់ឃើញ ប៉ុន្តែយើងអត់មានជិតស្និទ្ធ។

**ស៖** តើ ខៀវ សំផន នៅជិតស្និទ្ធជាមួយនឹង ប៉ុល ពត ដែរឬទេ?

**ឆ៖** អាហ្នឹងជាចង្កោមក្រុមដឹកនាំរបស់គាត់ ខ្ញុំអត់សូវក្តាប់ជាប់ អត់សូវដឹងដែរ។

**ស៖** ក្នុងរយៈពេល៧ឆ្នាំនោះ តើលោកធ្លាប់ឃើញ ប៉ុល ពត និង ខៀវ សំផន នៅជាប់ជាមួយគ្នាដែរឬទេ?

**ឆ៖** រយ: -- បាទ មួយរយៈខ្ញុំនៅជាមួយគាត់ៗ តែងតែជួបគ្នា។

**ស៖** តើពួកគាត់ទៅជួបគ្នានៅឯណាទៅ?

**ឆ៖** បាទ ភាគច្រើនគាត់ជួបតែនៅកន្លែងមន្ទីររបស់គាត់នៅ ដូចជាមន្ទីរ៨៩ នៅមួយជួរកោះកុង មួយជួរប៉ៃលិន មួយជួរអីហ្នឹងបាទ។

[១៩:១៣:១៥]

**ស៖** លោកបាននិយាយពួកគាត់ជួបនៅមន្ទីរ អ៊ីចឹងបានន័យថាមន្ទីរហ្នឹងជាកន្លែងដែល ខៀវ សំផន និង ប៉ុល ពត ធ្វើការរួមជាមួយគ្នា ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ពីព្រោះអង្កាល់ហ្នឹងខ្ញុំនៅក្នុងព្រៃ មន្ទីរ៨៩ វានៅក្នុងព្រៃ។ ត្រូវតែមានកន្លែងមួយសម្រាប់ខាងគាត់អ្នកធ្វើការ។

**ស៖** តើពួកគាត់ពីរនាក់ហ្នឹង ធ្វើការរួមជាមួយគ្នាហ្នឹងញឹកញាប់ទេ?

**ឆ៖** បាទ នែ! ការញឹកញាប់ខ្ញុំមិនសូវជាដឹងទេ ពីព្រោះកាលណាចូលក្នុងមន្ទីរហើយ ខ្ញុំដើរចេញទៅផ្សេងទៅ គាត់ចូលទៅកន្លែងធ្វើការទៅបាទ។

**ស៖** តើ ប៉ុល ពត មានអង្គរក្សទេ?

**ឆ៖** បាទ មាន។

**ស៖** លោកជាអង្គរក្សរបស់ ខៀវ សំផន ហ្នឹង តើលោកជួបជាមួយនឹងអង្គរក្សរបស់ ប៉ុល ពត ហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ អង្កាល់ណោះនៅក្មេងៗតែងតែយើងជួបគ្នាម្តងតែងតែជួបគ្នាបាទ។

**ស៖** តើលោកនៅឈ្មោះអង្គរក្សណាមួយរបស់ ប៉ុល ពត ដែរឬទេ?

[១៤:១៥:០៣]

**ឆ៖** នៅអង្គរក្សភាគច្រើនមួយស្រករខ្ញុំវាបាត់បង់ច្រើន ហើយអ្នកដែលនៅមិនដឹងគេនៅកន្លែងណាអត់ដឹងទេ វាដាច់ខ្សែរយៈគ្នាទាក់ទង។

**ស៖** សូមអធ្យាស្រ័យអង្គរក្សរបស់ ប៉ុល ពត បាត់ខ្លួន លោកទើបតែនិយាយអ៊ីចឹងអម្បាញ់មិញមែនទេ?

**ឆ៖** បាទ បាត់នោះបានន័យថា យើងផ្លាស់ប្តូរដូចជាក្រោយសមាហរណកម្មមិនដឹងគាត់នៅកន្លែងណា? មិនមែនជាបាត់ខ្លួនឬស្លាប់នោះទេ? មួយចំនួនស្លាប់នៅសង្គ្រាម។ បាទ មួយចំនួនទៀតក៏មានជំងឺអ៊ីចឹងទៅ។ បាទភាគច្រើនមួយស្រករខ្ញុំស្លាប់ នៅ៧៩វាច្រើនជាងនៅសម័យច្បាំង។

**ស៖** ខ្ញុំសូមឱ្យលោកគិតបន្តិចទៅមើលក្នុងរយៈពេល៧ឆ្នាំ ពេលដែលលោកធ្វើជាអង្គរក្សលោក ខៀវ សំផន នោះ ខ្ញុំសូមសួរថ្ងៃជាក់លាក់ដែលលោកនៅធ្វើការនៅក្នុងពេលនោះ។ វាអាចពិបាកសម្រាប់លោកដោយសារថា ម៉្ងៃៗវាខុសគ្នាសម្រាប់មនុស្សម្នាក់ៗ។ តើលោកអាចផ្តល់ជាយោបល់ដែរឬទេជាមធ្យមនោះបើគិតជាថ្ងៃ តើលោកជួបជាមួយលោក ខៀវ សំផន ប៉ុន្មានដែរ ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ លុះត្រាតែប្រសិនបើនៅកន្លែងគាត់អត់ចេញធ្វើដំណើរធ្វើការទៅណាឆ្ងាយ គឺខ្ញុំ ខ្ញុំធ្វើការរបស់ខ្ញុំ ហើយគាត់ការងាររបស់គាត់។ បើសិនជាគាត់ចេញទៅណាធ្វើការឆ្ងាយៗបានគាត់ហៅខ្ញុំទៅជាមួយ។ ព្រោះនៅកន្លែងខ្ញុំក៏ធ្វើការងាររបស់ខ្ញុំអ៊ីចឹងទៅ។

[១៤:១៧:១៣]

**ស៖** គឺខ្ញុំចង់និយាយអំពីថ្ងៃមួយជាក់លាក់តែម្តង នៅពេលដែលលោកនៅជាមួយគាត់នោះ ថាតើបើសិនជាមានថ្ងៃប្រជុំនោះគឺគាត់ទៅប្រជុំអ្វីដែរ ហើយលោកនៅជាមួយគាត់នៅកន្លែងណាដែរ?

**ឆ៖** បាទ ការប្រជុំ ការងាររបស់គាត់ខ្ញុំអត់ដឹងទេ ហើយនៅយើងនៅមួយជួរកោះកុង ហើយនៅក្នុងព្រៃ អាហ្នឹងមិនស្គាល់ ដល់អ៊ីចឹងនៅដងភ្នំក្រវាញ ហើយទៅមួយជួរប៉ៃលិន មួយជួរសំឡូត និងកន្លែងធ្វើការសម្រាប់ពីសម័យសង្គ្រាម។ ភាគច្រើននៅខាងផ្នែកកោះកុងមួយជួរដងភ្នំក្រវាញ។

**ស៖** នៅក្នុងពេល៧ឆ្នាំ លោកនៅមន្ទីរ ក-១៨ តើនៅទីនោះមានធ្លាប់គេរៀបចំប្រជុំកម្មាភិបាលរួមគ្នា ឬក៏កោះហៅទាហានហ្នឹងមកជុំគ្នាប្រជុំនៅមន្ទីរ ក-១៨ ដែរឬទេ?

**ឆ៖** បាទ ហ្នឹងអត់ទេគាត់មិនមែនជារឿងផ្នែកទាហានទេ។

**ស៖** ខ្ញុំសូមយោងទៅលើកំណត់ហេតុដែលយើងនិយាយមុននេះបន្តិច។

អង់គ្លេស ERN00288626, សាក្សីនេះបាននិយាយដូចតទៅ៖ "ប៉ុលពត និង ខៀវ សំផន ដែលជាមេផ្ទាល់របស់ខ្ញុំ គឺជាបុគ្គលដែលចេញបញ្ជាដោយផ្ទាល់នៅមន្ទីរក-១៨"។ តាមបទពិសោធន៍របស់លោកតើលោកយល់ស្របជាមួយ ចម្លើយដែលសាក្សីនោះឆ្លើយដែរឬទេ ឬក៏លោកមិនយល់ស្របជាមួយចម្លើយនោះទេ?

**លោក គង់ សំអុន៖**

លោកប្រធាន!

[១៤:២០:០៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

លោកប្រធានសូមអរគុណ។ ខ្ញុំបាទយល់ឃើញថា តំណាងសហព្រះរាជអាជ្ញាកំពុងតែសួរសំណួរចាកចេញពីវិសាលភាពនៃសំណុំរឿង ដែលយើងត្រូវជំនុំជម្រះនៅពេលនោះហើយ គឺសំណុំរឿង ០២/០១។ ដោយហេតុថារឿងរ៉ាវដែលតំណាងសហព្រះរាជអាជ្ញាលើកនោះ គឺជារឿងដែលទាក់ទងទៅនឹងក្រោយឆ្នាំ១៩៧៩ ដែលមិនមែនស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការនេះទេ។ ហើយម្យ៉ាងទៀតសាក្សីនេះ គឺផ្តោតសំខាន់ទៅលើការបង្ហាញពីអត្តចរិត មិនមែនពីការងារទំនាក់ទំនងរបស់កម្ពុជាប្រជាធិបតេយ្យក្រោយការដួលរលំនោះទេ។ បាទ សូមអរគុណ សូមជំទាស់លោកប្រធាន។

[១៤:២១:០៥]

**លោក ឃីត វេយ៍ន័រ៖**

គឺថាតើមេធាវីការពារក្តីមានគោលបំណងបែបណានោះ ខ្ញុំទុកឲ្យភាគីជាអ្នកផ្សេងវិនិច្ឆ័យ។

លោកប្រធាន មេធាវីការពារក្តីជាអ្នកស្នើសុំសាក្សីនេះ ហើយគាត់និយាយថាសាក្សីនេះផ្តល់សក្ខីកម្មអំពីអត្តចរិតនិងអង្គហេតុ។ អត្តចរិតយើងមើលមិនឃើញនោះទេ វាមិនមែនថាពាក់ព័ន្ធនឹងអំឡុងពេលណាមួយជាក់លាក់នោះទេ គឺវាពាក់ព័ន្ធទូទៅ។

លោកចៅក្រម ឡាវែន៍ បានសួរអំពីសមត្ថភាព លទ្ធភាពរបស់លោក ខៀវ សំផន ក្នុងការបញ្ជា។ សំណួរទាំងអស់នេះគឺស្របគ្នាជាមួយនឹងសំណួរដែលចៅក្រម ឡាវែន៍ គាត់បានតាំងរួចមក

ហើយ។ ហេតុដូច្នេះ ខ្ញុំគួរតែមានការទទួលអនុញ្ញាតឲ្យសួរទៅមុខទៀត ហើយខ្ញុំមិនដឹងថាតើមេធាវីការពារក្ដីគាត់មានអារម្មណ៍យ៉ាងម៉េចទៅលើការសួរសំណួររបស់ខ្ញុំនោះទេ គឺយើងខ្ញុំគួរតែមានលទ្ធភាពសួរសំណួរទាំងអស់នេះ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២២:២៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចបដិសេធចោលនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី ដែលបានជំទាស់នឹងការតាំងសំណួរនេះ ហើយសំណួរនេះ គឺសមស្របដែលអង្គជំនុំជម្រះត្រូវការស្ដាប់។

សាក្សីឆ្លើយតបទៅនឹងសំណួរចុងក្រោយ ដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ!

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមលើកសំណួរសាជាថ្មីក្រោយពីមានការជំទាស់។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោកសាក្សី សុខ រឿ ខ្ញុំយោងទៅលើកំណត់ហេតុរបស់សាក្សីមួយដែលលោកបានដឹងហើយ សាក្សីនេះបានឆ្លើយនៅក្នុងកំណត់ហេតុរបស់គាត់ ឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេតដូចខាងក្រោមនេះ៖

[១៤:២៣:០៨]

ខ្ញុំសូមដកស្រង់សម្ដីតែម្ដង សម្ដីរបស់សាក្សីនុំង៖ “ប៉ុល ពត និង ខៀវ សំផន ដែលជាប្រធានផ្ទាល់របស់ខ្ញុំ គឺជាបុគ្គលដែលចេញបញ្ជាដោយផ្ទាល់នៅមន្ទីរក-១៨ នោះតែម្ដង”។ តាមបទពិសោធន៍និងការសង្កេតរបស់លោក តើការអះអាងរបស់សាក្សីរូបនោះត្រឹមត្រូវដែរឬទេ ឬក៏មិនត្រឹមត្រូវទេ?

**លោក សុខ រឿ៖**

**ឆ៖** បាទ ក-១៨ ដូចជាខ្ញុំនិយាយអំពី ក-៣ទេ, ក-៣ ហ្នឹងនៅនេះទេ ក-១៨ដូចនៅ -- ដូចអត់បាននិយាយទេ ក-១៨, មានតែក-៣។

**ស៖** សូមអធ្យាស្រ័យលោក សុខ រឿ សូមលោកកុំគេចវេះពីការឆ្លើយនឹងសំណួររបស់ខ្ញុំ។ ចៅក្រម ឡាវែន៍ បានសួរសំណួរជាក់លាក់អំពី តើ ខៀវ សំផន មានលទ្ធភាពប៉ុនណាដែរក្នុងការចេញ

បញ្ហា? -- ខ្ញុំឃើញមានការជំទាស់ពីខាងមេធាវីការពារក្ដី។ ដូច្នេះខ្ញុំសូមឈប់ត្រឹមត្រង់នេះសិន។

[១៤:២៤:៤៩]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមកត់សម្គាល់ខ្លីមួយ គឺថាបន្ថែមទៅលើការជំទាស់។ អម្បាញ់មិញសហព្រះរាជអាជ្ញាក្នុងការឆ្លើយតបទៅនឹងលោក គង់ សំអុន សាក្សីបាននិយាយតែអំពី ក-៨ ស្រាប់តែឥឡូវនេះ សហព្រះរាជអាជ្ញានិយាយថា ក-១៨ វិញ។ អ៊ីចឹងគឺចម្លើយរបស់សាក្សីនេះ បង្ហាញថាមានការភាន់ច្រឡំ មានភាពមិនច្បាស់លាស់។ អ៊ីចឹងអ្វីដែលល្អ គួរតែបំភ្លឺសំណួរឡើងវិញ ដោយរំឭកកន្លែងឲ្យគាត់ដឹងច្បាស់ ហើយដើម្បីឲ្យចម្លើយវាឆ្លើយទៅនឹងសំណួរបានច្បាស់លាស់។

**ប្រធានអង្គជំនុំ៖**

អរគុណបាទ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាសូមបង្ហាញនូវសំណួរម្ដងទៀត បញ្ជាក់ឲ្យច្បាស់លាស់ ដើម្បីសាក្សីមានលទ្ធភាពឆ្លើយ ហើយបញ្ជាក់អំពីចំណុចខ្វែងគ្នាផង។ ហើយចំណុច ក-៣, ក-៨ និង ក-១៨ ហ្នឹង គោលបំណងនៃការសួរ ហើយនិងអ្នកឆ្លើយហ្នឹងវាឆ្ងាយពេក រវាងដាក់មន្ទីរទីតាំងនៃមន្ទីរ ក ដែលពាក់ព័ន្ធនឹងការសួរ ហើយនិងអ្នកដែលត្រូវឆ្លើយ។

[១៤:២៦:០៦]

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** យើងត្រូវតែច្បាស់ទាំងអស់គ្នាតែម្ដង លោកសាក្សី។ លោកបានរៀបរាប់ថា អំពីមន្ទីរដែលលោកធ្វើការងារ គឺមន្ទីរ ក-១៨។ លោកធ្វើការងារពីឆ្នាំ១៩៨៩ ដល់ឆ្នាំ៩៦ គឺលោកធ្វើការងារនៅមន្ទីរ ក-១៨។ តើលោកសាក្សី លោកធ្វើការងារនៅមន្ទីរ ក-១៨ មែនដែរឬទេ នៅចន្លោះឆ្នាំ៨៩ ដល់៩៦ នោះដល់ឆ្នាំ១៩៩៦នោះ?

**លោក សុខ រឿ៖**

**ឆ៖** បាទ ចន្លោះនោះ ដូចជា ក-១៨។ វាអាហ្នឹង វានៅក្នុងអំឡុងសង្គ្រាមហើយបាទ។

**ស៖** ក្នុងពេលនោះ ដែលលោកធ្វើការងារជាមួយ ខៀវ សំផន តើលោកនៅពេលនោះ លោកកំពុងតែឆ្លើយថា លោកមិនដែលឃើញលោក ខៀវ សំផន ឬក៏មិនដែលធ្លាប់ឮគេប្រាប់ថា ខៀវ សំផន ចេញបញ្ជាដោយផ្ទាល់ទេឬ?

**ឆ៖** បាទ រឿងបញ្ជា ខ្ញុំអត់ដឹងទេបាទ។

**ស៖** តើលោក ខៀវ សំផន មានអង្គរក្សប៉ុន្មាននាក់ដែរ នៅពេលដែលលោកធ្វើជាអង្គរក្សគាត់ដែរនោះ?

**ឆ៖** បាទ មានតែខ្ញុំមួយ ហើយនិងម្នាក់ទៀត នៅក្មេង។

[១៤:២៨:០៩]

**ស៖** ខ្ញុំចូលទៅដល់ប្រធានបទមួយផ្សេងវិញនាពេលនេះ--

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ១៥នាទី ដោយចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ ក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលម៉ោងបីខ្វះដប់ប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២៨ នាទី ដល់ម៉ោង ១៤:៤៦ នាទី)*

[១៤:៤៦:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** លោក សុខ រឿ តើលោកគិតថាភាពស្មោះត្រង់គឺជាលក្ខណៈ ឬក៏ជាសញ្ញាវិជ្ជមាននៃអាកប្បកិរិយាដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទយល់ឃើញថាសំណួរនេះ សាក្សីដោយសារខ្លួនគាត់មិនមែនជាអ្នកជំនាញផ្នែកអត្តចរិតជាទូទៅ។ អ៊ីចឹងខ្ញុំគិតថា ការឲ្យសាក្សីបញ្ជាក់ពីការគិតរបស់គាត់ ប្រហែលជាមិនមានប្រយោជន៍ទេ។ ប៉ុន្តែជាក់ស្តែង គឺសាក្សីនេះត្រូវបានមកឆ្លើយបញ្ជាក់អំពីលោក ខៀវ សំផន ជាលក្ខណៈជាក់លាក់។ បើសិនជាឲ្យលោកសាក្សីឆ្លើយជាលក្ខណៈទូទៅបែបនេះ ប្រហែលជាពុំមានតម្លៃសម្រាប់តុលាការទេបាទ។ សូមអរគុណ។

[១៤:៤៨:៤៦]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន! អាកប្បកិរិយារបស់មនុស្សណាម្នាក់ហ្នឹង ដូចដែលមេធាវីការពារក្តីបានបញ្ជាក់ថាជាសាក្សីអត្តចរិតនោះ។ ការវាយតម្លៃអំពីអត្តចរិតរបស់បុគ្គលណាម្នាក់នៅគ្រប់កន្លែងទាំងអស់នៅក្នុងតុលាការទូទាំងពិភពលោក គឺតម្រូវឲ្យមានការវាយតម្លៃអំពីលក្ខណៈ អំពីភាពត្រឹមត្រូវ ហើយនិងទំនោរនៃអាកប្បកិរិយាជាទូទៅ។ ទាំងអស់នេះគឺជាផ្នែកនៃអាកប្បកិរិយារបស់មនុស្ស។ ដូច្នេះ ខ្ញុំសូមប្រធានអនុញ្ញាតឲ្យខ្ញុំបន្តទៅមុខទៀត។

**ប្រធានអង្គជំនុំ៖**

សំណួរអំមិញនេះ ការជំទាស់គឺមានប្រសិទ្ធភាព ពីព្រោះសេចក្តី-- លោកតំណាងសហព្រះរាជអាជ្ញាមិនគប្បីតាំងសំណួរឲ្យសាក្សីផ្តល់នូវចម្លើយជាសេចក្តីសន្និដ្ឋានអត្តនោម័តិរបស់ខ្លួននោះទេ ពីព្រោះសាក្សីមិនមែនអ្នកជំនាញទេ។ លោកអាចបន្តសំណួរផ្សេងទៀត។ ហើយពេលវេលាខ្លីទេ ពេលវេលាអតិបរមា រួមទាំងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផង គឺមិនឲ្យលើសពីម៉ោងបី និងសាមសិបនាទីទេ។

[១៤:៥០:១៥]

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមចោទសំណួរបន្តទៅទៀត។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** ផ្អែកតាមការសង្កេតរបស់លោកទៅលើ ប៉ុល ពត ហើយនិង ខៀវ សំផន នៅជាមួយគ្នានោះ តើលោកអាចបញ្ជាក់បានទេថា ខៀវ សំផន ស្មោះត្រង់កម្រិតណាដែរចំពោះ ប៉ុល ពត?

**លោក សុខ រឿ៖**

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ។

**ស៖** ពាក់ព័ន្ធទៅនឹងបញ្ហាដែលថា ខៀវ សំផន ចេញបញ្ជា ឬក៏ចេញសេចក្ដីណែនាំនោះ នៅក្នុងរយៈពេលដែលលោកនៅជាមួយ ខៀវ សំផន ចំនួន៧ឆ្នាំ តើគាត់ធ្លាប់និយាយជាមួយលោកអំពីថ្ងៃទី០៥ ខែមករា ឆ្នាំ៧៩ នៅពេលដែលគាត់ចេញបញ្ជានៅក្នុងបន្ទប់មួយដែលបញ្ជាទៅដល់មនុស្សមួយក្រុម ដែលក្នុងនោះមាន ឌុច ហើយនិង វស់ ស៊ុយ ផងនោះ។ តើលោកធ្លាប់ឮទេ?

[១៤:៥១:២៤]

**ឆ៖** បាទ អត់ទេ។

**ស៖** តើ ខៀវ សំផន ធ្លាប់និយាយជាមួយលោកអំពីរយៈពេលចំនួន១០ថ្ងៃ មុនពេលដែលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលក្នុងរយៈពេល១០ថ្ងៃនោះ គាត់នៅជាមួយ ប៉ុល ពត ហើយមានការដកស្រង់នៅពាក្យមួយថា "មានតែយើងតែពីរនាក់នោះ"។ តើលោកធ្លាប់ឮទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** នៅក្នុងរយៈពេលពីឆ្នាំទសវត្សរ៍៧០ ដល់ ៨០ តើលោកធ្លាប់ឮថា ខៀវ សំផន ធ្លាប់ផ្ដល់សុន្ទរកថា ធ្លាប់ថ្លែងសុន្ទរកថាតាមវិទ្យុ ឬក៏ថ្លែងសុន្ទរកថា ជាបុគ្គល។ តើលោកធ្លាប់ដែលឮទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** តើ ខៀវ សំផន ធ្លាប់និយាយជាមួយលោក ឬក៏លោកធ្លាប់ដឹងថា ខៀវ សំផន ធ្លាប់អាននូវចម្លើយសារភាព នៅពេលដែលមានការប្រជុំជាសាធារណៈ។ តើលោកធ្លាប់ដឹងទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** តើនៅពេលដែលលោកជួបប្រពន្ធ ខៀវ សំផន ចុងក្រោយ គឺលោកស្រី សុជាតិ ហ្នឹងតើនៅពេលណាដែរ?

**ធ៖** បាទ ៨៩ ដែរ។

[១៤:៥៣:៣៣]

**ស៖** ក្នុងសក្ខីកម្មដែលលោកផ្តល់ពេលមុននេះ គឺលោកថា នៅពេលដែលលោកចាកចេញភ្នំពេញ គឺមានការជ្រើសរើសដោយអង្គការ ដែលនៅពេលនោះគេត្រួតពិនិត្យទៅលើប្រវត្តិរូបរបស់លោកព្រមទាំងសកម្មភាពការងាររបស់លោក ហើយគេក៏ជ្រើសរើសលោកឲ្យមកទីក្រុងភ្នំពេញ។ ហើយបន្ទាប់មកលោកនិយាយដូចតទៅនេះ ខ្ញុំដកស្រង់សម្តីលោក៖ "ខ្ញុំជាកូនកសិករ ដូច្នេះខ្ញុំមិនមានការលំបាកអ្វីនោះទេ"។ តើមានអ្នកដទៃធ្លាប់បង្កការលំបាក ឬក៏មានការលំបាកនៅក្នុងដំណើរការជ្រើសរើសបែបនេះដែរទេ? តើធ្លាប់មានអ្នកណាដែលមានការលំបាក ឬក៏បង្កការលំបាកអ្វីទេ?

**ធ៖** បាទ អត់សូវយល់សំណួរបាទ។

**ស៖** គឺថា លោកមិនមានការលំបាកអ្វីដែលធ្វើឲ្យគេសម្រេចជ្រើសរើសលោកទេ ដោយសារតែលោកជាកូនកសិករ។ តើអ៊ីចឹងមែនដែរឬទេ?

[១៤:៥៥:០១]

**ធ៖** អាហ្នឹងសម្រេចទៅលើគេ ពីព្រោះគេជាអ្នកមើលប្រវត្តិរូបយើង។ ឯខ្លួនឯងអត់ដឹងថាយ៉ាង ណានោះទេ។

**ស៖** ហេតុអ្វីបានជាលោកនិយាយថាដោយសារតែលោកជាកូនវណ្ណៈកសិករទើបលោកមិនមានការលំបាក។ តើហេតុអ្វី?

**ធ៖** បាទ ពីព្រោះពីដើមវាធ្លាប់លំបាកដល់ចូលក្នុងហ្នឹងលំបាកទៀត យើងគិតថា ការលំបាកធម្មតារបស់ខ្ញុំទៅហើយបាទ។ លើកប្រឡាយ ជីកទំនប់ក៏ធ្លាប់ ចុះយើងនៅផ្ទះជាមួយឪពុកម្តាយពីដើមក៏លំបាកដែរ ដល់អ៊ីចឹងអានេះវាលំបាកគ្នាច្រើនតែម្តង។

**ស៖** តើមានអ្វីកើតឡើងចំពោះបុគ្គលនៅពេលដែលគេត្រួតពិនិត្យប្រវត្តិរូបទៅ ហើយរកឃើញថា បុគ្គលទាំងនោះមិនមែនមកពីវណ្ណៈកសិករតើមានអ្វីកើតឡើងដែរឬទេ?

**ធ៖** បញ្ហាហ្នឹងអត់ដឹងដែរបាទ។

**ស៖** នៅពេលព្រឹកនេះ លោកបាននិយាយថាខ្ញុំមិនដែលជំទាស់ ហើយខ្ញុំមិនដែលតវ៉ា។ តើមានអ្វីកើតឡើងចំពោះបុគ្គល ឬក៏មនុស្សណាដែលធ្វើការតវ៉ាជាមួយអង្គការ?

**ធ៖** បាទក្នុងចំណោមដែលខ្ញុំស្គាល់គ្នា ដូចអត់មានអ្នកណាជំទាស់អីទេ គឺការជ្រើសរើសសុទ្ធតែ

គេគិតប្រវត្តិរូបរបស់គេហើយៗ។

[១៤:៥៧:២៣]

**ស៖** ក្នុងអំឡុងពេលដែលលោកស្នាក់នៅទីក្រុងភ្នំពេញពីឆ្នាំ ៧៦ ដល់ ៧៩ តើលោកធ្លាប់ឮថាមានបុគ្គលណាម្នាក់ ឬក៏មានអ្នកណាម្នាក់ធ្លាប់តវ៉ាប្រឆាំងអង្គការដែរឬទេ?

**ឆ៖** បាទ កាលនោះអត់បានគិតអត់បាននឹកអីទេ ពីព្រោះខ្លួនឯងអត់នេះ គិតតែការងារ។

**ស៖** ហេតុអ្វីបានជាចាំបាច់ត្រូវគិតតែខ្លួនឯង? ហេតុអីបានជាមិនគិតពីអ្នកដទៃ?

**ឆ៖** ពីព្រោះការងារគេប្រើយើងធ្វើ យើងធ្វើ គេ គេធ្វើ។ គេខ្លួនគេ យើងខ្លួនយើង។ ការងាររៀងខ្លួន។

**ស៖** ពីឆ្នាំ១៩៧៦ ដល់ ៧៩ តើធ្លាប់មានថ្ងៃណាមួយ ឬក៏មានកន្លែងណាមួយ ឬក៏មានការភ័យខ្លាចអីណាមួយដែរឬទេ ឬធ្លាប់មានថ្ងៃណាមួយដែលលោកភ័យខ្លាចអីដែរឬទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** ខ្ញុំចង់បញ្ជាក់បន្តិចគឺថានៅពេលដែលលោកនៅក-៣ តើលោកធ្លាប់ជួបប្រពន្ធ ខៀវ សំផន ឈ្មោះ សូ សុជាតិ នៅចង្ក្រានបាយ នៅផ្ទះបាយ ឬក៏នៅកន្លែងណាមួយផ្សេងទៀត។ តើលោកធ្លាប់ជួបគាត់ទេ?

**ឆ៖** បាទ ជួបនៅ ក-៣។

**ស៖** តើជាការត្រឹមត្រូវដែរឬទេ ថាប្រពន្ធរបស់ ខៀវ សំផន គាត់មកចង្ក្រានបាយនៅ ក-៣ ជាញឹកញាប់? តើលោកអាចពណ៌នាបានថា ឃើញញឹកញាប់ ឬក៏ទៀងទាត់អីដែរឬទេ?

[១៥:00:0៤]

**ឆ៖** បាទ កាលហ្នឹងអត់ បាទអត់បានគិតថាយ៉ាងណានោះទេ គ្រាន់តែឃើញទៅយើងអត់បានមាត់ ឬក៏និយាយរកគាត់ផង គ្រាន់តែឃើញពីចម្ងាយបាទ។

**ស៖** នៅក្នុងរយៈពេលដែលក-៣ នោះ តើលោកធ្លាប់ឮឈ្មោះ សឿ វ៉ាស៊ី ហៅ ឌឿន ដែរឬទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** តើលោកធ្លាប់ដឹង ឬក៏ធ្លាប់ឮឈ្មោះ ឈឹម សំអោក ហៅ ប៉ង់ ដែរឬទេ?

**ឆ៖** បាទ អត់ទេ។

**លោក ឃឹត រេយ៉ន័រ៖**

សូមអរគុណលោក សុខ រឿន គឺថាខ្ញុំបានបញ្ចប់សំណួររបស់ខ្ញុំហើយ ប៉ុន្តែកញ្ញា សុង ឆវ័ន្ត ដែលជាសហការីរបស់ខ្ញុំ កញ្ញានឹងបន្តនូវសំណួរបន្តទៅទៀត។ សូមអរគុណលោកសាក្សី។

**កញ្ញា សុង ឆវ័ន្ត៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ សូមជម្រាបសួរផងដែរលោក សុខ រឿ ខ្ញុំ សុង ឆវ័ន្ត ជាតំណាងសហព្រះរាជអាជ្ញាជាតិ។ ខ្ញុំមានសំណួរពីរយ៉ាងច្រើន ប្រសិនបើសំណួរដែល -- ដែលចម្លើយដែលលោកឆ្លើយវាមិនពាក់ព័ន្ធគ្នា។

[១៥:០១:៤៩]

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** មុននេះលោកបានប្រាប់សហការីអន្តរជាតិរបស់ខ្ញុំថា លោកបានឃើញប្រពន្ធលោក ខៀវ សំផន នៅក-៣។ ហេតុអ្វីបានជាលោកដឹងគាត់ជាប្រពន្ធ ខៀវ សំផន នៅពេលនោះ?

**លោក សុខ រឿ៖**

**ឆ៖** បាទ ពេលនោះមិត្តភក្តិតែងតែប្រាប់ថា អ្នកនេះអ្នកប្រាប់គេឲ្យដឹងបាទ។

**ស៖** តើលោកនៅចាំទេ អ្នកណាជាអ្នកប្រាប់លោកថាគាត់ជាប្រពន្ធរបស់លោក ខៀវ សំផន?

**ឆ៖** បាទ អ្នកនោះគ្នាស្លាប់អស់ហើយ និយាយទៅវាដូចជានេះពេក ព្រោះថាខ្មោចពូ សុត, ខ្មោចពូ សៅ។

**ស៖** ចាស សូមអរគុណ។ នៅក្នុងអំឡុងពេលដែលលោកធ្វើជាកងការពារឲ្យលោក ខៀវ សំផន ចាប់ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៦ តើលោកមានដែលសង្កេតឃើញ ធ្លាប់ឮ ធ្លាប់បានដឹងដោយផ្ទាល់ ឬក៏តាមរយៈអ្វី តើលោក ខៀវ សំផន ដែលបង្ហាញ ដែលនិយាយ ដែលរំឭកពីការសោកស្តាយរបស់គាត់ចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមដែរឬទេ?

[១៥:០៣:៣៦]

**ឆ៖** អត់ដែលនិយាយទេ។

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានសំណួរអ្វីបន្ថែមទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាចុងក្រោយនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំមានសំណួរមួយចំនួនសម្រាប់សួរលោកសាក្សី។ បាទសូមជម្រាបសួរលោកសាក្សី! ខ្ញុំ ពេជ អង្គ មេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

[១៥:០៤:០៦]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ខ្ញុំចង់សូមសួរបន្តពាក់ព័ន្ធទៅនឹងករណីដែលលោកបានមានប្រសាសន៍ថា បានជួបប្រពន្ធលោក ខៀវ សំផន នៅ ក-៣ នោះ។ ថាតើលោកបានជួបគាត់ញឹកញាប់ដែរឬទេ?

**លោក សុខ រឿ៖**

**ឆ៖** បាទ មិនញឹកញាប់ទេ។

**ស៖** លោកអាចនិយាយបានទេ ប្រហែលជាប៉ុន្មានដងដែរ?

**ឆ៖** បាទ ក្នុង១ខែជួនណាម្ដង ជួនណាអត់ក៏មានដែរបាទ។

**ស៖** ចុះលោកទៅទីនោះធ្វើអ្វីដែរនៅចង្ក្រានបាយនុ៎ង?

[១៥:០៤:៥៤]

**ឆ៖** ច្រើនគាត់ដើរមកកន្លែងខ្ញុំ កន្លែងធ្វើការ ជម្រះស្មៅជម្រះអីអ៊ីចឹងទៅ។

**ស៖** លោកបានមានប្រសាសន៍ថា លោកជួបគាត់នៅចង្ក្រានបាយ។ ហើយចង្ក្រានបាយ ហើយនិងកន្លែងជម្រះស្មៅនៅជិតគ្នា ឬក៏យ៉ាងដូចម្ដេច?

**ឆ៖** ព្រោះកន្លែងធ្វើការ ជួនណាមកពីកន្លែងធ្វើការឆៀងទៅហ្នឹងទៅ ដើរកាត់ របៀបថាកន្លែងយើងធ្វើការវាកាត់ទៅមកបានដែរ។

**ស៖** អ៊ីចឹងលោកមានប្រសាសន៍ថា គាត់ទៅកន្លែងលោកជម្រះស្មៅ ហើយលោកមានប្រសាសន៍ថា លោកបានជួបគាត់នៅចង្ក្រានបាយដែរ។ តើខ្ញុំយល់អ៊ីចឹងត្រូវដែរឬទេ?

**ឆ៖** បាទ ត្រូវហើយ ន៎ែ! លើកទីមួយ ខ្ញុំជួបគាត់នៅកន្លែងខ្ញុំធ្វើការអ៊ីចឹងទៅ គេប្រាប់ខ្ញុំថា

ហ្នឹងជាគ្រួសាររបស់គាត់។ បាទ លើកក្រោយទៅ ក៏ខ្ញុំដើរកាត់ទៅតាមផ្ទះបាយហ្នឹងទៅ។ អ៊ីចឹងឧស្សាហ៍ទៅមក ដើរលេងចាស់ក្មេងៗ ល្ងាចអី ជួនណាមកពីរៀនអីក៏ដើរកាត់ត្រង់ហ្នឹងដែរ បាទ។ មិនជាព្រោកប្រាជ្ញអីទេ ប៉ុន្តែគ្រាន់តែឃើញ ត្រង់កន្លែងអ៊ីចឹងទៅ។

[១៥:០៦:២២]

**ស៖** បាទ តើពេលដែលលោកឃើញគាត់ហ្នឹង លោកដឹងថា គាត់កំពុងតែធ្វើអ្វីទេ?

**ឆ៖** បាទ គាត់អត់មានធ្វើអីទេ សាមញ្ញធម្មតា ជួនណាគាត់កំពុងមើលកូនគាត់អ៊ីចឹងទៅ។ ជួនណាគាត់កំពុងធ្វើម្ហូបអ៊ីចឹងទៅ។

**ស៖** បាទ លោកមានបានដឹងទេ ម្ហូបដែលគាត់ធ្វើហ្នឹង គាត់មានលើកទៅខ្លួនឯងសម្រាប់អ្នកណាគេពិសា? ហើយអ្នកណាខ្លះដែលគាត់ធ្វើម្ហូបជូនហ្នឹង?

**ឆ៖** បាទ នៅអំឡុងហ្នឹងអត់ដឹងទេ។

**ស៖** បាទ អម្បាញ់មិញ ពេលលោកមានប្រសាសន៍ថា -- ពេលដែលលោកនៅកាត់ស្មៅហ្នឹង គឺគេប្រាប់លោកថា លោកស្រីហ្នឹង គឺជាប្រពន្ធរបស់លោក ខៀវ សំផន។ ហើយពេលនោះ លោកមានដឹងថា លោក ខៀវ សំផន គាត់ធ្វើអ្វីដែរទេ?

**ឆ៖** បាទ អត់ដឹងទេ។

**ស៖** តើលោកអាចបញ្ជាក់បានទេ នៅឆ្នាំ១៩៧៨នុ៎ង លោកអាយុប៉ុន្មានដែរ?

**ឆ៖** ៧៨ ខ្ញុំប្រហែលជា១៧, ១៧ឆ្នាំ។

**ស៖** បាទ សូមអរគុណចំពោះការបញ្ជាក់ពីអាយុ។ លោកបានធ្លាប់ឮគេនិយាយអំពីឈ្មោះលោក ខៀវ សំផន។ តើលោកមានដឹងទេ លោក ខៀវ សំផន មានឈ្មោះអ្វីផ្សេងទៀត ក្រៅពីឈ្មោះខៀវ សំផន ហ្នឹងទេ?

[១៥:០៨:២៤]

**ឆ៖** ខ្ញុំច្រើនតែហៅ អ៊ំ ហែមៗ អ៊ីចឹងទៅ។

**ស៖** តែមានឮថា -- ធ្លាប់ឮអ្នកផ្សេងហៅគាត់ ឈ្មោះអ្វីផ្សេងទៀតដែរទេ?

**ឆ៖** បាទ អត់ឮទេ។

**ស៖** តើលោកមានដែលឈ្មោះ ខាង ដែរឬទេ?

**ឆ៖** ដូចអត់ អត់ឮ។

**ស៖** បាទ ខ្ញុំនឹងសួរទៅលើចំណុចផ្សេងទៀត។ ខ្ញុំចង់ដឹងថា ពេលដែលក្រោយមកដែលលោកធ្វើជាអង្គរក្សរបស់លោក ខៀវ សំផន ហ្នឹង លោកមានគោលការណ៍អ្វីទេ? នៅក្នុងខ្លួននៅក្នុងការបម្រើលោក ខៀវ សំផន តើលោកមានគោលការណ៍អី? ធ្លាប់គិតខ្លួនឯងទេ ថាខ្លួនឯងមានគោលការណ៍អ្វីនៅក្នុងការបម្រើលោក ខៀវ សំផន?

**ឆ៖** ពីព្រោះពេលនោះ ខ្ញុំគិតថា គាត់ជាអ្នកដឹកនាំ ហើយការពារធ្វើម៉េចជៀសផុតពីភាពគ្រោះថ្នាក់ដល់ជីវិតតែប៉ុណ្ណឹងទេ បាទ។

[១៥:០៩:៥៥]

**ស៖** នៅពេលដែលលោកទទួល -- គាត់និយាយណែនាំ ឬគាត់និយាយពីអ្វីមួយជូនលោកស្តាប់ តើលោកមានធ្លាប់ទៅនិយាយប្រាប់អ្នកណាផ្សេងទៀតដែរឬទេ?

**ឆ៖** បាទ ធ្លាប់ ព្រោះក្នុងក្រុម វាក្រុមជាមួយគ្នា នៅមន្ទីរជាមួយអីអីចឹងទៅណា។

**ស៖** ចុះអ្នកដែលផ្សេងពីហ្នឹងលោកមាននិយាយទេ ឬក៏លោករក្សាការសម្ងាត់នូវអ្វីដែលគាត់និយាយជម្រាបលោក?

**ឆ៖** បាទ អត់ទេ អត់មានពិភាក្សាអីទេ។ និយាយប្រាប់អ្នកដទៃផ្សេងទៀត។

**ស៖** ខ្ញុំចង់សួរ ជាពិសេសពាក់ព័ន្ធទៅនឹងបុគ្គលភាពរបស់លោក ខៀវ សំផន។ លោកនិយាយថាគាត់ជាមនុស្សហ្មត់ចត់ ថាតើគាត់ជាមនុស្សទទួលខុសត្រូវការងារដែរឬទេ អ្វីដែលថាលោកសង្កេតឃើញគាត់ហ្នឹង?

[១៥:១១:១៥]

**ស៖** បាទ ក្នុងអំឡុងខ្ញុំនៅ ឃើញគាត់ -- ឃើញតែសំកុកធ្វើការអី យើងអត់ដឹងតើគាត់កម្រិតណា ព្រោះអត់មានអីវាស់។ អត់ដឹង។ ដល់អីចឹង ខ្ញុំឃើញតែគាត់ធ្វើការអីចឹងទៅ ដល់ម៉ោងបាយ ប្រាប់ថាបាយ ដល់ម៉ោង។ អីចឹងដូចឃើញធ្វើការ ព្រោះពិសេសនៅក្នុងសម័យដែលសង្គ្រាម។ កិច្ចព្រមព្រៀងបារីសក៏ដោយ អីក៏ដោយ គាត់ធ្វើការ គាត់គិតតែខាងក្រៅ។ បាទ ការងារខាងក្រៅប្រទេស។ នេះក្នុងអំឡុងដែលខ្ញុំនៅជាមួយគាត់។

**ស៖** បាទ ខ្ញុំនៅសំណួរចុងក្រោយសម្រាប់ចំណុចនេះ ហើយបន្ទាប់មកខ្ញុំនឹងទៅចំណុចចុងក្រោយរបស់ខ្ញុំ។ តើលោកមានបានសង្កេតឃើញថាលោក ខៀវ សំផន ជាមនុស្សឯករាជ្យនៅក្នុងការងារដែរឬទេ? ពេលដែលគាត់កើតកិច្ចអីផ្សេងៗ គឺគាត់សម្រេចការងារស្អីៗ គាត់ធ្វើដោយខ្លួនឯង

ហើយគាត់មិនមិនទទួលបញ្ហា ឬក៏ថាមិនឲ្យអ្នកណាគេបញ្ហាគាត់ស្រេចតែចិត្ត។ តើលក្ខណៈរបស់គាត់ គាត់មានលក្ខណៈបែបនេះដែរឬទេ?

[១៥:១២:២៦]

**ឆៈ** បាទ អត់ រឿងហ្នឹងអត់យល់ អត់បានសង្កេតបាទ។

**សៈ** បាទ ចំណុចមួយ ខ្ញុំចង់សួរលោកដែរ ដែលជាចំណុចចុងក្រោយ។ ពាក់ព័ន្ធទៅនឹងមេធាវី ដែលលោកមានប្រសាសន៍ថាបានទៅជួបលោកប្រហែលជា១ឆ្នាំ ឬ២ឆ្នាំមុន តើមេធាវីនោះស្រី ឬប្រុស ហើយចាស់ ឬក្មេង លោកអាចបញ្ជាក់បានទេ?

**ឆៈ** បាទ ប្រុស។

**សៈ** គាត់ចំណាស់ណាដែរ?

**ឆៈ** ប៉ាន់ប្រហែលជាខុស ព្រោះនៅស្រួលប្រហែលល្បាក់ ៦០ដែរ។

**សៈ** គាត់ជាអ្នកនិយាយច្រើនដែរឬទេ? គាត់ជាអ្នកចូលចិត្តនិយាយច្រើនដែរឬទេ?

**ឆៈ** បាទ អត់ទេ។

**សៈ** គាត់ជនជាតិអី?

[១៥:១៣:៣៥]

**ឆៈ** បាទ គាត់និយាយខ្មែរ។ គាត់និយាយខ្មែរទេ សង្ស័យខ្មែរ ឬក៏បរទេស អត់សូវច្បាស់ត្រង់ហ្នឹងដែរ។

**សៈ** ពេលលោកស្តាប់សម្តីសំដៅរបស់គាត់ តើគាត់និយាយច្បាស់ដូចខ្មែរដែរឬទេ?

**ឆៈ** បាទ គាត់និយាយច្បាស់។

**សៈ** គាត់និយាយអ្វីខ្លះ ពេលដែលគាត់ -- ធ្វើយ៉ាងម៉េចបានលោកដឹងថា គាត់គឺជាមេធាវីរបស់លោក ខៀវ សំផន? ដែលលោកនិយាយថា គាត់ជាមេធាវី -- គាត់និយាយថា គាត់ជាមេធាវីរបស់លោក ខៀវ សំផន ហ្នឹង លោក គាត់មាននិយាយអីផ្សេងទៀតដែរឬទេ បញ្ជាក់ដើម្បីបញ្ជាក់ថាគាត់ជាមេធាវីរបស់លោក ខៀវ សំផន នោះ?

**ឆៈ** បាទ ខ្ញុំក៏-- អានេះគាត់ថា គាត់ថាខាងមេធាវីខាងលោក ខៀវ សំផន។ ប៉ុន្តែខ្ញុំក៏មិនបាន សួរបញ្ជាក់ដែរ គេអ្នកធំ អ្នកណាទៅបានសួរបញ្ជាក់។ ដល់អីចឹងគាត់សួរនាំ សួរអាយុកាលរបស់ខ្ញុំ អីចឹងទៅ ប្រវត្តិរបស់ខ្ញុំអីចឹងទៅ។ ក៏ថា អីចឹងបានមានតែប៉ុណ្ណឹង។ ព្រោកប្រាជ្ញគ្នាលេងធម្មតាអីចឹង

ទៅ។ មានតែប៉ុណ្ណឹង។

**ស៖** ពេលដែលគាត់ទៅហ្នឹងមានគ្នាប៉ុន្មាននាក់ ហើយមានជនជាតិបរទេសទៅជាមួយដែរឬទេ?

[១៥:១៥:០២]

**ឆ៖** បាទ មានជនជាតិបរទេសដែរ អ្នកសរសេរកំណត់ហេតុអី។

**ស៖** លោកអាចនិយាយបានទេ ជនជាតិបរទេសហ្នឹងមានរូបរាងយ៉ាងម៉េចដែរ ហើយអាយុប្រហែលជាប៉ុន្មាន? ស្រី ឬប្រុស?

**ឆ៖** ស្រី ប្រហែលជា ២០ជាង។

**ស៖** បាទ ខ្ញុំមានសំណួរចុងក្រោយមួយទៀតសម្រាប់លោក។ នៅពេលដែលលោកធ្វើការនៅ ក-៣ ឬក៏មន្ទីរផ្សេងទៀត មុននឹងលោកមកដល់ក-៣ តើនៅពេលដែលលោកធ្វើការនៅទីនោះ លោកមានដែលមានអារម្មណ៍ភ័យព្រួយថា និងអាចមានបញ្ហាស្អីកើតឡើងចំពោះរូបលោកដែរឬទេ?

**ឆ៖** បាទ ចំពោះខ្ញុំដូចអត់មានបារម្ភអីបាទ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកសាក្សី ប្រហែលជាសហការីខ្ញុំគាត់មានសំណួរ។ សូមអរគុណលោកប្រធាន។

[១៥:១៦:៣៤]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម និងភាគីទាំងអស់ជាទីគោរព និងជម្រាបសួរលោកសាក្សី។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ដោយខ្ញុំមិនដឹងអំពីមូលហេតុនៃវត្តមានរបស់លោកនៅទីនេះ អ៊ីចឹងខ្ញុំសួរសំណួរតិចតួចទេ។ ប្រហែលជាតែពីរ ឬបីសំណួរនោះទេ។ លោកបាននិយាយថា នៅពេលដែលលោកនៅជិតលោក ខៀវ សំផន មែនទែន ចាប់ពីឆ្នាំ១៩៨៩ មក ហើយគាត់បានឲ្យលោកធ្វើការងារ លោកបានជួយលោក ហើយគាត់និយាយជាមួយលោក ហើយគាត់មិនមើលងាយកសិករទេ។ តើដោយសារមូលហេតុនេះហើយ ឬដែលលោកដឹងគុណគាត់? ហើយ ឬក៏លោកចង់ធ្វើឲ្យគាត់សប្បាយចិត្ត ឬក៏លោកចង់អរគុណគាត់?

**លោក សុខ រឿ៖**

**ឆ៖** បាទ សំណួរដូចចាប់អត់ជាប់បាទ។ បាទ អត់ច្បាស់ សូមម្តងទៀត សំណួរវែងពេក។

**ស៖** ខ្ញុំនឹងសង្ខេបសំណួរ លោកបាននិយាយថា លោក ខៀវ សំផន បានគិតគូរអំពីលោកច្រើនណាស់ចាប់ពីឆ្នាំ១៩៨៩។ តើលោកចង់អរគុណគាត់ ចង់ដឹងគុណគាត់ ចំពោះអ្វីដែលគាត់បានធ្វើចំពោះលោកពីមុនមកដោយផ្ទាល់ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ចង់ -- សំណួរនូវរបៀបថា នៅសង្ស័យថា តើរបៀបថា ខ្ញុំអរគុណ -- ដូចអស់សួរយល់សំណួរសោះ។ តែចុងក្រោយ ដែលទាក់ចុងក្រោយ ពីខាងដើមយល់ហើយតែចុងក្រោយគាត់នេះ។

[១៥:១៨:៥៣]

**ស៖** ខ្ញុំសួរអម្បាញ់មិញ ដោយហេតុតែគាត់ចិត្តល្អជាមួយលោក អ៊ីចឹងលោកចង់អរគុណគាត់។ លោកយល់សំណួរទេ?

**ឆ៖** បាទ ចង់បានន័យថា ចង់អរគុណនៅពេលដែលមកបង្ហាញសាក្សី ឬក៏យ៉ាងម៉េច អាហ្នឹងវាចង់សួរទៅអ៊ីចឹងវិញបាទ?

**ស៖** ខ្ញុំគិតថា អត់មានបញ្ហាអ្វីទេ។ ខ្ញុំឈប់សួរលោកហើយ សូមអរគុណលោក។

**ប្រធានអង្គជំនុំ៖**

បាទ លោក សុខ រឿ អរគុណណា៎! ឥឡូវនេះការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានលះបង់ពេលវេលាដែលមានតម្លៃមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេលកន្លះថ្ងៃកន្លងមកនេះ។ ដោយភាពអត់ធ្មត់ខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ខ្លួន ហើយសក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។

សូមជូនពរលោកឲ្យមានសុខភាពល្អ ជួបតែសំណាងល្អ ហើយនិងមានសេចក្តីសុខសេចក្តីចម្រើន ហើយនិងវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១៥:២០:១២]

សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី១០ ខែមិថុនាឆ្នាំ ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយនៅថ្ងៃច័ន្ទ ទី១០ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់

សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-742 នៅពេលព្រឹក ហើយនៅពេលរសៀលស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-673 សូមភាគីនៃរឿងក្តី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការហើយនិងសាធារណជនជ្រាប។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក សុខ រឿ ទៅកាន់គោលដៅណាដែលគាត់មានបំណងចង់ទៅ ឬក៏ទៅកាន់លំនៅដ្ឋានរបស់គាត់វិញចុះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.កវិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញនៅព្រឹកថ្ងៃចន្ទទី១០ ខែមិថុនា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមដែលរៀបចំឧបករណ៍សោត-ទស្សន៍សម្រាប់គាត់អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:២១ នាទី)*